**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

# របាយការណ៍
# បូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ២០១៧ និង
# ទិសដៅអនុវត្តន៍ការងារពាណិជ្ជកម្ម ឆ្នាំ២០១៨

## សេចក្តីផ្តើម

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា បានយកចិត្តទុកដាក់អភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ ការបង្កើនល្បឿនសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ការពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ការលើកកម្ពស់សមត្ថភាពផលិត និងផ្គត់ផ្គង់ ការការពារ និងលើកតម្កើងកម្មសិទ្ធិបញ្ញា ការបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងបង្ក្រាបការក្លែងបន្លំលើផលិតផល ទំនិញ និងសេវា។

ក្នុងឆ្នាំ២០១៧-២០១៨នេះ គឺជាឆ្នាំចុងក្រោយនៃអាណត្តិទី៥របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងពាណិជ្ជកម្មក្នុងនាមសេនាធិការរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យធុរកិច្ច និងកិច្ចទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ បានខិតខំពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់ខ្លួន តាមរយៈការធ្វើកំណែទម្រង់នានា ដែលក្នុងនោះរួមមាន រចនាសម្ព័ន្ធគ្រប់គ្រងការអភិវឌ្ឍស្ថាប័ន ការពង្រឹងធនធានមនុស្ស និងការកែលម្អសេវាសាធារណៈជាដើម ដោយប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាទំនើប។ សមិទ្ធផល និងទិសដៅការងាររបស់ក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ២០១៧-២០១៨ រួមមានដូចខាងក្រោម៖

# ជំពូក១

## សកម្មភាព និង
## លទ្ធផលការងារពាណិជ្ជកម្ម

## ១. កំណែទម្រង់

### ១.១. កំណែទម្រង់រដ្ឋបាលសាធារណៈ

- បានរៀបចំចងក្រងការពិពណ៌នាមុខតំណែងក្នុងមុខតំណែងគ្រប់គ្រង ចាប់ពីថ្នាក់អគ្គនាយក រហូតដល់អនុប្រធានការិយាល័យ គ្រប់អង្គភាពក្រោមឱវាទក្រសួងជូនក្រសួងមុខងារសាធារណៈ
- បានចូលរួមសិក្ខាសាលាស្តីពី ការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ ដែលរៀបចំឡើងដោយក្រសួងមុខងារសាធារណៈ
- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំប្រមូល និងវិភាគទិន្នន័យក្នុងការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ។

### ១.២. កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាទៀងទាត់ និងទាន់ពេលវេលា ជូនអគ្គលេខាធិការដ្ឋានកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អន្តរក្រសួង និងដៃគូអភិវឌ្ឍន៍
- បានរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតអង្គភាពថវិកា ដោយបង្កើតឱ្យមានអង្គភាពថវិកាចំនួន៣១ ក្នុងនោះអង្គភាពមន្ទីររាជធានីខេត្តទាំង២៥ ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធ និង០៦ទៀតនៅរដ្ឋបាលកណ្តាល ជាអង្គភាពថវិកាមិនមែនជាអាណាប័កផ្ទេរសិទ្ធិ
- បានរៀបចំប្រកាសផ្ទេរជូនដល់មន្ទីរពាណិជ្ជកម្មទាំង២៥ ជាអាណាប័កផ្ទេរសិទ្ធិ និងបានអនុវត្តស្របតាមប្រកាស ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីនៃការអនុវត្តរបស់អង្គភាពថវិកា
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តថវិកាកម្មវិធី ការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រៀបចំកម្រងសេវាសាធារណៈថ្មី។

### ១.៣. កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបានធ្វើប្រតិភូកម្មលើមុខងារចំនួន០២ជូនរដ្ឋបាល រាជធានី ក្រុង ស្រុក សម្រាប់ឆ្នាំ២០១៧ ដូចមានខាងក្រោម ៖

- អនុញ្ញាតឲ្យមានការចេញC/O Form D នៅខេត្តបាត់ដំបង និងប៉ៃលិន
- គ្រប់គ្រងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ។

### ១.៤. កំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈ

#### ១.៤.១. កំណែទម្រង់ការចេញវិញ្ញាបនបត្រប ញ្ជាក់ប្រភពដើមទំនិញ(C/O)

- បានបន្ថយនីតិវិធីបែបបទការងារ លើតម្រូវការឯកសារដែលមិនចាំបាច់ ការបំពេញទម្រង់ផ្សេងៗ និងពន្លឿនការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញដោយ C/O Form N, C/O Under ៦.០០០ អឺរ៉ូ និង៨០០ ដុល្លារអាមេរិក ត្រូវចុះហត្ថលេខាត្រឹមថ្នាក់អគ្គនាយកដ្ឋាន
- បានចូលរួម និងសហការរៀបចំការប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តកម្ម ក្នុងការដាក់ពាក្យ និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) ដើម្បីកាត់បន្ថយពេលវេលា និងការចំណាយផ្សេង
- បានប្រតិភូកម្មជូនដល់មន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន សម្រាប់ការនាំចូលអង្ករពីបរទេស និងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទម្រង់ឌី (D) សម្រាប់ទំនិញកសិផល

- បណ្តុះបណ្តាលស្តីពីនីតិវិធី នៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (C/O Form D) នាំចេញកសិផលទៅបរទេសតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដល់មន្ទីរពាណិជ្ជកម្មនានា
- សហការរៀបចំប្រកាស ស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារនាំចេញ-នាំចូល
- ជម្រាបជូនទៅភាគីសហភាពអឺរ៉ុប ស្តីពីការស្ម័គ្រចិត្តចូលរួមអនុវត្តសាកល្បងនូវប្រព័ន្ធអ្នកនាំចេញ ដែលបានចុះបញ្ជីសម្រាប់ការនាំចេញទៅសហភាពអឺរ៉ុប និងទទួលយកការចែករំលែកបទពិសោធន៍ពីមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានសហភាពពន្ធដារ និងគយរបស់គណៈកម្មការអឺរ៉ុប ដើម្បីទទួលចំណេះដឹង ស្តីពីការអនុវត្តគម្រោងនៅដើមឆ្នាំ២០១៩
- បានសហការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនិងប្រព័ន្ធ ACYCUDA នៃគម្រោងបញ្ជរតែមួយជាតិ និងឈានឆ្ពោះទៅតភ្ជាប់ជាមួយបញ្ជរតែមួយអាស៊ាន (ASEAN SINGLE WINDOW) ហើយរំពឹងថាប្រព័ន្ធនេះនឹងអាចភ្ជាប់ និងផ្តល់ព័ត៌មានទាក់ទងនឹង C/O Form D នៅដើមឆ្នាំ២០១៨។

### ១.៤.២. កំណែទម្រង់ការចុះបញ្ជីពាណិជ្ជកម្ម

- បានចេញប្រកាសស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- បានចេញសេចក្តីជូនដំណឹង ស្តីពីនីតិវិធីទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម
- បានចេញសេចក្តីជូនដំណឹង ស្តីពីបន្តការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧
- បានចេញប្រកាស ស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារនាំចេញ- នាំចូល នៅក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ ក្នុងកម្រិតបច្ចេកទេសលើការបន្ថែម និងការកែសម្រួលកម្រៃសេវា រួមទាំងការផាកពិន័យករណីមិនបានបំពេញបែបបទ ក្នុងការផ្លាស់ប្តូរ ការកែប្រែផ្សេងៗ និងការមិនតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ
- បានធ្វើការទាក់ទងផ្ទាល់ ជាមួយធនាគារឯកជនមួយចំនួនដូចជាៈ ធនាគារកាណាឌីយ៉ា និងក្រុមហ៊ុន Visa លើការបន្ថែមមុខងារទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- បានចូលរួមក្នុងក្រុមការងារចម្រុះស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

### ១.៤.៣. កំណែទម្រង់ការចុះបញ្ជីម៉ាកពាណិជ្ជកម្ម

- បានអនុវត្តផែនការសកម្មភាព ក្រោមអនុស្សរណៈនៃការយោគយល់គ្នាក្នុងវិស័យកម្មសិទ្ធិបញ្ញាជាទម្រង់ទ្វេភាគី ឬពហុភាគី KIPO, SIPO, MOST, LAO, JPO, USPTO, THAILAND, ASEAN-CHINA, ASEAN-JAPAN, ASEAN-KOREA, ASEAN-NEW ZEALAND
- បានប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាជាមួយដៃគូអភិវឌ្ឍនានា រួមមាន អង្គការ WIPO FAO EU AFD KIPA អង្គភាពកម្មសិទ្ធិបញ្ញាប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងអនុព័ន្ធអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន និងស្ថានតំណាងពាណិជ្ជកម្មថៃប្រចាំនៅកម្ពុជា
- បានសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការនូវប្រព័ន្ធស្នើសុំចុះម៉ាកតាមអេឡិចត្រូនិកនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៧ ដោយមានអ្នកចូលរួមប្រមាណ ៣០០នាក់
- បានពង្រីកកិច្ចការពារដោយចុះបញ្ជី "ម្រេចកំពត" និង "ស្ករត្នោតកំពង់ស្ពឺ" នៅប្រទេសថៃនិងសហភាពអឺរ៉ុប

- បានសហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីជំរុញនិងអភិវឌ្ឍ"ក្រូចថ្លុងកោះទ្រង់" ក្នុងខេត្តក្រចេះ សម្រាប់ចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលកំពុងបន្តអនុវត្ត
- បានសហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក សហព័ន្ធចុងភៅ និងសណ្ឋាគារ ដើម្បីជំរុញ និងកសាងម៉ាកយីហោ "គុយទាវភ្នំពេញ" សម្រាប់ចុះបញ្ជីការពារជាម៉ាកសមូហភាពដែលកំពុងបន្តអនុវត្ត
- បានពិនិត្យ និងផ្តល់មតិលើការស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម " Malys Angkor" របស់សហព័ន្ធស្រូវអង្គរកម្ពុជា ដែលសហព័ន្ធនេះកំពុងតែកែតម្រូវឯកសារបន្ថែម សម្រាប់ការចុះបញ្ជីក្នុងពេល ឆាប់ៗនេះ
- បានរៀបចំសិក្ខាសាលាវគ្គបណ្តុះបណ្តាល ស្តីពីកម្មសិទ្ធិបញ្ញា នីតិវិធីចុះបញ្ជីប្រព័ន្ធអេឡិចត្រូនិក ការកសាងម៉ាកយីហោ ការកសាងសមត្ថភាពសហគ្រាសធនតូចនិងមធ្យម ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងភ្នាក់ងារតំណាងម្ចាស់ម៉ាក នៅទីស្តីការក្រសួងពាណិជ្ជកម្ម សាកលវិទ្យាល័យ និងបណ្តាខេត្តចំនួន ៩វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបប្រមាណ ៨៣៥នាក់។

## ២. សកម្មភាពពាណិជ្ជកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

### ២.១. លទ្ធផលនៃការផ្តល់សេវាសាធារណៈ

### ២.១.១. ការងារកម្មសិទ្ធិបញ្ញា

រយៈពេល ១១ខែ ឆ្នាំ២០១៧ ការចុះបញ្ជីម៉ាក និងការងារក្រោយចុះបញ្ជីមានការកើនឡើង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ ដូចមានទិន្នន័យក្នុងតារាងខាងក្រោមៈ

| ប្រភេទពាក្យស្នើសុំ | ប្រៀបធៀប | | |
|---|---|---|---|
| | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ប្រៀបធៀប |
| ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក | ៤ ៣២៨ | ៥ ១២៣ | ១៨,៣៦% |
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម | | ០១ | |
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | | ០១ | |
| ការចុះបញ្ជីម៉ាក | ៣ ៧៨០ | ៣ ៩១៧ | ៣,៦២% |
| ការទទួលពាក្យសុំស្រាវជ្រាវលទ្ធភាពចុះបញ្ជីម៉ាក | ៥១២ | ៤៨១ | -០,៦% |
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកអន្តរជាតិ | ១ ១៤៤ | ២ ២៥៩ | ៩៧,៤៧% |
| ការចុះបញ្ជីម៉ាកជាអន្តរជាតិ | ៣២៩ | ៨៤០ | ១៥៥,៣២% |
| ការបញ្ជាក់អំពីការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក | ២ ២៤៣ | ២ ៦៨០ | ១៩% |
| ការចុះបញ្ជីម៉ាកសាជាថ្មី | ១ ១៦០ | ១ ៨៤៦ | ៥៩% |
| ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក | ៥៦ | ៩៩ | ៧៧% |
| ការកត់ត្រាអាជ្ញាបណ្ណ ឬប្រេវ៉ានឆាយ | ៣១ | ៦៤ | ១០៦% |
| ការផ្លាស់ប្តូរផ្សេងៗ | ១ ៩០៥ | ២ ០០៣ | ៥% |
| ការធ្វើទុតិយតាវិញ្ញាបនបត្រ | ៦២២ | ៦៨៤ | ១០% |
| ការដាក់ពិន័យមកបង់ប្រាក់ចុះបញ្ជីម៉ាកសាជាថ្មីយឺតយ៉ាវ | ០៩ | ២៤ | ១៦៧% |
| ការទទួលពាក្យសម្រុះសម្រួលវិវាទ | ១៧ករណី | ១៤ករណី | -១៨% |
| ការសម្រុះសម្រួលវិវាទ | ១២ករណី | ១៦ករណី | ៣៣% |
| ការទទួលពាក្យស្នើសុំលុបម៉ាក | ៣០ករណី | ៣១ករណី | ៣,៣% |
| ការលុបម៉ាក | ២១ម៉ាក | ១២ម៉ាក | -៤៣ |

## ២.១.២. ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ

ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលបានអនុវត្តកន្លងមក ឃើញថាមានការកើនឡើងដូចមានតារាងខាងក្រោម៖

| ល.រ | ប្រភេទសហគ្រាសពាណិជ្ជកម្ម | ៩ខែ ឆ្នាំ២០១៦ | ៩ខែ ឆ្នាំ២០១៧ | ប្រៀបធៀប |
|---|---|---|---|---|
| I | ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចុះបញ្ជីថ្មី)៖ | | | |
| ១. | ក្រុមហ៊ុន | ២ ៨៦៩ | ៤ ៨១២ | ៦៧,៧% |
| ២. | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (ការិយាល័យតំណាង និងសាខាក្រុមហ៊ុនបរទេស) | ៦៨ | ៨៧ | ២៩,៩% |
| ៣. | សរុប | ២ ៩៣៧ | ៤ ៨៩៩ | ៩៨,៦% |
| | សហគ្រាសឯកបុគ្គល | ៧៨៦ | ១ ២០៩ | ៥៣,៨% |
| II | ការសុំវិញ្ញាបនបត្រផ្សេងៗ៖ | | | |
| ១. | ការកែប្រែផ្លាស់ប្តូរភាគហ៊ុន | ៦៧០ | ១ ០១៦ | ៥១,៦% |
| ២. | ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៣៨៥ | ២៣៨ | -៣៨,១% |
| ៣. | ការកែប្រែផ្សេងៗ | ៣ ៣៥៦ | ៦ ២៥០ | ៨៦,២% |
| ៤. | ពិន័យករណីមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរកែប្រែផ្សេងៗ | ៥២ | ៣៧៦ | |
| ៥. | សរុប | ៤ ៤៦៣ | ៧ ៨៩០ | ៩៩,៧% |
| | សហគ្រាសឯកបុគ្គល | ៥០ | ៩០ | ៨០% |
| III | ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ៖ | | | |
| ១ | សេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | ១ ៦៩៤ | ៧ ៣៦៧ | ៣៣៤,៨% |
| ២ | ការពិន័យចំពោះការមិនតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | ០ | ៤០១ | |
| IV | ការថតចម្លងឯកសារ | ១៥៩ | ២ | |
| V | រំលាយ៖ | | | |
| ១. | ក្រុមហ៊ុន-ការិតំណាង-សាខាក្រុមហ៊ុនបរទេស | ៣០ | ៥៦ | ៨៦,៦% |
| ២. | សហគ្រាសឯកបុគ្គល | ១ | ២ | ១០០% |
| VI | ការបម្រុងទុកនាមរណ៍៖ | | | |
| ១. | បម្រុងទុកនាមករណ៍ក្រុមហ៊ុន | ៤ ៩៥៧ | ៦ ៨៣៥ | |
| ២. | ពន្យាការបម្រុងទុកនាមករណ៍ក្រុមហ៊ុន | ៨១ | ១២៤ | |
| ៣. | បម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ៩៧៦ | ១ ៥០០ | |
| ៤. | ពន្យាការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ២ | ៥ | |
| VII | ការប្តូរវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្រុមហ៊ុនរដ្ឋនិងរដ្ឋចម្រុះឯកជន) | ២ | ១ | |

### ២.១.៣. ការផ្ដល់សេវានាំចេញ-នាំចូល

-ការនាំចេញទំនិញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មមានទឹកប្រាក់ចំនួន **៩.៥៥៩.២៧១.០៦៦** ដុល្លារ អាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ ដែលមានទឹកប្រាក់សរុបចំនួន **៨.០១៧.៩៧៧.៣៨១**ដុល្លារអាមេរិក គឺកើនឡើងចំនួន ១៩,២២%

- បានផ្ដល់អាជ្ញាប័ណ្ណនាំចូល មានទឹកប្រាក់សរុបចំនួន **២.០៨៧.៨៤៤,០៨** ដុល្លារអាមេរិក បើប្រៀបធៀបទៅឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន **៤៧៩.៤៤៥,៦៨** ដុល្លារអាមេរិក មានការកើនឡើងចំនួន ៣៣៥,៤៧%
- បានផ្ដល់អាជ្ញាប័ណ្ណនាំចេញ មានទឹកប្រាក់សរុបចំនួន**៩.១២៣.៣៩៧,៧១** ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ ដែលមានទឹកប្រាក់សរុបចំនួន**៦.៦៤៧.៣៣១,៨៨** ដុល្លារអាមេរិក មានការកើនឡើង ៣៧,២៥%
- ការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃ មានទឹកប្រាក់សរុបចំនួន**១៦.៥១០.៥៤៩,៣៨** ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន **១៥.៦៧៤.៨២១,៣៥** ដុល្លារអាមេរិក មានការកើនឡើង ៥,៣៣%
- តួលេខនាំចេញត្បូងពេជ្រសល់ពីការកែច្នៃ មានទឹកប្រាក់សរុបចំនួន **៨.៤៣៤.៨៩០,១២** ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន **៥.០៨៦.៥៩២,២៦** ដុល្លារអាមេរិក មានការកើនឡើង ៦៧,១៤ %
- សរុបរួមការនាំចេញឆ្នាំ២០១៧ មានការកើនឡើងគួរឲ្យកត់សម្គាល់ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៦។

## ២.២. ការខារជំរុញពាណិជ្ជកម្ម

### ២.២.១. ការរៀបចំពិព័រណ៍ពាណិជ្ជកម្ម

ក្នុងឆ្នាំ២០១៧ ក្រសួងបានរៀបចំ និងចូលរួមពិព័រណ៍ក្រៅប្រទេសបានចំនួន ៣៣លើក និងសម្របសម្រួលរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសបានចំនួន ១១៨លើក។

#### ក. ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស

- បានចូលរួមពិព័រណ៍វិនិយោគផលិតផលអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ឆ្នាំ២០១៧ នៅទីក្រុងគុនមីញ ខេត្តយូណាន ដែលត្រូវបានទទួលការឧបត្ថម្ភគាំទ្រដោយក្រសួងពាណិជ្ជកម្មចិន និងរដ្ឋាភិបាលថ្នាក់តំបន់ ដោយមានប្រទេសចូលរួមចំនួន ៨៦ប្រទេស ស្តង់ពិព័រណ៍ចំនួន ៨០០០ ស្តង់ និងក្រុមហ៊ុនចូលរួមប្រមាណជាង ៥០០០ក្រុមហ៊ុន
- បានចូលរួមពិព័រណ៍ និងវេទិកាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា នៅទីក្រុងបាងកក ប្រទេសថៃ មានក្រុមហ៊ុនចំនួន ២៥០ចូលរួម និងមានស្តង់ពាណិជ្ជកម្ម សរុបចំនួន ១៩៣ស្តង់ ក្នុងនោះ កម្ពុជាមានស្តង់ចំនួន ១០ស្តង់ ដែលមានក្រុមហ៊ុនចំនួន ២០ចូលរួម
- បានចូលរួមពិព័រណ៍ចិន-អាស៊ាន លើកទី១៤ ទីក្រុងណាននីង ប្រទេសចិន ដែលត្រូវបានបើកសម្ពោធជាផ្លូវការក្រោមអធិបតីភាព ឯកឧត្តម ចាង ការលី (Zhang Gaoli) ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និង សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានចូលរួមថ្លែងសុន្ទរកថាក្នុងពិធីបើកសម្ពោធដ៏មហោឡារិកនោះផងដែរ។ នាឱកាសនោះ គណៈកម្មការរៀបចំពិព័រណ៍បានផ្តល់ពានរង្វាន់ចំនួន ០២ដល់កម្ពុជាគឺ៖

- ពានរង្វាន់ល្អប្រសើរ លើការរៀបចំសកម្មភាពជំរុញពាណិជ្ជកម្ម និងវិនិយោគ (Best on Promotion Investment Cooperation)
- ពានរង្វាន់ល្អប្រសើរ លើការរៀបចំក្រុមហ៊ុន សហគ្រាសចូលរួមបានល្អ (Best on Industry Organizer) ដែលគោរពបានតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិនានារបស់គណៈកម្មការរៀបចំ។

- បានចូលរួមពិព័រណ៍សម្លៀកបំពាក់ "APPAREL SOURCING PARIS 2017" នៅទីក្រុងប៉ារីស ប្រទេសបារាំង ជាព្រឹត្តិការណ៍អន្តរជាតិដ៏ល្បីល្បាញ និងធំជាងគេបង្អស់នៅក្នុងតំបន់អឺរ៉ុប ដូច្នោះហើយការចូលរួមរបស់កម្ពុជាក្នុងពេលនោះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។ គណៈប្រតិភូពាណិជ្ជកម្មកម្ពុជា និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានដឹកនាំពាណិជ្ជករកម្ពុជា ចំនួន ០៩ក្រុមហ៊ុន បានចូលរួមព្រឹត្តិការណ៍នេះ ដើម្បីបង្កើនទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-បារាំង។

### ខ. ការរៀបចំពិព័រណ៍ និងព្រឹត្តិការណ៍ពាណិជ្ជកម្មក្នុងប្រទេស

- ក្នុងឆ្នាំ២០១៧ បានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយបានរៀបចំនៅខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង ស្វាយរៀង រាជធានីភ្នំពេញ និងខេត្តកែប។ គោលបំណងនៃការរៀបចំយុទ្ធនាការទិញផលិតផលខ្មែរនេះ គឺដើម្បីពញ្ញាក់ស្មារតីអ្នកប្រើប្រាស់ទាំងឡាយ ឱ្យងាកមកប្រើប្រាស់ទំនិញក្នុងស្រុក កាត់បន្ថយការហូរចូលទំនិញពីបរទេស ជំរុញការនាំចេញផលិតផលខ្មែរទៅក្រៅប្រទេស រួមចំណែកជួយពង្រឹងសមត្ថភាព ផលិត និងបង្កើនការងារក្នុងស្រុក។ បានរៀបចំពិព័រណ៍ទំនិញនាំចេញ-នាំចូល និងពិព័រណ៍ខេត្ត១ផលិតផល១កម្ពុជាលើកទី១២ ឆ្នាំ២០១៧។ ទន្ទឹមនោះក៏បានរៀបចំផងដែរនូវព្រឹត្តិការណ៍ធំៗ ដូចជា៖
    - ពិព័រណ៍អង្គរសង្ក្រាន្ត លើកទី៥ នៅខេត្តសៀមរាប
    - តាំងផលិតផលក្នុងព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល នៅខេត្តព្រៃវែង
    - រៀបចំប្រទីបរបស់ក្រសួងពាណិជ្ជកម្ម សម្រាប់ចូលរួមព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក
    - រៀបចំតាំងបង្ហាញផលិតផលបន្លែផ្លែឈើខ្មែរ និងផលិតផលកសិកម្មកែច្នៃដទៃទៀត លើកទី៩នៅខេត្តប៉ៃលិន
    - តាំងបង្ហាញផលិតផលកសិ-ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម នៅខេត្តសៀមរាប។

## ២.២.២. ការងារអភិវឌ្ឍន៍ទីផ្សារ

### ក. ការអភិវឌ្ឍទីផ្សារ

- បានសហការជាមួយក្រុមហ៊ុនឯកជនកម្ពុជា និងចិន បង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា នៅប្រទេសចិន ដើម្បីជំរុញផ្សព្វផ្សាយពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ និងវិនិយោគកម្ពុជា ព្រមទាំងការដាក់តាំងបង្ហាញផលិតផលកម្ពុជាជាអចិន្ត្រៃយ៍។ មជ្ឈមណ្ឌលទាំងនោះបានសម្ពោធជាផ្លូវការចំនួន ០៣ ទីតាំងគឺ នៅទីក្រុងហាយនីង ទីក្រុងក្វាងចូវ និងទីក្រុងស៊ីអាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- បានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រុមហ៊ុនឯកជនចិន បង្កើតភូមិវប្បធម៌កម្ពុជា-ចិន នៅទីក្រុងប៉េកាំង ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្ម ទេសចរណ៍ និងវប្បធម៌ រួមគ្នាកម្ពុជា-ចិន

- បានរៀបចំបង្កើតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា នៅទីក្រុងប៉ារីស ប្រទេសបារាំងដើម្បីផ្តល់លទ្ធភាពឲ្យពាណិជ្ជករនៅក្រៅប្រទេស អាចចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជា
- បានសហការជាមួយប្រទេសវៀតណាម រៀបចំបង្កើតផ្សារតំបន់ព្រំដែនកម្ពុជា នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ ព្រះរាជាណាចក្រកម្ពុជា ដែលគម្រោងឈានដល់ការសាងសង់នៅខែធ្នូនេះ
- បានរៀបចំវេទិកាជំរុញពាណិជ្ជកម្មនៅក្រៅប្រទេសចំនួន ០៣លើក នៅប្រទេសចិន គឺ (១) នៅទីក្រុងប៉េកាំង ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងទេសចរណ៍ កម្ពុជា-ចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** (២) នៅទីក្រុងម៉ាកាវ ស្តីពី Cambodia Trade, Investment & Development Forum និង (៣) នៅទីក្រុងហាងចូវ ស្តីពីការផ្សព្វផ្សាយ និងជំរុញពាណិជ្ជកម្មកម្ពុជា-ចិន
- បានរៀបចំចុះអនុស្សរណៈយោគយល់គ្នា (MOU) រវាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងម្ហូបអាហារ នៃសាធារណៈរដ្ឋប្រជាមានិតបង់ក្លាដេស និងឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ស្តីពីការលក់អង្ករសកម្ពុជាឲ្យប្រទេសបង់ក្លាដេសចំនួន ១លានតោន ក្នុងរយៈពេល ៥ឆ្នាំ និងបានជំរុញការចុះកិច្ចសន្យាអនុវត្តចំនួន ១៥០,០០០តោន ក្នុងឆ្នាំ២០១៧នេះ
- បានរៀបចំសិក្ខាសាលា និងវេទិកាស្តីពី "ការពិគ្រោះយោបល់រវាងអ្នកផលិត និងអ្នកផ្គត់ផ្គង់ផលិតផលខ្មែរ ជាមួយអ្នកប្រើប្រាស់ និងអ្នកចែកចាយបន្ត" នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួង ០៤ គឺៈ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរាជធានីភ្នំពេញ
- បានរៀបចំសិក្ខាសាលា ដើម្បីចងក្រងអត្តសញ្ញាណផលិតផលសក្តានុពលកម្ពុជា និងអមដោយការតាំងបង្ហាញផលិតផលខ្មែរ ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងពង្រីកការនាំចេញផលិតផលទាំងនោះទៅកាន់ទីផ្សារអន្តរជាតិ សរុបចំនួន ០៥លើក គឺនៅខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តកំពត
- បានចូលរួមសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចរចាជាមួយប្រទេសចិន ជាពិសេសជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័ក្ត (AQSIQ) នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងការបញ្ជូនបញ្ជីក្រុមហ៊ុននាំចេញអង្ករចូលប្រទេសចិន និងសុំចុះបញ្ជីនាំផលិតផលកម្ពុជាចូលទីផ្សារចិនបន្ថែមទៀតមានដូចជា ម្រេចកញ្ចុំងអង្ករ សណ្តែកសៀង ផ្លែស្វាយ ផ្លែចេក ផ្លែមៀន គ្រាប់កាហ្វេ ផ្លែស្រកានាគ និងសំបុកទឹកមាត់ត្រចៀកកាំ និងផលិតផលកសិកម្មផ្សេងៗទៀត។

## ខ. ការពង្រីកដៃគូពាណិជ្ជកម្ម

បានទទួលរៀបចំជំនួបពាណិជ្ជកម្ម រវាងពាណិជ្ជករក្នុងប្រទេសជាមួយពាណិជ្ជករ ក្រៅប្រទេស និងដឹកនាំពាណិជ្ជករទៅបំពេញបេសកកម្មពាណិជ្ជកម្មនៅក្រៅប្រទេស រួមមានៈ ប្រទេសជប៉ុន កូរ៉េ ឥណ្ឌា កាណាដា ចិន ថៃ និងវៀតណាម ដូចជាៈ

- វេទិកា The 4th India CLMV Business Conclave នៅប្រទេសឥណ្ឌា
- 3rd Edition of Buyer Seller meet for Ceramic Products នៅប្រទេសឥណ្ឌា
- ដឹកនាំក្រុមហ៊ុនឯកជនកម្ពុជាទៅចូលរួមវគ្គបណ្តុះបណ្តាល "Business Management" នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

- វេទិកា ២០១៧ Macao International Environmental Co-Operation Forum & Exhibition (២០១៧ MIECF) និងរៀបចំទីតាំង ដើម្បីសម្ពោធមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជានៅទីក្រុងម៉ាកាវ ព្រមទាំងសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយផលិតផលកម្ពុជា ដើម្បីទាក់ទាញវិនិយោគចិន
- វេទិកា ស្តីពី "The 2017 First China Innovation Conference" នៅទីក្រុងក្វាងចូវ សាធារណរដ្ឋប្រជាមានិតចិន
- កម្មវិធី Textiles India - 2017 នៅហ្គូចារ៉ាត ប្រទេសឥណ្ឌា
- សហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន រៀបចំសិក្ខាសាលាស្តីពី "ASAEN Design Selection-Promoting Trade in Creative Industry" នៅរាជធានីភ្នំពេញ
- សិក្ខាសាលា ស្តីពី "The 3rd Seminar on Promoting Service Trade" នៅទីក្រុង កូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី
- សហការជាមួយប្រទេសថៃ រៀបចំសិក្ខាសាលា ស្តីពីការពង្រីកសក្តានុពលពាណិជ្ជកម្មតាមព្រំដែនរវាងកម្ពុជា-ថៃ នៅរាជធានីភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "Developed Marked Oriented Export Promotion Strategy Marketing Strategy" នៅទីក្រុងណាកូយ៉ា ប្រទេសជប៉ុន
- ចូលរួមសិក្ខាសាលា ស្តីពី "CLMV Export Capacity Program in Laos" នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ
- ធ្វើជាវាគ្មិនក្នុងសិក្ខាសាលា ស្តីពី E-Commerce and Status Border Trade between Cambodia, Thailand and Vietnam "នៅរាជធានីភ្នំពេញ ដែលរៀបចំដោយសមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជា (CAMFFA)
- សហការជាមួយវៀតណាមរៀបចំវេទិកា ស្តីពី "Viet Nam-Cambodia 2017 Trade and Investment Forum " នៅរាជធានីភ្នំពេញ។

## គ. ការងារស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស

- បានបង្កើតស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស
- រហូតមកដល់ពេលនេះ ស្ថានតំណាងពាណិជ្ជកម្មអមស្ថានអគ្គរាជទូតកម្ពុជា ប្រចាំនៅក្រៅប្រទេសមានចំនួន ១២ គឺ ៖ សហព័ន្ធរុស្ស៊ី សហរដ្ឋអាមេរិក អូស្ត្រាលី បែលហ្ស៊ិក ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ចិន វៀតណាម ថៃ ជប៉ុន សាធារណរដ្ឋកូរ៉េ និងសឹង្ហបូរី។

### ❖ ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់

- ផ្សព្វផ្សាយ និងជំរុញសកម្មភាពពាណិជ្ជកម្ម ផ្លាស់ប្តូរព័ត៌មាន ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មសេវាកម្មរបស់កម្ពុជាជាមួយបរទេស
- ធ្វើការទាក់ទាញពាណិជ្ជករ និងវិនិយោគិនបរទេស ឲ្យកាន់តែមានចំណាប់អារម្មណ៍ ក្នុងការធ្វើជាដៃគូជាមួយភាគីកម្ពុជា

- រួមចំណែកក្នុងការផ្សព្វផ្សាយ និងលើកមុខមាត់ អំពីកិត្យានុភាព និងសក្តានុពលនៃប្រទេសកម្ពុជាជាអាទិ៍៖ ពាណិជ្ជកម្ម សេដ្ឋកិច្ច វិនិយោគ ទេសចរណ៍ ព្រមទាំងផ្នែកសំខាន់ផ្សេងទៀត ដែលមានការពាក់ព័ន្ធនឹងការជួយជំរុញដល់ការរីកចម្រើនសេដ្ឋកិច្ចកម្ពុជា។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំប្រទេសឥណ្ឌូនេស៊ី**

- បានចូលរួមពិព័រណ៍ពាណិជ្ជកម្ម-ទេសចរណ៍
- បានប្រឹក្សាពិគ្រោះយោបល់ និងភ្ជាប់ដៃគូពាណិជ្ជកម្មចំនួន១៤ ក្រុមហ៊ុន
- បានរៀបចំដាក់តាំងបង្ហាញម្ហូបអាហារ និងបង្អែមខ្មែរ នៅក្នុងពិធីបុណ្យខួបអាស៊ានលើកទី៥០
- បានពិគ្រោះយោបល់ និងសម្របសម្រួលដល់គណៈប្រតិភូសហគមន៍ម្រេចអន្តរជាតិ មកសិក្សាស្វែងយល់ពីស្ថានភាពម្រេចនៅកម្ពុជា
- សហការ និងសម្របសម្រួលជាមួយស្ថានទូតឥណ្ឌូនេស៊ី ប្រចាំនៅទីក្រុងភ្នំពេញ ដឹកនាំពាណិជ្ជករកម្ពុជាចំនួន ២៨ក្រុមហ៊ុន មកចូលរួម និងស្វែងរកដៃគូក្នុងឱកាសពិព័រណ៍ពាណិជ្ជកម្មឥណ្ឌូនេស៊ីលើកទី៣២។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅសហរដ្ឋអាមេរិក**

- បានចូលរួមសិក្ខាសាលា កិច្ចពិភាក្សា កិច្ចប្រជុំ និងសន្និបាតផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម រួមទាំងចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ
- បានផ្សព្វផ្សាយពីព្រឹត្តិការណ៍ពិព័រណ៍ផលិតផលនាំចេញ-នាំចូល ខេត្ត ១ ផលិតផល ១ កម្ពុជាលើកទី១២ និងវេទិកាស្រូវអង្ករកម្ពុជាលើកទី៦ ទៅក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិក បណ្តាស្ថានទូត និងស្ថាប័នឯកជនផ្សេងទៀត
- បានចូលរួមកម្មវិធីប្រជុំ Alliance of GSP Countries ដែលមានសមាជិកចំនួន ២៧ ប្រទេស ដើម្បីស្វែងយល់ និងតាមដាន ពីគោលនយោបាយរបស់រដ្ឋបាលប្រធានាធិបតី Trump ចំពោះបញ្ហា GSP និង យុទ្ធសាស្ត្រក្នុងការស្នើសុំពន្យា GSP ដែលនឹងត្រូវផុតកំណត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ខាងមុខ
- បានធ្វើការសម្របសម្រួល និងចូលរួមកិច្ចប្រជុំក្រុមប្រឹក្សានៃកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម វិនិយោគលើកទី៤ នៅរដ្ឋធានីវ៉ាស៊ីនតោន ដែលដឹកនាំដោយ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅប្រទេសម៉ាឡេស៊ី**

- បានសម្របសម្រួល និងចូលរួមជាមួយគណៈប្រតិភូកម្ពុជា ទៅសិក្សាស្វែងយល់បទពិសោធន៍ ពាក់ព័ន្ធនឹងកិច្ចដំណើរការឧស្សាហកម្មហាឡាល់នៅប្រទេសម៉ាឡេស៊ី
- បានផ្តល់ប្រឹក្សា និងជួយសម្របសម្រួល ផ្តល់ព័ត៌មានទំនាក់ទំនងដល់ក្រុមហ៊ុន ពាណិជ្ជករបរទេស ដែលមានវេសនដ្ឋាននៅម៉ាឡេស៊ី ដើម្បីទទួលបានការចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសកម្ពុជា បានចំនួន ៣៨ក្រុមហ៊ុន
- បានធ្វើរបាយការណ៍ស្តីពីទិន្នន័យតម្លៃប្រេងលក់រាយនៅតាមស្ថានីយនានាក្នុងប្រទេសម៉ាឡេស៊ីដើម្បីផ្តល់ជូនមកក្រសួងពាណិជ្ជកម្ម។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅប្រទេសសិង្ហបុរី**

- បានទទួលជួបពិភាក្សាការងារជាមួយបណ្តាក្រុមហ៊ុនឯកជនមួយចំនួន ដើម្បីស្វែងយល់ពីបរិយាកាសធ្វើពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា នីតិវិធីការចុះបញ្ជីពាណិជ្ជកម្ម និងស្វែងរកដៃគូវិនិយោគ។
- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា កម្មវិធីសម្ពោធពិព័រណ៍ពាណិជ្ជកម្ម ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍
- បានចូលរួមធ្វើបទបង្ហាញស្តីពីឱកាសធ្វើពាណិជ្ជកម្ម និងវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា នៅក្នុងសិក្ខាសាលា Market Insights Seminar on Cambodia ដែលរៀបចំដោយសហព័ន្ធពាណិជ្ជកម្មសឹង្ហបុរី។ ក្នុងសិក្ខាសាលានេះ មានតំណាងក្រុមហ៊ុនចូលរួមប្រមាណ ៥០ក្រុមហ៊ុន
- បានធ្វើលិខិតផ្សព្វផ្សាយ ស្តីពី "ពិព័រណ៍ផលិតផលនាំចេញ-នាំចូល ខេត្ត ១ ផលិតផល ១ កម្ពុជាលើកទី១២កម្រិតអន្តរជាតិ"ជូនដល់ក្រសួងការបរទេសសិង្ហបុរី ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម របស់ប្រទេសសិង្ហបុរី បណ្តាស្ថានទូត និងស្ថានបេសកកម្មបរទេសប្រចាំសិង្ហបុរីទាំងអស់ ព្រមទាំងស្ថាប័នឯកជនសំខាន់ៗ មួយចំនួន
- បានធ្វើរបាយការណ៍អំពីតម្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយចំនួនបួន ក្នុងប្រទេសសិង្ហបុរី ផ្ញើជូនក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើជាមូលដ្ឋានក្នុងការកំណត់តម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅទីក្រុងណាននីងប្រទេសចិន**

- ជួបប្រឹក្សា និងសម្របសម្រួលជូនភ្ញៀវវិនិយោគចិន មកពីខេត្តស៊ីឈួននៃប្រទេសចិន ដាក់ពាក្យ និងលើកគម្រោងវិនិយោគអាហារវេចខ្ចប់ខ្នាតតូចនៅ CDC
- បានចូលរួមរៀបចំវេទិកាផ្សព្វផ្សាយ និងជំរុញពាណិជ្ជកម្មកម្ពុជា ដោយរៀបចំដោយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងបានចូលរួមចំណែករៀបចំការងារសម្ពោធមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាមួយចំនួន ប្រចាំនៅប្រទេសចិនផងដែរ
- ចូលរួមរៀបចំពិព័រណ៍ និងកម្មវិធីដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ
- បានរៀបចំពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរ ដោយមានការបង្ហាញរបាំប្រពៃណីវប្បធម៌ជាតិ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាដែលមានការចូលរួមពីមន្ត្រីរដ្ឋាភិបាលចិន អ្នកវិនិយោគចិន និងនិស្សិតកម្ពុជាសរុបប្រមាណជាង ២០០រូប។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅប្រទេសវៀតណាម**

- បានចូលរួមទទួលស្វាគមន៍សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងប្រតិភូជាន់ខ្ពស់អមដំណើរ នៅក្នុងខេត្ត BINH PHUOC និងខេត្ត BINH DUONG ដែលជាទីតាំងប្រវត្តិសាស្ត្រទាំងប្រាំពីរកន្លែង សម្រាប់ដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហម
- ចូលរួមប្រជុំជាមួយគណៈកម្មាធិការប្រជាជនទីក្រុង ហូ ជីមិញ ស្តីពីគំរោងវិនិយោគទីក្រុង ហូ ជីមិញ ចំនួនពីរលើក និងប្រជុំនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា បានចំនួនមួយលើក ស្តីពីការសាងសង់ផ្សារអន្តរជាតិ (ផ្សារដា)

- បានទទួលជួបជាមួយលោកទីប្រឹក្សាពាណិជ្ជកម្មនៃប្រទេស IRAN បានចំនួនពីរលើក ហើយបានទំនាក់ទំនងពិភាក្សាគ្នាអំពីបញ្ហាពាណិជ្ជកម្ម លើផលិតផលរបស់កម្ពុជាមួយចំនួនសំរាប់ការនាំចេញទៅកាន់ប្រទេស IRAN ជាពិសេសអង្ករកម្ពុជា
- បានទទួលជួបបណ្ដាតំណាងក្រុមហ៊ុន ដើម្បីផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម ស្វែងយល់ពីទីផ្សារ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចុះបញ្ជីវិនិយោគនៅស្ថានតំណាងពាណិជ្ជកម្ម។

## ❖ ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅប្រទេសប៊ែលហ្សិក

- បានអមឯកអគ្គរាជទូតកម្ពុជា ចូលរួមរាល់កិច្ចប្រជុំពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ជាពិសេសចូលរួមប្រជុំជាមួយមន្ត្រីស្នងការអឺរ៉ុប ដើម្បីឆ្លើយបំភ្លឺរាល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មនៅសភាអឺរ៉ុប
- បានសហការជាមួយសមាគមខ្មែរ តាំងបង្ហាញផលិតផលសក្ដានុពលរបស់កម្ពុជា ជូនអតិថិជនប៊ែលហ្សិកនៅរាល់ពេលមានពិធីពិព័រណ៌ពាណិជ្ជកម្មទាំងឡាយ ដែលរៀបចំដោយប្រទេសម្ចាស់ផ្ទះ
- បានអញ្ជើញអាជីវករ ផលិតករ កសិករប៊ែលហ្សិក មកស្ដាប់បទឧទ្ទេសនាមអំពីវឌ្ឍនភាព ស្ថានភាពនយោបាយថ្មី និងភាពរីកចំរើនសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ ដែលធ្វើបទឧទ្ទេសនាម ដោយឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ក្នុងគោលបំណងគៀងគរវិនិយោគទុនថ្មីៗ ឱ្យមកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា
- បានផ្ដល់យោបល់ជូនអាជីវករ កសិករ ឧស្សាហករ សាស្ត្រាចារ្យ សិស្ស និស្សិត ដែលស្វែងយល់អំពីសក្ដានុពលពាណិជ្ជកម្មនិងកាលានុវត្តភាពធ្វើធុរៈកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

## ❖ ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅសាធារណៈរដ្ឋកូរ៉េ

- បានចូលរួមកិច្ចប្រជុំពិភាក្សារវាងមន្ត្រីមកពីស្ថាប័នគយកូរ៉េ ជាមួយនឹងមន្ត្រីជាតំណាងរបស់ស្ថានទូតប្រទេសអាស៊ាន ស្ដីពីកិច្ចសម្របសម្រួលពាណិជ្ជកម្ម ក្នុងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីលើការអនុវត្ត e-CO នៅទីក្រុងសេអ៊ូល។
- បានចូលរួមប្រជុំ និងសម្របសម្រួលការអនុវត្តកម្មវិធីនានា ដែលទាក់ទងជាមួយនឹងកម្ពុជាក្នុងក្របខ័ណ្ឌមជ្ឈមណ្ឌលអាស៊ាន-កូរ៉េ
- ក្នុងនាមស្ថានទូតបានទទួលរៀបចំពិព័រណ៍ចំនួន០២លើក និងបានចូលរួមជាកិត្តិយសនៅក្នុងពិព័រណ៍របស់កូរ៉េ ២០១៧ ចំនួន ០២លើក នៅទីក្រុងសេអ៊ូលផងដែរ
- បានប្រឹក្សាយោបល់ និងផ្ដល់ព័ត៌មាន ស្ដីពីពាណិជ្ជកម្ម វិនិយោគ និងស្វែងរកដៃគូអាជីវកម្មជូនដល់ក្រុមហ៊ុនកូរ៉េ បានមួយចំនួន។

## ❖ ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅប្រទេសស្វីស

- បានចូលរួមធ្វើឲ្យវិសោធនកម្មកិច្ចព្រមព្រៀងកម្មសិទ្ធិបញ្ញា លើសុខភាពសាធារណៈ ចូលជាធរមានកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧
- បានចូលរួមជំរុញឲ្យកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម ដែលចូលជាធរមានកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧

- សម្រេចបានក្នុងការធ្វើទម្រង់បែបបទ (Template) សម្រាប់ឲ្យសមាជិកជូនដំណឹង (Notification) លើវិធានប្រភពដើមទំនិញ (ROO)
- បានទទួលសេចក្តីជូនដំណឹង លើការអនុវត្តលើប្រព្រឹត្តិកម្មពិសេស របស់ពាណិជ្ជកម្មសេវា (Notification on Services Waivers) ពីប្រទេសសមាជិកចំនួន ២៥ និងសេចក្តីជូនដំណឹងលើវិធានប្រភពដើមទំនិញសមាជិកចំនួន ១៨ប្រទេស
- បានដាក់សំណើចរចា (Proposals) តំណាងឲ្យLDCs លើឧបត្ថម្ភធនជលផល និងចូលរួមដាក់សំណើជាមួយក្រុមប្រទេស G90 ស្តីពីប្រព្រឹត្តិកម្មពិសេស (Special &Differential Treatment) ទៅលេខាធិការដ្ឋាននៃអង្គការ WTO
- ទទួលបានជំនួយបច្ចេកទេស (Technical Assistances)ពីប្រទេសអូស្ត្រាលី អាល្លឺម៉ង់ និងចក្រភពអង់គ្លេស សម្រាប់ជួយដល់ការសម្របសម្រួលដល់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច
- ទទួលបានជំនួយបច្ចេកទេសលើការជូនដំណឹង (Technical Assistance on Notifications) ដល់កម្ពុជា ពីលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក
- ទទួលបានជំនួយបច្ចេកទេសផ្សេងៗសម្រាប់ចូលរួមប្រជុំ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ។

❖ **ស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅទីក្រុងប៉េកាំង**

- បានចូលរួមសហការរៀបចំព្រឹត្តការណ៍ផ្សេងៗ ជាមួយអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មកម្ពុជា នៅក្នុងទីក្រុង និងខេត្តមួយចំនួនរបស់ប្រទេសចិន
- បានជួបពិភាក្សាជាមួយ Mr. Luyan QI អគ្គនាយកក្រុមហ៊ុន Huawei Security Group (Macao) អំពីការងារបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មនៅម៉ាកាវ
- បានទស្សនកិច្ច Nansha Free Trade Zone នៃខេត្តក្វាងទុង ដើម្បីសិក្សាគោលនយោបាយនាំទំនិញកម្ពុជាចូលមកប្រទេសចិន តាមច្រក Nansha
- បានរៀបចំទទួលដំណើរទស្សនកិច្ចរបស់អភិបាលខេត្តសានស៊ី មកកាន់ប្រទេសកម្ពុជា ដើម្បីជំរុញពាណិជ្ជកម្មទ្វេភាគី
- បានជួបពិភាក្សាការងារជាមួយ Mr. WANG Shoujun ប្រធានក្រុមហ៊ុន CNNC ដើម្បីអបអរសាទរគម្រោងជីកអណ្តូងនៅកម្ពុជា ព្រមទាំងពិភាក្សាបញ្ហាគម្រោង ស្តីពីសុខាភិបាល និងថែទាំសុខភាព ដែលគម្រោងនេះ អាចជួយលើកស្ទួយវិស័យសុខាភិបាលនៅកម្ពុជា ហើយគម្រោងនេះ ភាគីក្រុមហ៊ុនចិនគាំទ្រឱ្យមានគម្រោងបណ្តុះបណ្តាល។ បានសម្របសម្រួលផងដែរ ឲ្យមានកិច្ចពិភាក្សាលើបញ្ហាផលិតអគ្គិសនីនៅកម្ពុជា។ ភាគីក្រុមហ៊ុនចិននឹងទំនាក់ទំនងជាមួយក្រសួងជំនាញ ដើម្បីទទួលបានគំរោងវិនិយោគលើវិស័យអគ្គិសនីនៅកម្ពុជាផងដែរ
- បានចូលរួមទទួលដំណើរទស្សនកិច្ចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មកកាន់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីចូលរួមវេទិកាកំពូលផ្លូវមួយ និងខ្សែក្រវ៉ាត់មួយ និងរៀបចំវេទិកាជំរុញពាណិជ្ជកម្ម និងទេសចរណ៍ ដែលមានក្រុមហ៊ុនប្រមាណ ៣០០ ក្រុមហ៊ុនចូលរួម
- បានចូលរួមទទួលដំណើរអញ្ជើញមកដល់នៃគណៈប្រតិភូកម្ពុជា ដែលដឹកនាំដោយ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា និងចូលរួមពិព័រណ៍ជំរុញណិជ្ជកម្មផងដែរ

- បានចូលរួមអមដំណើរគណៈប្រតិភូកម្ពុជា ដែលដឹកនាំដោយ សម្តេចតេជោនាយករដ្ឋមន្ត្រី ចូលរួមសម្ពោធពិព័រណ៍ចិន-អាស៊ាន និងបានជួយសម្របសម្រួល និងចូលរួមជាសក្ខីភាពក្នុងពិធីចុះហត្ថលេខា MOU រវាងក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជាជាមួយក្រុម CNNC របស់ប្រទេសចិន។

❖ ស្ថានតំណាងពាណិជ្ជកម្មប្រចាំប្រទេសជប៉ុន
- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា វេទិកាធុរកិច្ច ស្តីពីពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍
- បានទទួលជួប និងពិភាក្សាការងារជាមួយធុរកិច្ច ចំនួន ២៨ក្រុមហ៊ុន និងមន្ត្រីរដ្ឋាភិបាលជប៉ុន
- បានផ្សព្វផ្សាយព័ត៌មាន ស្តីពីការតាំងពិព័រណ៍ OPOP នៅភ្នំពេញ ដល់ពាណិជ្ជករជប៉ុន
- បានរៀបចំ និងចូលរួមការតាំងពិព័រណ៍ពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៧ នៅតូក្យូ
- ជួយសម្រួលដល់ភ្នាក់ងារជប៉ុន ក្នុងការនាំយកអំណោយជាឧបករណ៍ភ្លេងដែលប្រើរួចផ្តល់ជូនមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល ចំនួន ២លើក។

❖ ស្ថានតំណាងពាណិជ្ជកម្មប្រចាំប្រទេសថៃ
- បានចូលរួមសម្របសម្រួល ការត្រៀមរៀបចំចាត់ចែងកិច្ចប្រជុំវេទិកាលើកទី២ នៃប្រទេសកម្ពុជា ឡាវ ភូមា វៀតណាម និងថៃ ដែលគ្រោងរៀបចំនៅ ខែកុម្ភៈ ឆ្នាំ២០១៨ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា
- បានចូលរួមកិច្ចប្រជុំក្របខ័ណ្ឌ កិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ដោយប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់បណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិក
- បានចូលរួមសម្របសម្រួលពិព័រណ៍ និងវេទិកាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា
- បានចូលរួមសម្របសម្រួលកិច្ចប្រជុំគណរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃលើកទី៣នៅភ្នំពេញ
- បានជួបធ្វើការជាប្រចាំជាមួយទីប្រឹក្សាពាណិជ្ជកម្មប្រទេសហ្វីលីពីនប្រចាំទីក្រុងបាងកក ដើម្បីប្រមូលទិន្នន័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការសម្របសម្រួលពាណិជ្ជករ វិនិយោគិនហ្វីលីពីន មកស្វែងយល់ទីផ្សារ រកដៃគូពាណិជ្ជកម្ម និងការបណ្តាក់ទុននៅកម្ពុជា
- បានជួបពិគ្រោះយោបល់ និងសម្របសម្រួលដល់ពាណិជ្ជករថៃ និងក្រុមហ៊ុនបរទេសជារៀងរាល់ខែ ដើម្បីជំរុញផ្សព្វផ្សាយអំពីសក្តានុពលទីផ្សារពាណិជ្ជកម្ម និងការបណ្តាក់ទុននៅកម្ពុជា។

### ២.២.៣. ការងារអភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្ម

#### ក. ការងារគោលនយោបាយអភិវឌ្ឍន៍ផលិតផលហាឡាលនៅកម្ពុជា

- បញ្ចប់ការរៀបចំអនុក្រឹត្យ ស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា" និងទទួលបានការអនុម័តពីរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦
- រៀបចំយន្តការ និងនីតិវិធីសមស្របមួយចំនួន ដូចជាប្រកាសដែលមានការពាក់ព័ន្ធនឹងការចេញវិញ្ញាបនបត្របញ្ជាក់ហាឡាល ជូនប្រតិបត្តិករអាជីវកម្ម ដើម្បីបញ្ជាក់លើផលិតផល និង

សេវាកម្មហាឡាល ក្នុងន័យកសាងទំនុកចិត្តជូនអ្នកប្រើប្រាស់ទាំងក្នុង និងក្រៅប្រទេស ទាំងជនមុស្លីម និងមិនមែនមុស្លីម

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជាបានមួយលើកនៅរាជធានីភ្នំពេញ ដើម្បីផ្តល់ព័ត៌មានបឋមដល់ប្រតិបត្តិករអាជីវកម្មហាឡាល បានជ្រាបពីយន្តការនៃការអនុវត្តកិច្ចការ ហាឡាលនៅកម្ពុជា
- ក្រសួងបានចាត់បញ្ជូនមន្ត្រីរបស់លេខាធិការដ្ឋានកិច្ចការហាឡាល និងក្រុមឯកទេសហាឡាលធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីនីតិវិធី និងយន្តការនៃការអនុវត្តការចេញវិញ្ញាបនបត្រហាឡាល នៅប្រទេសម៉ាឡេស៊ី និងនៅប្រទេសថៃឡង់ដ៍
- លេខាធិការដ្ឋានកិច្ចការហាឡាលកម្ពុជា គ្រោងសហការជាមួយក្រុមជំនាញការប្រទេសម៉ាឡេស៊ី ដើម្បីរៀបចំកសាងផែនទីបង្ហាញផ្លូវ និងកសាងស្តង់ដារហាឡាលលើផលិតផលម្ហូបអាហារ និងភេសជ្ជៈ សណ្ឋាគារ និងភោជនីយដ្ឋាន ផលិតផលអង្ករ ម្រេច ដើម្បីតម្រូវតាមទីផ្សារដែលចង់បាន។

## ខ. ការអភិវឌ្ឍផលិតផលម្រេច

- បញ្ចប់ការសិក្សាស្រាវជ្រាវ និងចុះប្រមូលទិន្នន័យ ស្តីពីផលិតកម្ម កត្តាទីផ្សារ បញ្ហាប្រឈមដែលកំពុងកើតមានចំពោះកសិករ និងបានចងក្រងជាឯកសារយុទ្ធសាស្ត្រជំរុញការនាំចេញម្រេច និងកំពុងបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ
- រៀបចំកសាងសៀវភៅបន្ទុកផលិតម្រេច ឱ្យអនុលោមតាមស្តង់ដារ GAP និងជួយបង្កើតក្បាលម៉ាស៊ីនដឹកនាំវិស័យម្រេចនៅកម្ពុជា ដើម្បីកសាងទំនុកចិត្តម្រេចខ្មែរគុណភាពខ្ពស់ នៅលើទីផ្សារ
- រៀបចំវេទិកាម្រេចលើកទី១ នៅរាជធានីភ្នំពេញ ដើម្បីសិក្សាស៊ីជម្រៅពីបញ្ហាប្រឈម និងឱកាសក្នុងការអភិវឌ្ឍវិស័យម្រេចនៅកម្ពុជា ដែលគ្រោងមានសមាគមម្រេចទូទាំងប្រទេសចូលរួម និងរៀបចំបង្កើតក្រុមប្រឹក្សាម្រេចថ្នាក់ជាតិ តំណាងឲ្យវិស័យម្រេចទាំងមូល សម្រាប់ធ្វើជាដៃគូជាមួយរាជរដ្ឋាភិបាល។

## គ. ការអភិវឌ្ឍផលិតផលដំឡូងមី

- សហការជាមួយអង្គការ UNDP កម្ពុជា រៀបចំគោលនយោបាយដំឡូងមីកម្ពុជា ដើម្បីធានាឲ្យមានចីរភាព និងការរីកលូតលាស់ផ្នែកផលិតកម្ម ពង្រឹង និងធ្វើឲ្យប្រសើរឡើងសង្វាក់តម្លៃដំឡូងមី និងប្រែ ក្លាយទីផ្សារដែលបើកហើយ ឲ្យក្លាយជាទីផ្សារដែលមានសកម្មភាពពេញលេញ និងជឿទុកចិត្តបាន។ ឯកសារគោលនយោបាយនេះ នឹងបញ្ចប់នាចុងខែធ្នូ ឆ្នាំ២០១៧ ខាងមុខ
- សហការជាមួយអង្គការ UNDP កម្ពុជា បានរៀបចំវេទិកាវិនិយោគ និងធុរកិច្ចដំឡូងមី នៅខេត្តសៀមរាប ដើម្បីកៀរគរអ្នកវិនិយោគទុនមកពីបរទេសមកបើករោងចក្រកែច្នៃដំឡូងមី ឲ្យក្លាយជាផលិតផលផ្សេងៗ តាមតម្រូវទីផ្សារ ដែលមានអ្នកចូលរួមចំនួន ១៦០នាក់ មកពីប្រទេសចំនួន ០៧ប្រទេស ជាអ្នកវិនិយោគ អ្នកនាំចេញ អ្នកប្រមូលទិញ អ្នកកែច្នៃ និងសមាគមផលិតដំឡូងមី
- រៀបចំទិវាដំឡូងមីលើកទី២ នៅខេត្តប៉ៃលិន ដោយមានអ្នកចូលរួមជាពាណិជ្ជករ កសិករ អ្នកនាំចេញ អ្នកកែច្នៃចំនួន ១,១៥០នាក់ មកពីរាជធានី ខេត្តចំនួន ០៧

- បានរៀបចំបេសកកម្មពាណិជ្ជកម្មជំឡុងមី ទៅប្រទេសឥណ្ឌា និងប្រទេសឥណ្ឌូនេស៊ី ដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម លើផលិតផលម្រៀមីដែលកម្ពុជាផលិតបាន។

### ឃ. ការអភិវឌ្ឍកសិ-ពាណិជ្ជកម្មកម្ពុជា

បានរៀបចំវេទិកាថ្នាក់ជាតិ ស្តីពីការជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្មកម្ពុជាលើកទី៤ នៅខេត្តប៉ៃលិន និងលើកទី៥ នៅខេត្តសៀមរាប ក្នុងគោលដៅជំរុញការលើកកម្ពស់ផលិតផលក្នុងស្រុក ជំរុញឲ្យមានសកម្មភាពពាណិជ្ជកម្មរស់រវើក ជំរុញផលិតករសិប្បករ កសិករកម្ពុជា ឲ្យយកចិត្តទុកដាក់លើផលិតកម្មស្អាត ផលិតទំនិញដែលមានគុណភាព និងសុវត្ថិភាព សម្រាប់អ្នកប្រើប្រាស់ដើម្បីបង្កើតការងារ បង្កើនប្រាក់ចំណូល និងជួយទប់ស្កាត់ការធ្វើចំណាកស្រុករបស់យុវជនវ័យក្មេងនៅតាមមូលដ្ឋាន។

### ង. ការងារអភិវឌ្ឍន៍គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥

បានចូលរួមពិនិត្យមើលលើភាពជឿនលឿន នៃការអនុវត្តការងាររបស់ក្រសួងពាណិជ្ជកម្មក្រោមកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់ក្រសួង ក្នុងការចូលរួមអនុវត្តន៍តាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងបានរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាលេខាធិការដ្ឋានឲ្យរាជរដ្ឋាភិបាលកម្ពុជា។

### ច. ការងារអភិវឌ្ឍន៍គោលនយោបាយវិនិយោគកម្ពុជា

បានចូលរួមពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងគោលនយោបាយវិនិយោគថ្មីរបស់កម្ពុជា ដោយបានរំលេចពីសមិទ្ធផលជាវិជ្ជមានរបស់ក្រសួងពាណិជ្ជកម្ម ក្រោមកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់ ក្រសួង និងបានផ្តល់របាយការណ៍នេះ ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាលេខាធិការដ្ឋានឲ្យរាជរដ្ឋាភិបាលកម្ពុជា។

### ឆ. ការងារបរិយាកាសធុរកិច្ច វិនិយោគ និងទេសចរណ៍

- បានរៀបចំវេទិកាធុរកិច្ច វិនិយោគ និងទេសចរណ៍ ក្នុងឱកាសដែលប្រទេសកម្ពុជាបានចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ចិន-អាស៊ានប្រចាំឆ្នាំ បានចំនួន ៥លើក នៅទីក្រុងណាននីញ តំបន់ស្វយ័តខេត្តក្វាងស៊ី ដែលមួយលើកៗ មានពាណិជ្ជករចិនចូលរួមចំនួន ៥០០នាក់។ ការរៀបចំវេទិកាធុរកិច្ច វិនិយោគ និងទេសចរណ៍នាឱកាសនោះ គឺដើម្បីផ្សព្វផ្សាយពីឱកាសវិនិយោគ ទាក់ទាញទេសចរណ៍ចិនមកកាន់កម្ពុជា និងជំរុញទំហំពាណិជ្ជកម្ម រវាងប្រទេសទាំង២ កម្ពុជា-ចិន ឲ្យមានលក្ខណៈកាន់តែប្រសើរឡើង
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីកែទម្រង់ របស់ក្រសួងពាណិជ្ជកម្ម សម្របតាមរបត់សហគមន៍សេដ្ឋកិច្ចអាស៊ាន បានចំនួន ០១លើក នៅសាកលវិទ្យាល័យកម្ពុជា ដែលមានអ្នកចូលរួមចំនួន ៣៥០នាក់ និងលើកទី២ នៅសណ្ឋាគារអ៊ីមារ៉ាវី ដែលមានអ្នកចូលរួមប្រមាណ ១០០នាក់។

## ២.៣. ការងារកសាងបញ្ញត្តិច្បាប់ពាណិជ្ជកម្ម

### ២.៣.១. ការងារធ្វើសេចក្តីព្រាងច្បាប់

- សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសភាពាណិជ្ជកម្ម បានដាក់ជូន ទីស្តីការគណៈរដ្ឋមន្ត្រី និងកំពុងឆ្លងកាត់ដំណាក់កាលពិភាក្សាតាមបែបបទ និងនីតិវិធី
- សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្មកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សាក្រុមចង្អៀត ដែលមានការចូលរួមពីតំណាងក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ តាមការណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង បានបញ្ចប់ការត្រួតពិនិត្យ និងសម្រេចលើសេចក្តីព្រាងចុងក្រោយ នៅថ្នាក់ក្រសួង និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបានអន្តរស្ថាប័នសម្រេចមិនធ្វើវិសោធនកម្ម ដោយទុកឱ្យស្ថាប័នពាក់ព័ន្ធរៀបចំលិខិតបទដ្ឋានសម្រាប់អនុវត្តជាក់ស្តែងតាមការចាំបាច់
- ការផ្សព្វផ្សាយច្បាប់បានអនុវត្ត តាមគេហទំព័រក្រសួង (www.moc.gov.kh) និងចុះផ្សព្វផ្សាយផ្ទាល់ច្បាប់សំខាន់ៗដូចជាច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ច្បាប់មជ្ឈត្តការពាណិជ្ជកម្ម និង ច្បាប់ក្ស័យធន តាមបណ្តាខេត្តរួមមាន បាត់ដំបង សៀមរាប និង ព្រះសីហនុ។

### ២.៣.២. ការងារតម្កល់លិខិតជូនដំណឹង

ពីខែមករា ដល់វិច្ឆិកា ឆ្នាំ២០១៧ ការចុះបញ្ជីតម្កល់លិខិតជូនដំណឹងធ្វើបាន១១៧៦ (មួយពាន់មួយរយចិតសិបប្រាំមួយ) ច្បាប់ ដែលមានទ្រព្យអរូបិយ និងចលនទ្រព្យរូបិយមួយចំនួនត្រូវបានដាក់ធានា។

### ២.៣.៣. ការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តិ

- បញ្ចប់របាយការណ៍វាយតម្លៃបឋម (PAS) លើសេចក្តីព្រាងប្រកាសអន្តរក្រសួង"ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ" និងកំពុងពិនិត្យ ផ្នែកផ្សេងទៀតនៃសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងដើម្បីវាយតម្លៃបន្តទៀត
- ចូលរួមជាវាគ្មិនក្នុងសន្និសីទថ្នាក់តំបន់អាស៊ាន ស្តីពីការអនុវត្តល្អក្នុងការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តិ និងកិច្ចប្រជុំចម្រុះ រៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី និងវគ្គបណ្តុះបណ្តាលនានាដូចជាវគ្គសិក្សាស្តីពីការវិភាគបន្ទុកចំណាយ និងផលចំណេញ (CBA) និងវគ្គសិក្សាពីគោលការណ៍សេដ្ឋកិច្ចនៅសាលា CamEd ចំនួនពីរវគ្គ និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀត០៤លើក ដើម្បីបង្កើនសមត្ថភាពមន្ត្រីក្នុងការអនុវត្តការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ដែលជាតម្រូវការសម្រាប់តំបន់ និងពិភពលោក។

## ២.៤. ការងារអភិវឌ្ឍន៍វិស័យឯកជន

### ២.៤.១. ការងារអភិវឌ្ឍន៍ផលិតផល

- ចុះស្រាវជ្រាវផលិតផលសក្តានុពលដូចជាម្រេចនៅកោះកុង សិប្បកម្មចិញ្ចឹមក្រពើ ត្រសក់ផ្អែម ប្រហុកអប់ និងសិប្បកម្មឫស្សីនៅសៀមរាប សណ្តែកបាយនៅស្វាយរៀង ផ្កាអំបិលនៅកំពត ដូងក្រអូបនៅតាកែវ ក្រូច និងម្នាស់នៅបាត់ដំបង និងទំពាំងបារាំងនៅប៉ៃលិន

- ស្រាវជ្រាវនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង ព្រះសីហនុ និងខេត្តបន្ទាយមានជ័យ ដើម្បីធ្វើបច្ចុប្បន្នភាពផលិតផលសំខាន់ៗដែលមាននៅក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម កម្ពុជា ឆ្នាំ២០១៤-២០១៨ (CTIS 2014-2018)
- រៀបចំការបង្ហាញផលិតផលសាច់ក្ដាមរបស់សហព័ន្ធសមាគមជលផលសមុទ្រកម្ពុជា និងផលិតផលត្រសក់ផ្អែមរបស់សមាគមត្រសក់ផ្អែមសៀមរាបមានជ័យជូនដល់សណ្ឋាគារ និងអតិថិជននៅខេត្តសៀមរាប
- រៀបចំកិច្ចប្រជុំ និងដំណើរទស្សនៈកិច្ចរវាងសហព័ន្ធសូត្រអន្តរជាតិប្រទេសចិន និងគណៈកម្មការអភិវឌ្ឍន៍វិស័យសូត្រកម្ពុជា ទៅកាន់ខេត្តតាកែវ សៀមរាប កណ្ដាល បន្ទាយមានជ័យ និងរាជធានីភ្នំពេញ ដើម្បីជំរុញវិស័យសូត្រ និងកែលម្អគុណភាពផលិតផលសូត្រកម្ពុជា
- រៀបចំបង្កើតម៉ាកសញ្ញាសម្គាល់សូត្រខ្មែរ ក្រោមការឯកភាពពីគម្រោង EIF (CEDEP I)
- រៀបចំចងក្រងរបាយការណ៍លម្អិតស្ដីពីដំណាំសក្ដានុពលរបស់ខេត្តកណ្ដាល កោះកុង កំពត ប៉ៃលិន ព្រះវិហារស្វាយរៀង ស្ទឹងត្រែង បាត់ដំបង និងខេត្តត្បូងឃ្មុំ
- ប្រជុំសម្រេចលើអនុស្សារណៈយោគយល់គ្នា ក្នុងការបង្កើតវិទ្យាស្ថានសូត្រជាតិជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងគណៈកម្មការជំរុញអភិវឌ្ឍន៍វិស័យសូត្រកម្ពុជា ដែលមានក្រសួងពាណិជ្ជកម្មជាលេខាធិការដ្ឋាន និងចុះអនុស្សារណៈយោគយល់គ្នារវាង គណៈកម្មការជំរុញ និងអភិវឌ្ឍន៍វិស័យសូត្រកម្ពុជាជាមួយសហព័ន្ធសូត្រអន្តរជាតិ(ISU) ក្នុងទិសដៅ សហប្រតិបត្តិការទាំងការអភិវឌ្ឍ និងការជំរុញពាណិជ្ជកម្មសូត្រលើទីផ្សារអន្តរជាតិ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីគម្រោងជំរុញទីផ្សារសម្រាប់កសិករខ្នាតតូច (AIMS) នៅខេត្តបាត់ដំបង តាកែវ និងកំពង់ចាម និងសិក្ខាសាលាស្ដីពី ការផ្សព្វផ្សាយផលិតកម្ម និងផលិតផលសក្ដានុពល នៅខេត្តព្រះសីហនុ និងខេត្តសៀមរាប
- រៀបចំសិក្ខាសាលាស្ដីពី ការឆ្លើយតបរបាំងបច្ចេកទេសពាណិជ្ជកម្ម សុវត្ថិភាពចំណីអាហារ ការវេចខ្ចប់ និងការដាក់ ស្លាកសញ្ញា និងភស្តុភារ នៅខេត្តព្រះសីហនុ ស្វាយរៀង និងកំពត
- រៀបចំសិក្ខាសាលាស្ដីពីផលប៉ះពាល់នៃការកែច្នៃដំឡូងមី និងវិធានការកាត់បន្ថយហានិភ័យ នៅបាត់ដំបង ព្រមទាំងការពង្រឹងសមត្ថភាពអនុវត្តតាមតម្រូវការអនាម័យ និងភូតគាមអនាម័យនៅសៀមរាប ដោយសហការជាមួយ UNDP ។

### ក. **ការងារអនុវត្តន៍គម្រោងជំរុញទីផ្សារសម្រាប់កសិករខ្នាតតូច** ( AIMS )

- រៀបចំកិច្ចប្រជុំដំណើរការអនុវត្តគម្រោង (Launching of AIMS Project) ក្រោមអធិបតីភាពរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយការអនុវត្តគម្រោងដល់ដៃគូពាក់ព័ន្ធ និងសាធារណៈជន សំដៅទាក់ទាញការចូលរួម និងការគាំទ្រការអនុវត្តគម្រោងរយៈពេល៦ឆ្នាំនេះ និងគ្រោងអនុវត្តថវិកាប្រមាណជា៦១លានដុល្លារ ដែលក្នុងនោះជាថវិកាកម្ចីពីមូលនិធិអភិវឌ្ឍកសិកម្មអន្តរជាតិ (IFAD) និងថវិកាបដិភាគពីរាជរដ្ឋាភិបាល ព្រមទាំងការចូលរួមវិនិយោគរបស់វិស័យឯកជនក្រោមរូបភាព Public Private Partnership (PPP)
- រៀបចំរួចនូវអង្គការលេខ ជារចនាសម្ព័ន្ធសម្រាប់អនុវត្តគម្រោងរួមមានគណៈកម្មការតម្រង់ទិសដែលមានសមាសភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ក្រុមការងារអភិវឌ្ឍន៍ ខ្សែសង្វាក់តម្លៃ ការិយាល័យមណ្ឌលភូមិភាគ និងការិយាល័យតភ្ជាប់ នៅតាមភូមិភាគទាំងបី បង្កើតគណៈកម្មការលទ្ធកម្ម គណៈកម្មការវិនិយោគសម្រាប់ផ្ដល់ទុនវិនិយោគ ខ្សែសង្វាក់

តម្លៃ និងទុនវិនិយោគសម្រាប់បង្កើតទ្រព្យសាធារណៈ និងរៀបចំរួច កិច្ចព្រមព្រៀងដៃគូរវាងបណ្តាញកសិករ និងសភាពាណិជ្ជកម្ម ដែលត្រូវចូលរួមអនុវត្តគម្រោង

- រៀបចំរួចសេចក្តីបរិយាយការងារ សម្រាប់រើសទីប្រឹក្សាជាតិ និងអន្តរជាតិចំនួន២៩តួនាទី
- អនុវត្តការងារអភិវឌ្ឍខ្សែសង្វាក់តម្លៃរួមមាន ការធ្វើសិក្ខាសាលាបណ្តុះបណ្តាល និងណែនាំបច្ចេកទេសតាមមណ្ឌលភូមិភាគទាំង៣ ចំនួន៩លើក សម្រាប់ភាគីពាក់ព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណផលិតករ ចងក្រងក្រុមផលិតកម្មសំដៅអភិវឌ្ឍ និងរៀបចំវេទិកាពហុភាគីពាក់ព័ន្ធ
- រៀបចំសេចក្តីព្រាងសៀវភៅណែនាំសម្រាប់អនុវត្តគម្រោង (PIM) និងកូនសៀវភៅសង្ខេបការអនុវត្តជាក់ស្តែងសម្រាប់ក្រុមផលិតកម្ម និងភាគីពាក់ព័ន្ធ
- បានធ្វើលទ្ធកម្មរួចរាល់ សម្ភារ បរិក្ខារ ឧបករណ៍ ចាំបាច់សម្រាប់ការអនុវត្តគម្រោងរួមមាន រថយន្ត ទោចក្រយានយន្ត សម្ភារការិយាល័យ គ្រឿងបំពាក់ និងគ្រឿងសង្ហារឹម
- រៀបចំសេចក្តីព្រាង ការណែនាំបែបបទ ដើម្បីកំណត់ និងសម្រេចការស្នើសុំវិនិយោគខ្សែសង្វាក់តម្លៃ (VCIF) និងសៀវភៅសម្រាប់ការស្នើសុំវិនិយោគទ្រព្យសាធារណៈ (SDF)
- រៀបចំ kick-off meeting សម្រាប់បេសកកម្មត្រួតពិនិត្យគម្រោង និងចូលរួមក្នុងដំណើរការត្រួតពិនិត្យជាក់ស្តែងរបស់បេសកកម្មនេះនៅតាមមណ្ឌលភូមិភាគទាំងបី។

## ខ. ការងារអភិវឌ្ឍស្ថាប័នពាណិជ្ជកម្ម

- ចេញវិញ្ញាបនប័ត្រទទួលស្គាល់ការតម្កល់លក្ខន្តិកៈជូនសមាគម និងសម្ព័ន្ធអាជីវកម្មចំនួន១១ ដែលមានជំនាញអាជីវកម្មផលិតផលស្វាយចន្ទី សូត្រ ម្រេច ឱសថបុរាណចិន ជលផលសមុទ្រ ផលិតផលទឹកពិសា និងសមាគមសភាពាណិជ្ជកម្មអ៊ឺរ៉ុប ជប៉ុន កាណាដា និងសមាគម សិប្បកម្មខ្មែរ ព្រមទាំងសមាគមអាជីវកម្មកម្ពុជា-សិង្ហបុរី
- ចេញប្រកាសទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មមណ្ឌល ខេត្តបាត់ដំបង ប៉ៃលិន និងមណ្ឌលខេត្តកំពត កែប តាកែវ ព្រមទាំងចេញប័ណ្ណសម្គាល់សមាជិកភាពសភាពាណិជ្ជកម្ម ចំនួន ១៥មណ្ឌល ហើយរៀបចំពិធីប្រកាស និងប្រគល់អនុក្រឹត្យស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តស្វាយរៀង
- ចុះពង្រឹងការងារ និងសម្របសម្រួលការរៀបចំសន្និបាតសភាពាណិជ្ជកម្មខេត្តកោះកុង កំពង់ធំ ក្រចេះ ខេត្តកំពត-កែប-តាកែវ ខេត្តបន្ទាយមានជ័យ ខេត្តស្វាយរៀង ខេត្តសៀមរាប ឧត្តរមានជ័យ បាត់ដំបង និងខេត្តប៉ៃលិន
- ចុះពង្រឹងការងារ សមាគមអាជីវកម្មស្រុករតនៈមណ្ឌល និងស្រុកសំឡូត ខេត្តបាត់ដំបង សមាគមដំឡូងមីស្រុកត្រពាំងប្រាសាទ ស្រុកអន្លង់វែង និង ស្រុកបន្ទាយអំពិល ឧត្តរមានជ័យ
- រៀបចំចុះអនុស្សរណៈយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មបង់ក្លាដេស និងរវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មទីម័រ
- បោះឆ្នោតបង្កើតសមាគមថ្មីចំនួន៦គឺ សមាគមសូត្រកោះដាច់ សមាគមអាជីវកម្មស្វាយចន្ទីស្ទឹងសែន សមាគមស្វាយចន្ទីប្រាសាទបាល្ល័ង្គ និងសម្ព័ន្ធសមាគមដំឡូងមីឧត្តរមានជ័យ សមាគមស្វាយអន្លង់វែង និងសម្ពន្ធ័សមាគមដំឡូងមីបាត់ដំបង
- កែសម្រួលលក្ខន្តិកៈ និងកិច្ចព្រមព្រៀងការសាងសង់ផ្សាររួមសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា ព្រមទាំងផ្សព្វផ្សាយអំពីនីតិវិធីក្នុងការដាក់តាំងលក់ផលិតផលជលផល និងរៀបចំពិធីសម្ពោធផ្សាររួមនោះនៅកំពត ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- សហការជាមួយ UNIDO រៀបចំ និងដំណើរការគេហទំព័រសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជាព្រមទាំងទទួលបានប័ណ្ណសរសើរពីអង្គការUNIDO ចំពោះការចូលរួមចំណែកយ៉ាងសកម្មរបស់ក្រសួងពាណិជ្ជកម្ម ក្នុងការជំរុញផលិតផលជលផលសមុទ្រកម្ពុជា
- រៀបចំរបាយការណ៍សង្ខេប ស្តីពីផែនការកសាងសមត្ថភាពសមាគមជំឡូងមីកម្ពុជាជាមួយអង្គការ UNDP និងរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសដាំដុះជំឡូងមីបានទិន្នផលខ្ពស់ដល់សមាគមជំឡូងមីនៅស្រុកបន្ទាយអំពិល និងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងសមាគមអាជីវកម្មជំឡូងមីស្រុកសន្ទាន់ខេត្តកំពង់ធំ។

### ២.៤.២. ការងារពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម

- ត្រួតពិនិត្យសន្និធិប្រេងឥន្ធនៈនិងហ្គាស នៅខេត្តព្រះសីហនុ និងកោះកុងចំនួន ០៩ក្រុមហ៊ុន រួមមានក្រុមហ៊ុនសូគីម៉ិច ឆេវរ៉ុនកម្ពុជា អិលអេចអ ភីធីធីកម្ពុជា តូតាល់ លឹមលុង សាវីម៉ិច ប៊ីវីអឹម និងក្រុមហ៊ុនតេលាកម្ពុជា និងកែសម្រួលប្រកាសស្តីពីការកំណត់រូបមន្តថ្លៃលក់រាយប្រេងឥន្ធនៈ និងចេញសេចក្តីជូនដំណឹងស្តីពីថ្លៃលក់រាយនេះបានចំនួន២៧លើក
- តាមដានពីការវិវត្តន៍ថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ដើម្បីជាមូលដ្ឋានក្នុងការកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈ និងផ្សព្វផ្សាយដល់ក្រុមហ៊ុនលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- ត្រួតពិនិត្យ និងតាមដានការអនុវត្តសកម្មភាពការងារដល់មន្ទីរពាណិជ្ជកម្មចំនួន២២លើក នៅខេត្តកំពត កែប ព្រះសីហនុ តាកែវ ពោធិ៍សាត់ កំពង់ឆ្នាំង ក្រចេះ ត្បូងឃ្មុំ កោះកុង កំពង់ស្ពឺ ព្រៃវែង ក្រចេះ ត្បូងឃ្មុំ ស្វាយរៀង ឧត្តរមានជ័យ ព្រះវិហារ បាត់ដំបង ប៉ៃលិន សៀមរាប បន្ទាយមានជ័យ កំពង់ចាម កំពង់ធំ
- តាមដានការអនុវត្តចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្ម (ចេញដោយមន្ទីរចំនួន ៦០៣៥ លិខិត និង ដោយច្រកចេញចូលតែមួយចំនួន ២៦៨៥ លិខិត) និងលិខិតអនុញ្ញាតធ្វើអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ (១១៧០ លិខិត) និងលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស (ចំនួន ៤៥៥ លិខិត) ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើប្រតិភូកម្មពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ
- រៀបចំចងក្រងថ្លៃទំនិញចាំបាច់ប្រចាំជីវភាព និងសន្និធិស្រូវ-អង្ករតាមបណ្តារាជធានី-ខេត្ត។

## ២.៥. ការងារផែនការស្ថិតិ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម

### ២.៥.១. បោះពុម្ពព្រឹត្តបត្រពាណិជ្ជកម្ម

បានកែលម្អព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មដោយបន្ថែមមាតិកា ខ្លឹមសារ និងអត្ថបទថ្មីមួយចំនួន និងបោះផ្សាយព្រឹត្តិបត្រនេះចំនួន២៤ លេខ ស្មើនឹង ៧២០០ច្បាប់។

### ២.៥.២. ការងារចងក្រងស្ថិតិ និងព័ត៌មាន

- បានចងក្រង និងផ្សព្វផ្សាយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ មួយចំនួនលើទីផ្សារ ក្នុងប្រទេសប្រចាំសប្តាហ៍ និងប្រចាំខែ
- បានផ្តល់ទិន្នន័យស្ថិតិនាំចេញ-នាំចូលដល់បុគ្គល ដែលបានស្នើសុំ ចំនួន១៥០លើក
- បានរៀបចំ និងបញ្ចូលទិន្នន័យស្ថិតិទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិនាំចេញ-នាំចូលរបស់ក្រសួង ព្រមទាំងស្រាវជ្រាវ និងចងក្រងឯកសារ ស្តីពីព័ត៌មានពាណិជ្ជកម្មជាតិ និងអន្តរជាតិ

- បានរៀបចំស្ថិតិទំនិញនាំចេញប្រចាំខែក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មផ្សេងៗដូចជា ស្ថិតិនាំចេញទៅកាន់ USA, CANADA, CENTRAL & SOUTH AMERICA, EU, NON-EU, AFRICA , MIDDLE EAST និង ASIA AND OCEANIA។

### ២.៥.៣ ការងាររៀបចំផែនការពាណិជ្ជកម្ម

- រៀបចំឯកសារគាំទ្ររួមមាន តារាងសូចនាករ ចំណាត់ថ្នាក់ព័ត៌មាន/ទិន្នន័យ និងប្រភពព័ត៌មានទិន្នន័យ សម្រាប់កសាង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្ម ឆ្នាំ២០១៩-២០២៣" និងកិច្ចប្រជុំសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូល
- ត្រួតពិនិត្យ និងកែសម្រួលធាតុចូលរបស់ក្រសួងពាណិជ្ជកម្ម នៅក្នុង "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" សម្រាប់ការធ្វើមូលដ្ឋានីយកម្មគោលដៅនៅក្នុងបរិការណ៍កម្ពុជា
- សម្របសម្រួល និងរៀបចំព័ត៌មានទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៦ ហើយបញ្ជូនទៅក្រសួងផែនការ ដើម្បីកសាងទិន្នន័យថ្នាក់ជាតិ
- ដាក់បញ្ចូលកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) បីឆ្នាំរំកិល ២០១៨-២០២០ របស់ក្រសួងពាណិជ្ជកម្មទៅក្នុងកម្មវិធី ក.វ.ស. ONLINE របស់ក្រសួងផែនការ
- ផ្តល់ធាតុចូលក្រសួងពាណិជ្ជកម្ម ទៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (.ជ.អ.យ.ផ)២០១៤-២០១៨
- ផ្តល់តារាងសូចនាកររបស់ក្រសួងពាណិជ្ជកម្មសម្រាប់ដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ មូលដ្ឋានសូចនាករអភិវឌ្ឍន៍ជាតិ (CAMInfo) ទៅក្រសួងផែនការ។

### ២.៥.៤. ការងារព័ត៌មានវិទ្យា ( ICT )

- កែលម្អ និងសម្រិតសម្រាំងព័ត៌មានចាំបាច់ក្នុងគេហទំព័រក្រសួង ដោយបញ្ចូលព័ត៌មានថ្មីៗពីសកម្មភាពថ្នាក់ដឹកនាំ សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំថ្ងៃ ថ្លៃលក់រាយប្រេងឥន្ធនៈ អាត្រាប្តូរប្រាក់ ស្ថិតិនាំចេញ-នាំចូលផលិតផល និងតម្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ
- អភិវឌ្ឍសមត្ថភាពគេហទំព័ររបស់ក្រសួងដូចជា ការបង្កើតទំព័រផ្ទុកព័ត៌មានថ្មី ក្រោមរូបភាព ជាព្រឹត្តិបត្រព័ត៌មាន ដែលឆ្លុះបញ្ចាំងពីថ្លៃទំនិញប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ
- ដាក់ឲ្យប្រើប្រាស់ Email Domain Name របស់ក្រសួង និងធ្វើការបណ្តុះបណ្តាលនៅទីស្តីការក្រសួង និងនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តទាំង២៥
- ដាក់ដំណើរការសេវា INTERNET ល្បឿនលឿន 200Mbps និងតម្លើងឧបករណ៍ MikroTik នៅក្នុងទិន្នដ្ឋានសំរាប់បែងចែកល្បឿន INTERNET ទៅតាមតម្រូវការ និងដាក់ឱ្យដំណើការសេវា INTERNET តាមប្រព័ន្ធ HOTSPOT
- ផ្ទេរទិន្នន័យ និងប្រព័ន្ធប្រតិបត្តិការមានកិច្ចធានា (SETFO) មកក្នុងទិន្នដ្ឋានរបស់ក្រសួង
- ធ្វើការតម្លើង Server និង Storage សម្រាប់ Back-Up ការងារចុះបញ្ជីពាណិជ្ជកម្ម និងប្តូរ Hard Disk Server ចំនួន ៣គ្រឿង ដើម្បីសម្រួលដល់ដំណើរការនៃប្រព័ន្ធ
- ផ្ទេរទិន្នន័យនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម C/O មក Server នៅលើ Cloud ថ្មី ដើម្បីសម្រួលប្រតិបត្តិការស្នើសុំ C/O ONLINE
- រៀបចំប្រតិបត្តិការជួសជុលថែទាំទិន្នដ្ឋាន ដោយដាក់ឧបករណ៍ Heat Detector សម្រាប់ត្រួតពិនិត្យសីតុណ្ហភាព និងសិក្សាការបំពាក់ Firewall Palo Alto ជាមួយក្រុមហ៊ុនឯកជន ព្រមទាំងដាក់

ប្រព័ន្ធ Anti Virus សម្រាប់ Servers របស់ក្រសួង និងប្រព័ន្ធទិន្នន័យ (Database) និងបានជួសជុលម៉ាស៊ីន Scan មេដៃ នៅតាមនាយកដ្ឋាននានា ។

## ២.៦. ការងារសមាហរណកម្មសេដ្ឋកិច្ចតំបន់ អនុតំបន់ និងដៃគូ

### ២.៦.១. សហគមន៍សេដ្ឋកិច្ចអាស៊ាន

- ថ្ងៃទី២៦-២៩ ខែមេសា ឆ្នាំ២០១៧៖ កិច្ចប្រជុំកំពូលអាស៊ានលើកទី៣០នៅទីក្រុងម៉ានីលឡា ប្រទេសហ្វីលីពីន ៖
    - បានទទួលស្គាល់អំពីសេចក្ដីត្រូវការរបស់អាស៊ាន ក្នុងការត្រៀមខ្លួនអោយបានល្អ ដើម្បីអាចទាញយកផលប្រយោជន៍អោយបានជាអតិបរមាពី 4th Industrial Resolution
    - បានពេញចិត្តចំពោះការផ្ដោតយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះការអភិវឌ្ឍ MSMEs ដែលជាកម្លាំងរុញច្រានកំណើនសេដ្ឋកិច្ច
    - បានលើកទឹកចិត្តអាស៊ានបន្តពង្រឹងការចូលរួមរវាងវិស័យឯកជន និងសាធារណៈ លើកកម្ពស់តម្លាភាពវិធានការមិនមែនពន្ធគយ សាមញ្ញកម្មនីតិវិធីគយ ជាដើម និងស្វាគមន៍ចំពោះគោលដៅកំណត់កាត់បន្ថយតម្លៃជួញដូរពាណិជ្ជកម្ម ១០% នៅត្រឹមឆ្នាំ ២០២០។
- កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន AEM លើកទី៤៩៖
    - បានអនុម័ត ASEAN Seamless Trade Facilitation Indicators
    - បានអនុម័ត ASEAN Inclusive Business Framework
    - បានអនុម័ត ASEAN Work Programme on Electronic Commerce 2017-2025
    - បានអនុម័ត AEC 2025 Trade Facilitation Strategic Action Plan
    - បានអនុម័ត ASEAN High-Level Principles on Consumer Protection
    - បានអនុម័ត ASEAN Regional Principles for Good Business Registration Practices
- ថ្ងៃទី១២-១៤ ខែវិច្ឆិកា ឆ្នាំ២០១៧៖ កិច្ចប្រជុំកំពូល អាស៊ានលើកទី៣១ នៅទីក្រុងម៉ានីលឡា ប្រទេសហ្វីលីពីន ៖
    - បានអនុម័ត ASEAN Declaration on Innovation
    - ASEAN-wide Self-Certification Scheme នឹងអនុវត្តបានក្នុងឆ្នាំ ២០១៨ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន នឹងត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ ២០១៨
    - បានជំរុញមន្ត្រីផ្នែកប្រកួតប្រជែងបង្កើនកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីពង្រឹងបរិស្ថានប្រកួតប្រជែងរបស់អាស៊ាន ទោះបីជាមានការបញ្ចប់នូវឯកសារចំនួនពីរទាក់ទងនឹងការប្រកួតប្រជែងក៏ដោយ
    - បានកោតសរសើរចំពោះការចាប់ផ្ដើមសម្ពោធ ASEAN Mentorship for Entrepreneurs Network (AMEN) និងការសិក្សាអំពីការចូលរួមរបស់សហគ្រាសមីក្រូ តូច និងមធ្យម (MSMEs) នៅក្នុងសេដ្ឋកិច្ចឌីជីតាល់
    - បានបញ្ជាក់អំពីសារៈសំខាន់ក្នុងការរក្សា ASEAN Centrality and Unity ក្នុងការកសាងតំបន់ដោយផ្អែកលើយន្តការដែលដឹកនាំដោយអាស៊ាន ដូចជា អាស៊ានបូក១ អាស៊ានបូក៣ វេទិកាតំបន់អាស៊ាន ជាដើម
    - បានកត់សម្គាល់ថា ការសិក្សាអំពីពាក្យស្នើសុំរបស់ Timor-Leste ចូលជាសមាជិកអាស៊ានកំពុងដំណើរការ។ ដូច្នេះ ថ្នាក់ដឹកនាំ ទន្ទឹងរង់ចាំលទ្ធផលនៃការចរចារបស់ក្រុមការងារ

ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន នៅក្នុងខែធ្នូ ឆ្នាំ២០១៧ និងបានជំរុញអង្គភាពផ្នែកអាស៊ានពាក់ព័ន្ធ បន្តរកសកម្មភាពកសាងសមត្ថភាពពាក់ព័ន្ធ សម្រាប់ការចូលរួមរបស់ Timor-Leste នៅក្នុងអាស៊ាន។

- កិច្ចប្រជុំភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយប្រចាំតំបន់ (RCEP) ឆ្នាំ២០១៧៖
  - ពាណិជ្ជកម្មសេវា៖ ការពិភាក្សាលើសេចក្តីព្រាងជំពូកសេវាពាណិជ្ជកម្ម មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ដោយកិច្ចប្រជុំបានពិភាក្សាលើសេចក្តីព្រាងមាត្រាទាំង៣៣ ដោយផ្តោតសំខាន់លើ មាត្រា ស្តីពីវិសាលភាពនៃជំពូកពាណិជ្ជកម្មសេវា និងមាត្រាដែលពាក់ព័ន្ធនឹងការធ្វើរូបមន្តទ្វេកញ្ចប់សន្យា (Dual Listing Approach)។ កិច្ចប្រជុំក៏បានពិភាក្សាលើបញ្ហាច្រកចូលទីផ្សារ ការផ្ទេរកញ្ចប់សន្យាទៅបញ្ជីអវិជ្ជមាន (Negative List) និងបម្លាស់ទីរូបវន្តបុគ្គល
  - ពាណិជ្ជកម្មទំនិញ៖ ក្រុមការងារបានយល់ព្រមទៅលើកិច្ចការជំហានបន្ទាប់ដែលត្រូវធ្វើដើម្បីដោះស្រាយវិធានការមិនមែនពន្ធគយ(NTMs) និងគោលការណ៍ស្តីពីវិធីដោះស្រាយការចរចាសំណើ និងផ្តល់តារាងពន្ធគយ។ ក្រុមការងារ នឹងធ្វើអាទិភាពក្នុងការសំអាតអត្ថបទដែលមាន ៤ មាត្រា ដែលបានកំណត់នៅក្នុង Key Element Papers។

### ២.៦.២. ដៃគូអាស៊ាន

#### ក. អាស៊ាន-ចិន

ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះរវាងអាស៊ាន និងចិន៖ កម្ពុជាទទួលបានការផ្តល់សច្ចាប័នពីរដ្ឋសភា និងព្រឹទ្ធសភា ហើយព្រះមហាក្សត្របានឡាយព្រះហស្តលេខាឱ្យប្រើប្រាស់ច្បាប់នេះរួចរាល់ហើយ។

#### ខ. អាស៊ាន-កូរ៉េ

ពិធីសារទី៣ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញរវាងអាស៊ាននិងកូរ៉េ៖ កម្ពុជាទទួលបានការផ្តល់សច្ចាប័នពីរដ្ឋសភា និងព្រឹទ្ធសភា ហើយព្រះមហាក្សត្របានឡាយព្រះហស្តលេខាឱ្យប្រើប្រាស់ច្បាប់នេះរួចរាល់ហើយ។

#### គ. អាស៊ាន-ជប៉ុន

ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន និងជប៉ុន៖ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងជប៉ុន បានឯកភាពនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ហើយគ្រោងចុះហត្ថលេខានៅដើមឆ្នាំ២០១៨។

#### ឃ. អាស៊ាន-រុស្ស៊ី

- អនុស្សារណៈយោគយល់គ្នារវាងអាស៊ាន និង គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (Eurasian Economic Commission-EEC) ត្រូវបានបញ្ចប់ នឹងគ្រោងចុះហត្ថលេខានាពេលខ្លីខាងមុខ
- ការសិក្សាលទ្ធភាព (Feasibility Study) ចរចាពាណិជ្ជកម្មសេរីរវាងអាស៊ាន និងEurasian Economic Union-EAEU ៖ ភាគីទាំងពីរកំពុងផ្លាស់ប្តូរព័ត៌មាន និងស្វែងយល់អំពីនីតិវិធីផ្ទៃក្នុង។

### ខ. អាស៊ាន-ហុងកុង

បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង និងកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ហុងកុង នាកិច្ចប្រជុំកំពូលអាស៊ាន នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧។

### ច. អាស៊ាន-អឺរ៉ុប

- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មអឺរ៉ុប បានប្រកាសបើកការចរចាពាណិជ្ជកម្មសេរីតំបន់ និងតំបន់ នាកិច្ចប្រជុំរដ្ឋមន្ត្រីចង្អៀតសេដ្ឋកិច្ចអាស៊ាននាថ្ងៃទី៨-១០ ខែមីនា ឆ្នាំ២០១៧
- ក្រុមការងារចរចាអាស៊ាន-អឺរ៉ុប បានកំពុងពិភាក្សាលើការបង្កើតក្របខ័ណ្ឌសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អឺរ៉ុប

### ឆ. អាស៊ាន-កាណាដា

- បានបញ្ចប់របាយការណ៍បឋមស្តីអំពីការសិក្សារួម (Joint Feasibility Study) សម្រាប់ពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា ហើយភាគីទាំងពីរនឹងបញ្ចូលយោបល់ ស៊ីជម្រៅបន្ថែមទៀតដើម្បីឱ្យស្របទៅតាមលក្ខខណ្ឌប្រតិបត្តិ (ToR)។

## ២.៦.៣. ការងារអនុតំបន់

- កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម-ថៃ (CLMVT) ៖ បាន និងកំពុងរៀបចំប្រធានបទនៃកិច្ចប្រជុំ (Theme) និងសេចក្តីព្រាងបង្កើតគណៈកម្មការ និងអនុគណៈកម្មការ ត្រៀមធ្វើម្ចាស់ផ្ទះរៀបចំ CLMVT Forum នៅដើមឆ្នាំ២០១៨
- ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ៖ កិច្ចប្រជុំក្រុមការងារស្តីពីការតភ្ជាប់សេដ្ឋកិច្ច កម្ពុជា-ឡាវ-វៀតណាម (CLV)៖ ក្រុមការងារបានពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពស្តីពីការតភ្ជាប់សេដ្ឋកិច្ច កម្ពុជា-ឡាវ-វៀតណាម បានបញ្ចប់៥០%ហើយ។ ចំណែក ៥០% ទៀតនឹងបញ្ចប់នៅកិច្ចប្រជុំគណៈកម្មការសម្របសម្រួលចម្រុះលើកទី ១១ នៅខែធ្នូ ឆ្នាំ២០១៧។

## ២.៦.៤. ការងារទ្វេភាគី

- សាធារណរដ្ឋប្រជាមានិតចិន ៖ បានចុះអនុស្សារណៈយោគយល់គ្នា ស្តីពី ពាណិជ្ជកម្មអេឡិចត្រូនិក នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧។
- ថៃ៖ បានរៀបចំប្រជុំពាណិជ្ជកម្មចម្រុះថ្នាក់ឧត្តមមន្ត្រី នាថ្ងៃទី១៣-១៤ ខែមីនា ឆ្នាំ២០១៧ ដោយបានពិភាក្សាលើយុទ្ធសាស្ត្រកំណើននៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៅតាមបណ្តាខេត្តជាប់ព្រំដែន (Growth Strategy of Border Provinces′ Economic Cooperation) និងអនុស្សារណៈយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការជំរុញពាណិជ្ជកម្ម
- បង់ក្លាដេស៖ អនុស្សារណៈយោគយល់គ្នាស្តីពីពាណិជ្ជកម្មអង្ករ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៧។

## ២.៧. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក

## ២.៧.១. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយអឺរ៉ុប

- ក្នុងអំឡុងពេលកិច្ចប្រជុំលើកទី១ នៃក្រុមការងាររួមស្តីពី កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ភាគីទាំងពីរបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមស្តីពីទំនាក់ទំនង

សេដ្ឋកិច្ច និងពាណិជ្ជកម្ម កម្ពុជា និងសមាជិកនៃសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី អំពីពាណិជ្ជកម្ម និងការវិនិយោគ អនាម័យ ភូតគាមអនាម័យ និងវិធានការបសុពេទ្យ បទដ្ឋានគតិយុត្តបច្ចេកទេស បទដ្ឋានគតិយុត្តគយ វិស័យកម្មសិទ្ធិបញ្ញា និងកិច្ចសម្រួលពាណិជ្ជកម្ម ការលើកទឹកចិត្តឲ្យមានការវិនិយោគដោយផ្ទាល់ និងការធ្វើសកម្មភាពពាណិជ្ជកម្មផ្សេងៗ និងការរៀបចំកិច្ចប្រជុំលើកទី២ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងម៉ូស្គូ នៃសហព័ន្ធរុស្ស៊ី

- ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មបានទទួលជួប ឯកឧត្តម Valeriu Arteni ភារៈធារីនៃស្ថានទូតរ៉ូម៉ានីប្រចាំកម្ពុជាមាននិវេសនដ្ឋាននៅទីក្រុងហាណូយ ពិភាក្សាដើម្បីជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ រវាងកម្ពុជា និងរ៉ូម៉ានី
- ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មបានទទួលជួប ឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំនៅកម្ពុជា ដោយផ្តោតសំខាន់លើការជំរុញឲ្យមានជំនួបពិភាក្សាវេទិកាវិស័យឯកជនរវាងប្រទេសទាំងពីរ ជំរុញការនាំចូលផលិតផលកសិកម្មពីកម្ពុជារួមមាន៖ អង្ករ កៅស៊ូ និងស្វាគមន៍អ្នកវិនិយោគិនរុស្ស៊ីមកកម្ពុជា និងបង្កើតក្រុមការងារចរចា (Working Group)។ ក្រសួងពាណិជ្ជកម្ម បានជូនដំណឹងទៅស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា ដើម្បីរំលឹក និងជំរុញការអនុវត្តការអនុគ្រោះពន្ធលើទំនិញកម្ពុជាប្រមាណជិត៣០០០មុខ ចូលទៅកាន់ទីផ្សាររុស្ស៊ីដោយមិនជាប់ពន្ធ និងកូតា។ បានពិភាក្សាជាមួយ ឯកឧត្តម Dmitry Tsvetkov អំពីសំណើសិក្សារួមនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) និងអាស៊ាន (ASEAN) និងពាណិជ្ជកម្មសេរី កម្ពុជា-EAEU
- ក្រសួងពាណិជ្ជកម្ម បានបញ្ជូនបញ្ជីវិស័យអាទិភាពខ្ពស់ និងគម្រោងរួមគ្នា សម្រាប់កិច្ចសហប្រតិបត្តិការជាមួយ EAEU និងបញ្ជីស្តីពីបញ្ហានានាពាក់ព័ន្ធនឹងការនាំចេញទំនិញកម្ពុជា ទៅសហភាព សេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU)
- ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មបានទទួលជួប ឯកឧត្តម Beketzhan Zhumakhanov ឯកអគ្គរដ្ឋទូតកាហ្សាក់ស្ថានប្រចាំកម្ពុជា ដោយផ្តោតលើការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ
- ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មបានទទួលជួប លោកបណ្ឌិត Sergey PRONIN នាយកប្រតិបត្តិក្រុមហ៊ុន RSTradehouse នៃសហព័ន្ធរុស្ស៊ី ដើម្បីត្រៀមលក្ខណៈរៀបចំវេទិកាធុរកិច្ចរវាងកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី(EAEU) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ទន្ទឹមនឹងនេះដែរ ក្រសួងបានត្រៀមលក្ខណៈស្ទើរតែរួចរាល់ហើយ
- នៅថ្ងៃទី២៩-៣០ខែមិថុនា ឆ្នាំ២០១៧ បានប្រជុំលើកទី២ នៃគណៈកម្មាធិការចម្រុះ ស្តីពីកិច្ច សហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច រវាងកម្ពុជា និងបេឡារុស នៅទីក្រុងមីនស្គ និងបានចុះហត្ថលេខាលើកំណត់ហេតុរួម ដែលមានខ្លឹមសារសំខាន់ៗ ដូចជាការជំរុញពាណិជ្ជកម្មទ្វេភាគី ជំរុញឲ្យទិញផលិតផលកសិកម្មពីកម្ពុជា ពង្រឹងវិស័យអនាម័យ និងភូតគាមអនាម័យ ជំរុញ និងពង្រីកការវិនិយោគ ការផ្លាស់ប្តូរព័ត៌មានទេសចរណ៍ និងវប្បធម៌ និងវេទិកាធុរកិច្ច
- នៅថ្ងៃទី២៣-២៤ ខែសីហា ឆ្នាំ២០១៧ បានចូលរួមកិច្ចប្រជុំលើកទី១០ នៃគណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ីស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស នៅសហព័ន្ធរុស្ស៊ី ដោយបានឯកភាពជំរុញរៀបចំបញ្ជីសំណើលម្អិតនៃគម្រោងវិនិយោគរួមសម្រាប់កិច្ចសហប្រតិបត្តិការកម្ពុជា-រុស្ស៊ី លើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិនិយោគដល់ឆ្នាំ២០២០ និងកម្ពុជាក៏បានស្នើសុំឲ្យភាគីរុស្ស៊ី ពិនិត្យលទ្ធភាពរៀបចំកិច្ចប្រជុំលើកទី២ នៃក្រុមការងារជាន់ខ្ពស់ ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងកម្ពុជា និងរុស្ស៊ី

- ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មបានទទួលជួបឯកឧត្តម EVGUENI STEFANOV STOYTCHEV ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប៊ុលហ្គារីប្រចាំកម្ពុជា ដែលមាននិវេសនដ្ឋាន នៅទីក្រុងហាណូយ ដោយបានបញ្ចប់សេចក្តីព្រាង នៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស រវាងកម្ពុជា និងប៊ុលហ្គារី និងគ្រោងចុះហត្ថលេខានៅពេលសមស្របខាងមុខ
- ថ្ងៃទី១៧-១៩ ខែតុលា ឆ្នាំ២០១៧ បានសហការរៀបចំជាមួយ អង្គការអន្តរជាតិនៃប្រទេសនិយាយភាសាបារាំង(OIF) ស្តីអំពីការប្រឹក្សាយោបល់ថ្នាក់តំបន់ (អាស៊ី កាពាប៉ៀន និងប៉ាស៊ីហ្វិក) ដើម្បីត្រៀមចូលរួមសន្និសីទលើកទី១១ ថ្នាក់រដ្ឋមន្ត្រីរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO) នៅខេត្តសៀមរាប ដោយកិច្ចប្រជុំនេះសង្កត់ធ្ងន់ និងទទួលបានលទ្ធផលសំខាន់ៗ ដូចជាការជំរុញឲ្យប្រទេសអភិវឌ្ឍន៍ អនុវត្តការបើកច្រកទីផ្សារសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួចដោយមិនជាប់ពន្ធ និងកូតា (DFQF) ខ្សែសង្វាក់តម្លៃនៃផលិតផលកប្បាស និងការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម (TFA)
- ក្រសួងបានសហការសិក្សាស្រាវជ្រាវជាមួយ Economic Research Institute for ASEAN and East Asia (ERIA) អំពីអត្ថប្រយោជន៍ និងផលប៉ះពាល់នៃការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រវាងកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) ដែលការសិក្សាស្រាវជ្រាវនេះស្ទើរតែចប់សព្វគ្រប់ហើយ។

## ២.៧.២. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយមជ្ឈឹមបូព៌ា

- បានទំនាក់ទំនងជាមួយប្រទេសកាតា ដើម្បីឈានទៅដល់ការពិនិត្យ សេចក្តីព្រាងចុងក្រោយនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកទេសសម្រាប់ត្រៀមចុះហត្ថលេខានៅពេលសមស្របណាមួយ
- បានទំនាក់ទំនងជាមួយស្ថានទូតសាធារណរដ្ឋតួកគីប្រចាំនៅកម្ពុជា ស្តីពីការរៀបចំកិច្ចប្រជុំលើកទី២ នៃគណៈកម្មការសេដ្ឋកិច្ចចម្រុះ រវាងកម្ពុជា និងតួកគី ដែលគ្រោងនឹងប្រព្រឹត្តទៅនៅតួកគីនៅពេលខាងមុខ
- បានទំនាក់ទំនងជាមួយស្ថានទូតរដ្ឋគូវ៉ែតប្រចាំកម្ពុជានៅភ្នំពេញ ស្តីពីលទ្ធភាពនៃការរៀបចំកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការពាណិជ្ជកម្មចម្រុះ រវាងកម្ពុជា និងរដ្ឋគូវ៉ែត នៅរដ្ឋគូវ៉ែត ដែលអាចនឹងធ្វើឡើងនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៨។

## ២.៧.៣. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយអាហ្វ្រិក

- ថ្នាក់ដឹកនាំក្រសួង បានជួបប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូមកពីបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក រួមមាន៖ អាហ្វ្រិកខាងត្បូង កូម៉ូរុស អេត្យូពី និងកូឌីវ័រ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានជួបពិភាក្សាការងារជាមួយ លោក Kamalidini SOUEF តំណាងក្រសួងហិរញ្ញវត្ថុ និងថវិកា នៃសហភាពកូម៉ូរុស។ កូម៉ូរុសបានបង្ហាញចំណាប់អារម្មណ៍ចង់ទិញអង្ករ និងសំលៀកបំពាក់ពីកម្ពុជា។

## ២.៧.៤. ពាណិជ្ជកម្មស្រូវ-អង្ករ

- សហភាពអឺរ៉ុប (EU) បានបង្ហាញអំពីការចេញបទប្បញ្ញត្តិថ្មីពាក់ព័ន្ធនឹង ការកម្រិតកំណត់ការប្រើប្រាស់ កាកសំណល់សារធាតុគីមីសកម្ម Tricyclazole ទៅ 0.0១មីលីក្រាម។ ក្រសួងពាណិជ្ជកម្ម បាន

អញ្ជើញក្រសួងកសិកម្ម សហព័ន្ធស្រូវ-អង្ករកម្ពុជា សហគមន៍កសិកម្ម ក្រុមហ៊ុនផ្គត់ផ្គង់សារធាតុគីមីសកម្មសម្រាប់ដំណាំកសិកម្ម តំណាងរោងចក្រម៉ាស៊ីនកិនស្រូវ អ្នកផលិតនាំចេញស្រូវ-អង្ករកម្ពុជា និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ បង្ហាញអំពីបទប្បញ្ញត្តិថ្មីនេះ ឱ្យយល់ដឹងអំពីការហាមឃាត់ និងការដាក់កំរិតសារធាតុគីមីសកម្ម Tricyclazole និងដើម្បីត្រៀមរៀបចំវិធានការទុកជាមុនទៅនឹងការហាមឃាត់នេះ

- សហព័ន្ធស្រូវអង្ករ និងស្ថាប័នដើម្បីជួយផ្សព្វផ្សាយ និងពន្យល់ឱ្យសមាជិកសហព័ន្ធស្រូវ-អង្ករកម្ពុជា សហគមន៍កសិកម្ម ក្រុមហ៊ុនផ្គត់ផ្គង់សារធាតុគីមីសកម្មសម្រាប់ដំណាំកសិកម្ម តំណាងរោងចក្រម៉ាស៊ីនកិនស្រូវ អ្នកផលិត-នាំចេញស្រូវ-អង្ករកម្ពុជា និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យយល់ដឹងអំពីការហាមឃាត់ និងការដាក់កំរិតសារធាតុគីមីសកម្ម Tricyclazole ដែលមាននៅក្នុងអង្ករកម្ពុជា និងដើម្បីរៀបចំវិធានការទុកជាមុន ទាក់ទងនឹងការហាមឃាត់ និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមីសកម្ម Tricyclazole នេះ
- ថ្នាក់ដឹកនាំក្រសួងបានជួបពិភាក្សាជាមួយ គណៈប្រតិភូនៃសហភាពអឺរ៉ុប ដែលដឹកនាំដោយលោក Nikolaos Zaimis ទទួលបន្ទុកការងារពាណិជ្ជកម្មសហភាពអឺរ៉ុប(EU) ដើម្បីពិគ្រោះយោបល់ជាលើកទី៤ ស្តីពីពាណិជ្ជកម្មអង្ករទៅកាន់ទីផ្សារសហភាពអឺរ៉ុប៖ ១). ពិនិត្យអំពីស្ថានភាពការនាំចេញប្រភេទអង្ករ និង ២). EU បានបង្ហាញអំពីតួលេខការនាំចូលអង្ករស្ថិតក្រោមប្រព័ន្ធអនុគ្រោះពន្ធ (EBA) សរុបចំនួន ១,២៥ លានតោន (តួលេខពីខែកញ្ញា ឆ្នាំ២០១៦ដល់ខែសីហា ឆ្នាំ២០១៧) ដែលក្នុងនោះតួលេខនាំចូលពីកម្ពុជាស្មើនឹង ៤៥%។

## ២.៨. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាមេរិក

- បានចូលរួមកិច្ចប្រជុំស្តីពីកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគ និងពាណិជ្ជកម្មលើកទី៤ (TIFA) ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៧ នៅវ៉ាស៊ីនតោន ឌី.ស៊ី សហរដ្ឋអាមេរិក។ ជាលទ្ធផល ភាគីទាំងពីរបានឯកភាពបង្កើតក្រុមការងារ ដើម្បីពិភាក្សាបន្តលើវិស័យចំនួន៥៖ ១). កម្មសិទ្ធិបញ្ញា ២). ជំនួយបច្ចេកទេសទាក់ទងនឹងការកសាងច្បាប់ ការអនុវត្តកិច្ចព្រមព្រៀង សម្រួលពាណិជ្ជកម្មក្រោមក្របខ័ណ្ឌ WTO ការរៀបចំខ្លួនសម្រាប់ពិចារណាចូលរួមក្នុងកិច្ចព្រមព្រៀងបច្ចេកវិទ្យាព័ត៌មានអនាម័យ និងភូតគាមអនាម័យ នៃវិស័យកសិកម្ម ជំនួយកសាងធនធានមនុស្សផ្នែកសុវត្ថិភាពចំណីអាហារ ការកសាងសមត្ថភាពអនុវត្តន៍ច្បាប់ឧបាស្រ័យពាណិជ្ជកម្ម និងច្បាប់ប្រកួតប្រជែង និងការកសាងសមត្ថភាពក្នុងការអនុវត្តច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៣). សេវាបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ៤). វិស័យការងារ និង ៥). វិស័យពាណិជ្ជកម្ម។ ភាគីទាំងពីរបានឯកភាពថា ប្រជុំក្រុមការងារត្រូវជួបគ្នា២ដងក្នុងមួយឆ្នាំ ដើម្បីដោះស្រាយបញ្ហានានាក្នុងគោលបំណងពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី
- បានដាក់ញត្តិតវ៉ា លើផលិតផលសំលៀកបំពាក់ វាយនភណ្ឌ និងស្បែកជើង ទៅកាន់ស្ថានតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក (USTR) សម្រាប់ការពិនិត្យឡើងវិញនូវប្រពន្ធ័អនុគ្រោះពន្ធទូទៅប្រចាំឆ្នាំ២០១៧ របស់សហរដ្ឋអាមេរិក (GSP Review Program 2017)
- បានបញ្ជូនក្រុមហ៊ុនចំនួន០៣ ចូលរួមសន្និសីទពាណិជ្ជកម្មស្តេតឈីវ័ន់-អាស៊ី ទីក្រុងRegina ខេត្តសាស្តេតឈីវ័ន់ កាណាដា ហើយមានពាណិជ្ជករនៅកាណាដា មានចំណាប់អារម្មណ៍ចំពោះផលិតផលម្រេច និងសំបុកត្រចៀកកាំរបស់កម្ពុជា
- សហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) ក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មអង្គការពាណិជ្ជកម្មពិភពលោក" និងបង្ហាញពី

លទ្ធផលស្រាវជ្រាវៈ ១). ស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ២). ឥទ្ធិពលនានា ដែលអាចកើតឡើងពីការអនុវត្តកិច្ចព្រមព្រៀង TFA នេះ ៣). ចំណុចអាទិភាពដែលគួរត្រូវបានកែទម្រង់ ដើម្បីអនុវត្ត និងអនុលោមតាមកិច្ចព្រមព្រៀងមួយនេះ ៤). ការវិភាគលម្អិតលើមាត្រានីមួយៗនៃកិច្ចព្រមព្រៀង និង៥). កាលានុវត្តភាពនៃការបង្កើតគណៈកម្មាធិការជាតិសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម

- បានរៀបចំការប្រជុំពិភាក្សា ជាមួយគណៈប្រតិភូរបស់ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន ដើម្បីស្វែងយល់ពីសក្តានុពលធ្វើពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា ដែលមានក្រុមហ៊ុនធំៗចំនួន១៤ របស់សហរដ្ឋអាមេរិក ដែលមានដើមទុនសរុបជាង ពីរប៊ីលានដុល្លារ។

## ២.៩. ការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក

- បានចូលរួមកិច្ចប្រជុំតុមូលចិនលើកទី៦ និងវេទិកាថ្នាក់រដ្ឋមន្ត្រីលើកទី១១ នៅថ្ងៃទី០៩ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ នៅទីក្រុងប៊ូណូសអៃរេស ប្រទេសអាហ្សង់ទីន ដើម្បីបន្តចរចាលើបញ្ហាដែលនៅសេសសល់ពីកិច្ចប្រជុំលើកទី១០ ដូចជាៈ បញ្ហាកសិកម្ម (កប្បាស) ការឧបត្ថម្ភធនជលផល ការលើកលែងពន្ធ និងមិនកំណត់ចំនួនកូតា ប្រព្រឹត្តិកម្មពិសេស និងបញ្ហាថ្មីគឺការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានរៀបចំកិច្ចប្រជុំ ការត្រួតពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ទទួលបានជោគជ័យ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅថ្ងៃទី២១ និង ២៣ ខែវិច្ឆិកា ឆ្នាំ២០១៧។ ការធ្វើការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មគឺ ដើម្បីបង្កើនតម្លាភាព និងការយល់ដឹងអំពីគោលនយោបាយ និងការអនុវត្តគោលនយោបាយពាណិជ្ជកម្មរបស់កម្ពុជាតាមរយៈការត្រួតពិនិត្យជាទៀងទាត់តាមកាលវិភាគ និងដើម្បីបើកការវាយតម្លៃពហុភាគីអំពីឥទ្ធិពលនៃគោលនយោបាយលើប្រព័ន្ធពាណិជ្ជកម្មពិភពលោក
- បានរៀបចំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការធ្វើចំណាត់ថ្នាក់វិធានការនៃកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម (TFA) និងបានធ្វើសេចក្តីជូនដំណឹងស្តីពីការធ្វើចំណាត់ថ្នាក់វិធានការកិច្ចព្រមព្រៀង TFA របស់កម្ពុជា ដោយអង្គការ WTO បានធ្វើការផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧
- បានធ្វើបច្ចុប្បន្នភាព លើតារាងកម្មវិធីរបស់រាជរដ្ឋាភិបាលក្រោមក្របខ័ណ្ឌអង្គការ WTO Work program ដែលមានសកម្មភាព បញ្ញត្តិ និងច្បាប់សរុបចំនួន ៨៣
- បានរៀបចំកិច្ចប្រជុំតុមូលចិនលើកទី៥ (The 5th China Round Table) នៅថ្ងៃទី ២០ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅទីក្រុងសៀមរាប។ កិច្ចប្រជុំនេះបានទទួលការឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសចិន និងអនុវត្តន៍ ដោយអង្គការ WTO ក្នុងនេះមានការចូលរួមពីថ្នាក់រដ្ឋមន្ត្រី នៃប្រទេសអភិវឌ្ឍន៍តិចតួចដែលជាសមាជិកអង្គការ WTO និងអង្គការអន្តរជាតិមួយចំនួនសរុបអ្នកចូលរួមប្រមាណ៩០នាក់។ លទ្ធផលនៃកិច្ចប្រជុំនេះ គឺដើម្បីផ្តល់ជាវេទិកាសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ដែលជាសមាជិក WTO និងប្រទេសអភិវឌ្ឍន៍តិចតួច ដែលកំពុងស្នើចូលជាសមាជិកអង្គការ WTO ក្នុងការចែករំលែកបទពិសោធន៍នានាពាក់ព័ន្ធដល់ការចូលជាសមាជិក
- បានសហការរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានឆ្នាំ២០១៧ នៅថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧។ លទ្ធផលនៃកិច្ចប្រជុំនេះគឺ ដើម្បីពង្រឹងវិស័យអប់រំភាពជាសហគ្រិន ប្រព័ន្ធបច្ចេកវិទ្យាក្នុងការធ្វើពាណិជ្ជកម្ម។ វេទិកានេះ ជាវេទិកាអង្គការអន្តរជាតិមួយសម្រាប់កិច្ចសហប្រតិបត្តិការសាធារណៈ និងឯកជន។ កិច្ចប្រជុំនេះនឹងក្លាយជាវេទិកាដ៏ល្អសម្រាប់អ្នកជំនួញពីវិស័យនានា ដើម្បីចាប់ដៃគូក្នុងការធ្វើវិនិយោគ

- ព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើស ជាប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ក្រោមក្របខ័ណ្ឌអង្គការ WTO កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧។ ក្រសួងបានធ្វើការផ្សព្វផ្សាយដល់សាធារណៈជន អំពីសារៈសំខាន់ក្នុងការទទួលយកតួនាទីនេះ ដើម្បីជួយប្រទេសអភិវឌ្ឍន៍តិចតួចក្នុងការចរចានានាដូចជា ការមិនជាប់ពន្ធ និងមិនជាប់កូតា (DFQF) ការផ្តល់នូវការអនុគ្រោះពន្ធ (GSP) ប្រព្រឹត្តិកម្មពិសេស (S&DT)។

## ២.១០. ការងារសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ

### ២.១០.១. ការងាររបស់កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញរបស់កម្ពុជាជំហានទី២ (ផ្នែកតាមដាន និងវាយតម្លៃ)

- បានវាយតម្លៃបញ្ចប់គម្រោងសមាសភាគពីរគឺ (១) សមាសភាគជលផលសមុទ្រ អនុវត្តដោយអង្គការ UNIDO និង (២) សមាសភាគជំឡូងមី អនុវត្តដោយអង្គការ UNDP។ ជាលទ្ធផលបានបង្ហាញថា ការអនុវត្តមានការពេញចិត្ត
- ដោយឡែក សមាសភាគពីរទៀតគឺ (១) សមាភាគសាលាបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើម្ហូបអាហារ អនុវត្តដោយអង្គការ Shift 360 និង (២) សមាសភាគត្រួតពិនិត្យ និងវាយតម្លៃ អនុវត្តដោយលេខាធិការដ្ឋានជំនួយសម្រាប់ពាណិជ្ជកម្ម បន្តដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៨។

### ២.១០.២. គម្រោងគាំទ្រនិរន្តរភាព

- បាន និងកំពុងអនុវត្តគម្រោងគាំទ្រនិរន្តរភាព គឺជាគម្រោងក្រោមជំនួយឥតសំណងរបស់ EIF ដែលមានទឹកប្រាក់ ២៣៥.៤៥០ ដុល្លារអាមេរិក សម្រាប់រយៈពេល ០២ ឆ្នាំ ពីឆ្នាំ២០១៧ ដល់ ២០១៨ ហើយបាន និងកំពុងអនុវត្តបន្តក្រោមផែនការសកម្មភាពរបស់គម្រោងរួមមាន៖
  - គាំទ្រការពង្រឹងសមត្ថភាពមន្ត្រីលេខាធិការដ្ឋានជំនួយសម្រាប់ពាណិជ្ជកម្ម ដើម្បីដើរតួជាភ្នាក់ងារអនុវត្តគម្រោងថ្នាក់ជាតិ ឲ្យមានប្រសិទ្ធភាព និងដំណើរការពេញលេញ
  - ពង្រឹងការចូលរួមមន្ត្រីលេខាធិការដ្ឋានជំនួយសម្រាប់ពាណិជ្ជកម្ម និងភាគីពាក់ព័ន្ធក្នុងការអនុវត្ត រៀបចំ និងសម្របសម្រួលជំនួយសម្រាប់ពាណិជ្ជកម្ម
  - ពង្រឹងសមត្ថភាពមន្ត្រីលេខាធិការដ្ឋានជំនួយសម្រាប់ពាណិជ្ជកម្ម និងពង្រីកការយល់ដឹង អំពីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម គោលនយោបាយពាណិជ្ជកម្ម និងការរៀបចំសម្របសម្រួល និងគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្ម
  - គាំទ្រដល់ការផ្តល់ជាធាតុចូលរបស់ក្រសួងពាណិជ្ជកម្ម ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិលើកទី៥ តាមរយៈការប្រឹក្សាជាមួយក្រសួងពាក់ព័ន្ធ
  - គាំទ្រដល់សកម្មភាពការងាររបស់សហព័ន្ធស្រូវអង្ករកម្ពុជា (CRF)
  - គាំទ្រដល់សកម្មភាពការងាររបស់គណៈកម្មាធិការអភិវឌ្ឍន៍សូត្រ (SDC)
  - គាំទ្រដល់ការសិក្សាអំពីការត្រៀមខ្លួនរបស់កម្ពុជា ក្នុងការអភិវឌ្ឍចេញពីប្រទេសមានការអភិវឌ្ឍតិចតួច។

### ២.១០.៣. ការងារគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច

- បាន និងកំពុងអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ជាប្រាក់កម្ចីចំនួន ៣៦,៣ លានដុល្លារអាមេរិកពីអង្គការមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម(IFAD) ដែលនៅឆ្នាំដំបូងសម្រាប់ការចាប់ផ្តើមអនុវត្តគម្រោង ដូចជា៖

- ការរៀបចំស្ថាប័ន និងអង្គភាពអនុវត្តន៍គម្រោង៖ គណៈកម្មការគ្រប់គ្រងគម្រោង អង្គភាពគ្រប់គ្រងគម្រោង អង្គភាពអនុវត្តន៍គម្រោង ការិយាល័យមណ្ឌលភូមិភាគ គណៈកម្មការលទ្ធកម្ម ត្រូវបានបង្កើតឡើងដើម្បីអនុវត្តគម្រោង។ ក្រៅពីនេះលេខាធិការដ្ឋានជំនួយសម្រាប់ពាណិជ្ជកម្ម ក៏បានរៀបចំជាស្ថាពរនូវផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តគម្រោងឆ្នាំ២០១៧ និងបានរៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ និងគ្រោងរៀបចំកិច្ចប្រជុំសម្រាប់ត្រួតពិនិត្យលើផែនការសកម្មភាព និងបូកសរុបថវិការួមឲ្យបានរួចរាល់នៅក្នុងអំឡុងខែធ្នូ ឆ្នាំ២០១៧ រួចផ្ញើផែនការសកម្មភាព និងថវិកានោះទៅអង្គការ IFAD និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត
- ការរៀបចំឯកសារណែនាំពីគម្រោង៖ សៀវភៅណែនាំពីការអនុវត្តគម្រោង និងគោលការណ៍ណែនាំឥណទានអភិវឌ្ឍន៍វិស័យ (SDF) និងឥណទាននវានុវត្តន៍ខ្សែសង្វាក់តម្លៃ (VCIF) បានរៀបចំដើម្បីបង្កើតជានីតិវិធី ក្នុងការផ្តល់ឥណទានលើការវិនិយោគណាមួយក្រោមក្របខ័ណ្ឌគម្រោង
- ការធ្វើលទ្ធកម្មទំនិញ និងទីប្រឹក្សា៖ ការធ្វើលទ្ធកម្មទំនិញ និងទីប្រឹក្សានឹងផ្តល់នូវឧបករណ៍គ្រឿងបរិក្ខារ និងមូលដ្ឋានចំណេះដឹងគ្រប់គ្រាន់ដល់ភ្នាក់ងារអនុវត្តគម្រោងទាំងថ្នាក់កណ្តាល និងថ្នាក់មណ្ឌលភូមិភាគ ក្នុងការអនុវត្តគម្រោងឲ្យសម្រេចបានតាមលទ្ធផលរំពឹងទុក។

## ២.១១ ការងារត្រួតពិនិត្យ បង្ក្រាបការក្លែងបន្លំ និងការពារអ្នកប្រើប្រាស់

ក្នុងគោលបំណងរួមចំណែកអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ ក្រសួងពាណិជ្ជកម្ម ដែលមានអគ្គនាយកដ្ឋានកាំកុងត្រូលជាសេនាធិការ បានខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពផលិតផល ពិសេសចំណីអាហារ តាមរយៈការត្រួតពិនិត្យទំនិញនាំចូល-នាំចេញ នៅតាមគ្រប់ច្រកព្រំដែន និងឃ្លាំពិនិត្យទីផ្សារក្នុងស្រុក ដើម្បីទប់ស្កាត់នូវការនាំចូល-នាំចេញ និងការចរាចរទំនិញពុំសមស្របតាមបញ្ញត្តិបច្ចេកទេស ពាក់ព័ន្ធនឹងគុណភាពសុវត្ថិភាពផលិតផល និងគោលនយោបាយពាណិជ្ជកម្ម។ ក្នុងឆ្នាំ២០១៧ អគ្គនាយកដ្ឋានកាំកុងត្រូលបានអនុវត្តតួនាទី និងភារកិច្ច ដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

### ២.១១.១. លទ្ធផលពីការប្រមូលចំណូលសោហ៊ុយត្រួតពិនិត្យ

ក្នុងឆ្នាំ២០១៧ អគ្គនាយកដ្ឋានកាំកុងត្រូល បានប្រមូលចំណូលពីកម្រៃសេវាត្រួតពិនិត្យ និងវិភាគគុណភាពទំនិញបាន ១០៨.៣៥២.០០០.០០០រៀល បើប្រៀបធៀបជាមួយប្រាក់ចំណូលក្នុងឆ្នាំ២០១៦ មានការកើនឡើងចំនួន ៧.៩២៩.៩៧៤.៩០១រៀល ស្មើនឹង៧.៩០%។ ប្រៀបធៀបជាមួយផែនការចំណូលរដ្ឋឆ្នាំ២០១៧ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ចំនួន ៩២.០០០.០០០.០០០រៀល (កៅសិបពីរពាន់ លានរៀលគត់) អគ្គនាយកដ្ឋានអនុវត្តបានលើសផែនការចំនួន ១៦.៣៥២.០០០.០០០រៀល ស្មើ១៧.៧៧% ។

### ២.១១.២. លទ្ធផលពីការងារត្រួតពិនិត្យការនាំចូល-នាំចេញ តាមច្រកព្រំដែន

- រថយន្តពិសោធន៍ចល័តផ្នែកម្ហូបអាហារ បានចុះទៅតាមច្រកទ្វារព្រំដែននៃបណ្តាខេត្ត ដោយបានត្រួតពិនិត្យ និងវិភាគទៅលើផលិតផល (បន្លែ សាច់ គ្រឿងសមុទ្រស្រស់) ចំនួន ៥៤០ គំរូ និងរកឃើញផលិតផល ៣៦ គំរូ មានសំណល់ថ្នាំកសិកម្ម ឬសារធាតុគីមីហាមឃាត់

- បានរកឃើញ និងកម្ទេចចោល នូវផលិតផលម្ហូបអាហារខូចគុណភាពនាំចូលនៅតាមបណ្ដាច្រកព្រំដែនចំនួន ៥៨.២៦៦គីឡូក្រាម
- សហការទប់ស្កាត់ការធ្វើចរាចរសារធាតុញៀនបាន ០១ ករណី នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យចំនួន ០១ នាក់ និងរឹបអូសសារធាតុញៀនប្រភេទកូកាអ៊ីនចំនួន ២.៤៥១,២៤ ក្រាម (ពីរពាន់ បួនរយហាសិបមួយក្រាមក្បៀសម្ភៃបួន) ដើម្បីចាត់ចែងតាមនីតិវិធី។

## ២.១១.៣. លទ្ធផលពីការខារឃ្លាំពិនិត្យទីផ្សារ

- រថយន្តពិសោធន៍ចល័តផ្នែកម្ហូបអាហារ បានចុះត្រួតពិនិត្យ និងវិភាគទៅលើផលិតផល (បន្លែ សាច់ គ្រឿងសមុទ្រស្រស់) នៅតាមបណ្ដាផ្សារក្នុងរាជធានី ខេត្ត បានចំនួន ៣.០៧៥ គំរូ និងរកឃើញផលិតផល ១៩៨ គំរូ មានសំណល់ថ្នាំកសិកម្ម ឬសារធាតុគីមីហាមឃាត់
- បានរកឃើញ និងរឹបអូសមកកម្ទេចចោលនូវផលិតផលម្ហូបអាហារខូចគុណភាព ចំនួន ២១.០៦៦ គីឡូក្រាម និងផលិតផលមិនមែនម្ហូបអាហារចំនួន ១១៣ គីឡូក្រាម ពីទីផ្សារចំនួន១.៧១៨ ផ្សារ ដែលបានត្រួតពិនិត្យ។

## ២.១១.៤. ការខារដើម្បីប្រសិទ្ធភាពចំពោះកិច្ចការពារអ្នកប្រើប្រាស់

- បានតាមដាន ពិនិត្យ និងស្រាវជ្រាវ លើការផ្សាយពាណិជ្ជកម្មលក់ផលិតផលរបស់ក្រុមហ៊ុនដោយមានភ្ជាប់រង្វាន់ជូនអតិថិជន ដោយបានអញ្ជើញតំណាងក្រុមហ៊ុនចំនួន ១៦ ឱ្យមកបំភ្លឺអំពីខ្លឹមសារ និងផ្ដល់ការអះអាង អំពីការផ្ដល់រង្វាន់ គុណភាព និងប្រភពផលិត
- បានរៀបចំខ្លឹមសារជាអត្ថបទ៖ "សុវត្ថិភាព និងការសន្សំសំចៃម្ហូបអាហារ" សម្រាប់ការយល់ដឹងពីម្ហូបអាហារ បន្លែ ផ្លែឈើ ការជ្រើសរើសអាហារ សារធាតុបន្ថែមក្នុងអាហារ លេខកូដបញ្ជាក់ពីការដាំដុះសរីរាង្គ ឬតាមបែបធម្មតាជាដើម សម្រាប់ធ្វើការអប់រំ ផ្ដល់ការយល់ដឹងដល់សិស្ស និស្សិត អាជីវករ និងអ្នកប្រើប្រាស់
- បានចុះស្រាវជ្រាវករណីពុលអាហារ ដែលបានកើតឡើងនៅបណ្ដាខេត្តចំនួន ០៤លើក និងយកសំណាក រួមមានចំណីអាហារ និងភេសជ្ជៈ ដែលប្រជាពលរដ្ឋបានបរិភោគ មកវិភាគរកមូលហេតុបណ្ដាលឱ្យមានការពុល។

## ២.១១.៥. ការខារទប់ស្កាត់ការក្លែងបន្លំ

- បានចុះត្រួតពិនិត្យគុណភាពកម្រិតសន្ទស្សន៍អុកតាន (Octane) ប្រេងសាំង និងបរិមាណប្រេងឥន្ធនៈ ដែលលក់នៅតាមស្ថានីយ ចំនួន ១០២ (នៅរាជធានីភ្នំពេញចំនួន ៧៦ស្ថានីយ និងតាមបណ្ដាខេត្តចំនួន ២៦ស្ថានីយ) ដោយបានរកឃើញស្ថានីយ ៣៧ លក់ប្រេងសាំង ដែលមានកម្រិតសន្ទស្សន៍អុកតាន (Octane) ទាបជាងបទដ្ឋានកំណត់ និងមានស្ថានីយចំនួន ៤៧ បានលក់ប្រេងជូនអតិថិជន មានកម្រិតលំអៀងផ្នែករង្វាស់រង្វាល់ (ពី ០២លីត្រ ទៅ ០៨លីត្រ ក្នុងបរិមាណប្រេង ១០០លីត្រ)។ មន្ត្រីជំនាញបានតម្រូវឱ្យម្ចាស់ ស្ថានីយទាំង ៨៤ ធ្វើកិច្ចសន្យាដើម្បីធ្វើការកែតម្រូវ និងអនុវត្តនីតិវិធីបន្តក្នុងករណីមិនបានកែតម្រូវ
- បានស្នើសុំផ្អាកការផលិតជាបណ្ដោះអាសន្ន ចំពោះសិប្បកម្មផលិតសរសៃគុយទាវចំនួន ០៥កន្លែង ក្រោយពីមន្ត្រីកាំកុងត្រូលបានរកឃើញវត្ថុមានសារធាតុគីមីបូរ៉ាក់ក្នុងផលិតផលនោះ។ មន្ត្រីជំនាញ

បានឱ្យម្ចាស់សិប្បកម្ម ធ្វើកិច្ចសន្យា និងកែតម្រូវបញ្ឈប់ការប្រើប្រាស់សារធាតុគីមីហាមឃាត់ ក្នុងការផលិតបន្តទៀត បើពុំនោះទេ ម្ចាស់សិប្បកម្មនឹងត្រូវប្រឈមចំពោះមុខច្បាប់

- បានសហការចុះត្រួតពិនិត្យទីតាំងផលិត និងស្តុកទំនិញចំនួន ០៧កន្លែង (ខេត្តត្បូងឃ្មុំ ០១កន្លែង និងនៅរាជធានីភ្នំពេញ ០៦កន្លែង) ដោយបានរកឃើញ និងឃាត់ទុកបណ្តោះអាសន្ន នូវផលិតផលក្លែងស្លាកសញ្ញា (ស្រា ទឹកម្ទេស ទឹកសៀង និងធូបមូស...) មួយចំនួនមករក្សាទុក ដើម្បីអនុវត្តតាមនីតិវិធីបន្ត។

## ២.១១.៦. ការងារលើកកម្ពស់ការយល់ដឹងសាធារណៈ

- បានចុះអប់រំផ្សព្វផ្សាយអំពីគុណភាព សុវត្ថិភាពម្ហូបអាហារ ដល់អាជីវករនៅតាមទីផ្សារក្នុងរាជធានី-ខេត្តបានចំនួន ១.៧១៨លើក និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "សុវត្ថិភាពម្ហូបអាហារ និងការពារអ្នកប្រើប្រាស់" និង "យន្តការ និងនីតិវិធីត្រួតពិនិត្យទំនិញ និងការគ្រប់គ្រងសកម្មភាពអាជីវកម្ម លោហធាតុ ត្បូងមានតម្លៃ ជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍" ដល់ក្រុមអាជីវករ ផលិតករ និងប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប បានចំនួន ០៩ លើក មានអ្នកចូលរួមសរុបប្រមាណ ២៧៦.៤២០នាក់
- បានផ្សព្វផ្សាយអំពីសុវត្ថិភាពម្ហូបអាហារដល់សិស្សានុសិស្ស នៅតាមបណ្តាគ្រឹះស្ថានសិក្សា ក្នុងរាជធានី-ខេត្ត ចំនួន ៣៥លើក ដោយមានសិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងអាជីវករតូចតាចចូលរួមចំនួន ១១,៨៧៧ នាក់
- បិទផ្ទាំងរូបភាពផ្សព្វផ្សាយ (Posters) អំពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារដែលមានសុវត្ថិភាព នៅតាមទីផ្សារ និងទីសាធារណៈ បានចំនួន ៥២.៦៣០ ផ្ទាំង។

## ២.១១.៧. ការងារចំណុច ទំនាក់ទំនងអំពីអនាម័យ និងភូតគាមអនាម័យ (SPS Enquiry Points)

- ស្រាវជ្រាវ ពិនិត្យ ជ្រើសរើស និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីអនាម័យ និងភូតគាមអនាម័យ បានចំនួន ៥១១ ករណី (ផ្នែកសុវត្ថិភាពផលិតផលម្ហូបអាហារចំនួន ៣៩៦ករណី ផ្នែកកិច្ចការពារដំណាំចំនួន ៤៨ករណី និងផ្នែកកិច្ចការពារសុខភាពសត្វចំនួន ១១៧ករណី) ពី ៣៨ប្រទេស និងដែនដីរដ្ឋបាល ដែលជាសមាជិក WTO
  - បានតាមដានព្រឹត្តិការណ៍ស្តីពី "សុវត្ថិភាពផលិតផលម្ហូបអាហារ" ដែលកើតមានឡើងនៅប្រទេសនានាបានចំនួន ០៦ ដើម្បីចាត់វិធានការទប់ស្កាត់ការនាំចូល និងស្រាវជ្រាវរកការចរាចរលើទីផ្សារកម្ពុជា ចំពោះផលិតផលនោះ
  - ការរកឃើញវត្តមានបាក់តេរី Bacillus cereus នៅក្នុងផលិតផលតៅហ៊ូ ដែលផលិតនៅកោះតៃវ៉ាន់ ដោយមជ្ឈមណ្ឌលសុវត្ថិភាពម្ហូបអាហារក្រុងហុងកុង
  - ការប្រមូលត្រឡប់មកវិញ នូវផលិតផលអាហារសំរាប់ទារក និងកុមារតូច PC Organic Brand ពីទីផ្សារប្រទេសកាណាដា បន្ទាប់ពីបានរកឃើញកំហុសឆ្គងបានកើតឡើង នៅក្នុងសង្វាក់ផលិតកម្ម ដែលជាសក្តានុពលអំណោយផល ចំពោះការលូតលាស់បាក់តេរី Clostridium botulinum
  - ការប្រមូលត្រឡប់មកវិញនូវផលិតផលម្ហូបអាហារ "I.M. Healthy SoyNut Butter , I.M. Healthy Granola products and Dixie Diner's Club brand" ពីទីផ្សារសហរដ្ឋអាមេរិករបស់ក្រុមហ៊ុន The Soynut Butter Co. ក្រោយពីសង្ស័យមានចម្លងចូលបាក់តេរី E. coli O:157H 7

- ការរកឃើញវត្ថុមានសារធាតុគីមី propyl para-hydroxybenzoate នៅក្នុងគំរូផលិតផលគ្រឿងផ្សំរស់ (Oyster Sauce) ដោយមជ្ឈមណ្ឌលសុវត្ថិភាពផលិតផលម្ហូបអាហារក្រុងហុងកុង។ សារធាតុគីមីនេះ ត្រូវបានហាមប្រើក្នុងផលិតផលម្ហូបអាហារ
- ការប្រមូលត្រឡប់មកវិញពីទីផ្សារប្រទេសបារាំងនូវផលិតផលត្រី Tuna កែវមានគំរប បន្ទាប់ពីរកឃើញវត្ថុមានបំណែកដុំកែវនៅក្នុងផលិតផលនេះ ដោយក្រុមហ៊ុន Conserverie Chancerelle
- ការប្រមូលត្រឡប់មកវិញពីទីផ្សារប្រទេសកាណាដានូវផលិតផលពងត្រី Rainbow Trout Caviar បន្ទាប់ពីបានរកឃើញនូវករណីដែលអាចមានសក្តានុពល អំណោយផលចំពោះការលូតលាស់បាក់តេរី Clostridium botulinum ក្នុងផលិតផលនេះ ដោយក្រុមហ៊ុន International House of Caviar។

## ២.១១.៨. ការងារពាក់ព័ន្ធនឹងកិច្ចការប្រកួតប្រជែង

- បានរៀបចំសិក្ខាសាលាថ្នាក់តំបន់ស្តីពី "ការកសាងស្ថាប័នប្រកួតប្រជែង" នៅក្រុងសៀមរាប ក្រោមកិច្ចសហការរបស់គំរោង CLIP–ASEAN Australia New Zeeland ដោយមានប្រទេសចំនួន ០៤ បានចូលរួម (ប្រទេសកម្ពុជា វៀតណាម ឡាវ និងមីយ៉ាន់ម៉ា)
- បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី "ការផ្សព្វផ្សាយជាសាធារណៈអំពីគោលនយោបាយប្រកួតប្រជែង និង សេចក្តីព្រាងច្បាប់ប្រកួតប្រជែង" ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធចំនួន ០៨
- បានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ២៥លើក ដែលមានប្រធានបទពាក់ព័ន្ធនឹងគោលនយោបាយ និងការអនុវត្តច្បាប់ប្រកួតប្រជែង និងបានចូលរួមទស្សនកិច្ចសិក្សាស្តីពីបទពិសោធន៍នៃការអនុវត្តច្បាប់ប្រកួតប្រជែង ដែលរៀបចំឡើងដោយគណៈកម្មាធិការប្រកួតប្រជែង និងអ្នកប្រើប្រាស់អូស្ត្រាលី និងគណៈកម្មាធិការប្រកួតប្រជែងពាណិជ្ជកម្មញូវែលសេឡង់។

## ២.១១.៩. ការកសាងច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេស

- បានបញ្ចប់សេក្តីព្រាងច្បាប់ស្តីពីម្ហូបអាហារ នៅកម្រិតថ្នាក់បច្ចេកទេស និងកំពុងស្ថិតនៅក្នុងការពិនិត្យ ពិភាក្សារបស់ក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ជាមួយអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី (៧០%សម្រេចបាន )
- ក្រុមការងារបច្ចេកទេសបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង និងបន្តរៀបចំសេចក្តីពន្យល់តាមខ្លឹមសារនៃមាត្រានីមួយៗ
- បានរៀបចំសេចក្តីព្រាងបញ្ញត្តិបច្ចេកទេសស្តីពីការប្រមូលត្រលប់មកវិញ នូវម្ហូបអាហារដែលមានគ្រោះថ្នាក់ (Food Recall) ដើម្បីបង្កើនប្រសិទ្ធភាពទាំងផ្នែកគ្រប់គ្រង និងកិច្ចការត្រួតពិនិត្យ។

## ២.១១.១០. ការងារមន្ទីរពិសោធន៍

- បានទទួលវិភាគគំរូផលិតផល ចំនួន ៤.៩៧៣ គំរូ (ផលិតផលម្ហូបអាហារចំនួន ២.៨៣១គំរូ ផលិតផលកសិផល ចំនួន ១.៣១៦គំរូ ប្រេងឥន្ធនៈចំនួន ៧៩៩គំរូ និងផលិតផលមិនមែនម្ហូបអាហារចំនួន ០៧ គំរូ) ដោយបានរកឃើញគំរូចំនួន ២២៦ (៤.៥០ %) មិនអនុលោមតាមបញ្ញត្តិបច្ចេកទេស
- បានចូលក្នុងកម្មវិធីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍ (Proficiency Testing) ចំនួន ០១លើក ដើម្បីវិភាគរកចំនួនបាក់តេរី Bacillus cereus នៅក្នុងគំរូម្សៅទឹកដោះគោ រៀបចំដោយមន្ទីរ

ពិសោធន៍ QUATEST-3 របស់ប្រទេសវៀតណាម ដែលជាមន្ទីរពិសោធន៍យោងផ្នែកមីក្រូជីវសាស្ត្ររបស់អាស៊ាន

- បានបំពាក់រថយន្តពិសោធន៍ចល័តផ្នែកប្រេងឥន្ធនៈ ចំនួន ០១ គ្រឿង ដែលមានសមត្ថភាពអាចចុះត្រួតពិនិត្យ គុណភាព និងវង្វាស់វង្វាល់ប្រេងនៅតាមបណ្តាស្ថានីយនៅរាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង
- បានអនុញ្ញាតឱ្យនិស្សិត ចំនួន ៤៣៨នាក់ មកពីបណ្តាសកលវិទ្យាល័យ និងវិទ្យាស្ថាន ចំនួន ០៧ ធ្វើកម្មសិក្សាស្តីពី "ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ និងវិធីសាស្ត្រវិភាគរកសារធាតុគីមី និងបាក់តេរី នៅក្នុងម្ហូបអាហារ"
- បានបំពាក់ឧបករណ៍វិភាគដល់មន្ទីរពិសោធន៍ខ្នាតតូច (Mini Lab) ចំនួន ០៣កន្លែង នៅខេត្តបន្ទាយមានជ័យ ខេត្តស្វាយរៀង និងខេត្តព្រះសីហនុ។ ឧបករណ៍ទាំងនោះមានសមត្ថភាពអាចវិភាគរកសារធាតុគីមីហាមឃាត់ ចំនួន ១១ មុខ ក្នុងផលិតផលម្ហូបអាហារ ដូចជា បន្លែ ផ្លែឈើ ត្រី សាច់ អាហារសមុទ្រ និងអាហារកែច្នៃ វេចខ្ចប់ស្រាប់។ល។ និងកំពុងដំណើរការសាងសង់មន្ទីរពិសោធន៍ខ្នាតតូចចំនួន ០៣ បន្ថែមទៀត នៅខេត្តកំពង់ចាម ខេត្តតាកែវ និងខេត្តព្រៃវែង ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០១៧ និងបំពាក់ឧបករណ៍នៅដើម ឆ្នាំ២០១៨ ខាងមុខ។

### ២.១១.១១. ការងារក្នុងក្របខ័ណ្ឌអាស៊ានពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការត្រួតត្រាវិជ្ជា និងសុវត្ថិភាពម្ហូបអាហារ

### ក. ការងារពាក់ព័ន្ធនឹងកិច្ចប្រជុំនានា

មន្ត្រីនៃចំណុចទំនាក់ទំនងថ្នាក់ជាតិ បានចូលរួមក្នុងកិច្ចប្រជុំនានា របស់គណៈកម្មការការពារអ្នកប្រើប្រាស់ អាស៊ាន និងអនុគណៈកម្មការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាម្ហូបអាហារ (SCFST) ដើម្បីពិនិត្យពិភាក្សា លើប្រធានបទដូចខាងក្រោម៖

- កិច្ចប្រជុំរបស់អនុគណៈកម្មការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាម្ហូបអាហារ (SCFST) លើកទី១៤ នៅប្រទេសប្រ៊ុយណេ ដើម្បីរៀបចំឱ្យមានការបណ្តុះបណ្តាលលើអាហារមុខងារ (Functional Foods) និងការវេចខ្ចប់អាហារ (Food Packaging)
- សន្និសីទម្ហូបអាហារ (ASEAN Food Conference) លើកទី១៥ របស់អនុគណៈកម្មការអាស៊ានផ្នែក វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាម្ហូបអាហារ (SCFST) និងបានធ្វើបទបង្ហាញពីការស្រាវជ្រាវលើប្រធានបទម្ហូបអាហារ និងចូលរួមការប្រឡងប្រជែងសំណួរក្នុងវិស័យម្ហូបអាហារ
- កិច្ចប្រជុំលើកទី១៥ របស់គណៈកម្មការការពារអ្នកប្រើប្រាស់អាស៊ាន (15th ACCP) ដើម្បីពិភាក្សាលើ កម្មវិធីការងារ ដែលមាននៅក្នុងផែនការសកម្មភាពជាយុទ្ធសាស្ត្រ អាស៊ានសម្រាប់ ការពារអ្នកប្រើប្រាស់ ២០១៦-២០២៥ និងការពង្រឹងស្ថាប័នអនុវត្តន៍ច្បាប់
- កិច្ចប្រជុំពិសេសរបស់គណៈកម្មការការពារអ្នកប្រើប្រាស់អាស៊ាន ដើម្បីរៀបចំសៀវភៅមគ្គុទេសក៍ស្តីពីកិច្ចការពារអ្នកប្រើប្រាស់អាស៊ាន (Consumer Protection Handbook) និងផ្តល់ការយល់ដឹងអំពីសិទ្ធិរបស់អ្នកប្រើប្រាស់ (Consumer Empowerment)
- វេទិកាពិភាក្សារបស់បណ្តាប្រទេសអាស៊ី លើគោលនយោបាយការពារអ្នកប្រើប្រាស់លើកទី៦ ដើម្បីពិនិត្យ បញ្ហាប្រឈម ដែលកើតមានចំពោះសមត្ថកិច្ចទទួលខុសត្រូវកិច្ចការការពារអ្នកប្រើប្រាស់
- កិច្ចប្រជុំគណៈកម្មការការពារអ្នកប្រើប្រាស់លើកទី១៦ (16th ACCP) ដើម្បីរៀបចំប្រព័ន្ធផ្លាស់ប្តូរព័ត៌មាន អាស៊ានលើគេហទំព័រ ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យផលិតផលមិនមានសុវត្ថិភាពក្នុង

អាស៊ាន និងរៀបចំព័ត៌មាន ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ក្នុងគេហទំព័រអាស៊ាន (ACCP Website)

- បានរៀបចំរូបភាពវីដេអូអំពីភារកិច្ច និងសកម្មភាពនានាពាក់ព័ន្ធនឹងកិច្ចការការពារអ្នកប្រើប្រាស់ ការកសាងច្បាប់ការពារអ្នកប្រើប្រាស់ ការបង្ក្រាបការក្លែងបន្លំ និងការអង្កេតផលិតផលលើទីផ្សារ ការទប់ស្កាត់ទំនិញនាំចូលមិនមានសុវត្ថិភាព ឬមិនអនុលោមនឹងបទប្បញ្ញត្តិនានា ការអប់រំ និងផ្តល់ការយល់ដឹងជូនអ្នកប្រើប្រាស់ ជាពិសេសសិស្ស និងនិស្សិត ជូនដល់លេខាធិការដ្ឋានអាស៊ានដើម្បីដាក់បញ្ចូលក្នុងគេហទំព័រអាស៊ាន
- បានចូលរួមក្នុងកិច្ចប្រជុំលើកទី២៤ នៃក្រុមការងារសុខដុមនីយកម្មស្តង់ដារផលិតផលម្ហូបអាហាររៀបចំស្រេច និងកិច្ចការមន្ទីរពិសោធន៍អាស៊ាន
- បានចូលរួមក្នុងកិច្ចប្រជុំលើកទី៥ នៃក្រុមមន្ត្រី ចំណុចទំនាក់ទំនងថ្នាក់ជាតិ ស្តីពីប្រព័ន្ធផ្តល់ព័ត៌មានរហ័ស ស្តីពីម្ហូបអាហារ និងចំណីសត្វ
- បានចូលរួមកិច្ចប្រជុំក្រុមការងារអ្នកជំនាញប្រកួតប្រជែងអាស៊ាន (AEGC-Meeting) លើកទី១៩ និងលើកទី២០ នៅប្រទេសភូមា ដើម្បីជំរុញលើកកម្ពស់គោលនយោបាយ និងការអនុវត្តច្បាប់ប្រកួតប្រជែងអាស៊ានរហូតដល់ឆ្នាំ២០២៥។

### ខ. ការងារពាក់ព័ន្ធនឹងសិក្ខាសាលា

- ចូលរួមសិក្ខាសាលាស្តីពីការបណ្តុះបណ្តាល E-Commerce ដើម្បីយល់ដឹងពីការរៀបចំច្បាប់បទប្បញ្ញត្តិ ការទទួលពាក្យបណ្តឹងក្នុងស្រុក និងពីបរទេស និងការដោះស្រាយសំណង
- ចូលរួមសិក្ខាសាលាស្តីពី ការកសាងប្រព័ន្ធប្រមូលផលិផលមិនមានសុវត្ថិភាពក្នុងប្រទេសអាស៊ាន-ចិន ដើម្បីយល់ដឹងពីប្រព័ន្ធប្រមូលផលិតផលមិនមានសុវត្ថិភាពក្នុងប្រទេសអាស៊ាន និងរៀបចំផែនការលើកកម្ពស់ការផ្តល់ព័ត៌មានទៅវិញទៅមកតាមរយៈគេហទំព័រអាស៊ាន។

## ២.១១.១២. ការងារពាក់ព័ន្ធនឹងកូដិច

- បានចូលរួមក្នុងកិច្ចប្រជុំលើកទី១៧ របស់ក្រុមការងារកូដិចអាស៊ាន ស្តីពីការពិនិត្យ និងពិភាក្សាអំពីគោលជំហរ របស់អាស៊ាននៅក្នុងការកសាងស្តង់ដារកូដិច នៅប្រទេសឥណ្ឌូណេស៊ី
- លេខាធិការដ្ឋាននៃគណៈកម្មាធិការកូដិចជាតិ បានទទួលឯកសារថ្មីៗ ចំនួន ៨៣ ដែលពាក់ព័ន្ធនឹងសំណើនៃសេចក្តីព្រាងស្តង់ដារកូដិច ដែលត្រូវបានស្នើសុំឱ្យមានការពិនិត្យ និងផ្តល់មតិ ដើម្បីបញ្ជាក់អំពីគោលជំហរជាតិ ក្នុងកិច្ចប្រជុំគណៈកម្មាធិការកូដិចអន្តរជាតិចំនួន ១៧ លើក
- បានចូលរួមក្នុងកិច្ចប្រជុំកូដិចអន្តរជាតិលើកទី៣៩ នៃគណៈកម្មាធិការអាហារូបត្ថម្ភ និងម្ហូបអាហារសម្រាប់ប្រើប្រាស់ជារបបអាហារពិសេស ដែលពាក់ព័ន្ធទៅនឹងការពិនិត្យឡើងវិញនៃស្តង់ដារផលិតផលសម្រាប់ទារក និងកុមារ និងសាធាតុអាហាររូបបត្ថម្ភ ផ្សេងៗទៀត។

## ២.១១.១៣. ការងារពាក់ព័ន្ធនឹងការចូលរួមអនុវត្តន៍គម្រោងផ្សេងៗ

- គម្រោងកម្ចីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់កិច្ចសម្រួលពាណិជ្ជកម្មស្តីពីការធ្វើឱ្យប្រសើរឡើងនូវវិធានអនាម័យ និងភូតគាមអនាម័យ (SPS) នៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- គម្រោងថ្នាក់តំបន់របស់អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) ស្តីពីការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍ និងអនុវត្តន៍ស្តង់ដារសុវត្ថិភាពម្ហូបអាហារក្នុងប្រទេសអាស៊ាន (២០១៦-២០២១)
- គម្រោងសុវត្ថិភាពម្ហូបអាហារ របស់វិទ្យាស្ថានមេគង្គថ្នាក់តំបន់ សម្រាប់ប្រទេស CLMV ដែលពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាល ការគ្រប់គ្រង និងការធ្វើអធិការកិច្ចសុវត្ថិភាពម្ហូបអាហារ ដល់គ្រប់ភាគីពាក់ព័ន្ធទាំងស្ថាប័នជាតិ និងវិស័យឯកជន
- គម្រោងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃឡង់ ស្តីពីផែនការសកម្មភាពស្តង់ដារគុណភាពជំឡូងមីស្ងួត។

## ២.១២. ការងារមន្ត្រី បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលសរុបគិតត្រឹមឆ្នាំ២០១៧នេះមានចំនួន ១.៧១៧នាក់ ក្នុងនោះស្រី ចំនួន ៩៧៥នាក់ (ក្របខ័ណ្ឌប្រភេទ « **ក** » មានចំនួន ១.៣៩៨នាក់ ប្រភេទ « **ខ** » ចំនួន ៩៨នាក់ និងក្របខ័ណ្ឌប្រភេទ« **គ** » ចំនួន ១៨៥នាក់)៖

- ថ្នាក់កណ្តាល៖ ១.២៧៣នាក់
- ថ្នាក់រាជធានី-ខេត្ត៖ ៤៤៤នាក់

### ២.១២.១. ការតែងតាំង

តែងតាំង និងសម្រួលភារកិច្ចជូនមន្ត្រីរាជការ ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសថ្នាក់កណ្តាល ចំនួន១៥២ រូប និងថ្នាក់មន្ទីររាជធានី-ខេត្ត ចំនួន៣១រូប។

### ២.១២.២ .ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

#### ក. ផ្នែកបណ្តុះបណ្តាលក្នុងប្រទេស

- បានចាត់បញ្ជូនមន្ត្រីឲ្យចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលខ្លីៗក្នុងប្រទេសមានចំនួន ១,០៣៨នាក់ ក្នុងនោះស្ត្រីមានចំនួន ២៧៨នាក់ ដោយទទួលការបណ្តុះបណ្តាលទៅលើប្រធានបទដូចជា Regional Comprehensive Economic Partnership (RCEP) ការវិនិយោគអន្តរជាតិ មជ្ឈត្តការពាណិជ្ជកម្ម និងច្បាប់អន្តរជាតិសាធារណៈ "Public-Private Partnerships" អាហារូបករណ៍ទៅសិក្សានៅប្រទេសអូស្ត្រាលី វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី បច្ចេកទេសនៃការបង្កើត និងប្រើប្រាស់ មជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក ផ្តល់វគ្គបណ្តុះបណ្តាលលើជំនាញកិច្ចការបរទេស ការងារពិធីការ និងការទូត ការអភិវឌ្ឍវិស័យឯកជន ការធ្វើតេស្តចូលរៀនវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសកម្រិត១ និងកម្រិត៨
- ចាត់បញ្ជូនមន្ត្រីក្របខ័ណ្ឌថ្មីឆ្នាំ២០១៦ ចូលរួមទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាលចំនួន៩វគ្គ។

#### ខ. ការបណ្តុះបណ្តាលក្រៅប្រទេស

បានចាត់បញ្ជូនមន្ត្រីឲ្យចូលរួមការបណ្តុះបណ្តាលក្រៅប្រទេសមានចំនួន ១៦ នាក់ ក្នុងនោះស្ត្រីចំនួន ០៤ នាក់ នៅ ប្រទេសឥណ្ឌា ប្រទេសថៃ ប្រទេសចិន ប្រទេសជប៉ុន ប្រទេសកូរ៉េ និងប្រទេសអាល្លឺម៉ង់។

## គ. ការអភិវឌ្ឍធនធានមនុស្ស

- ការបណ្តុះបណ្តាល
  - រៀបចំបណ្តុះបណ្តាលចំនួន២០វគ្គ ពាក់ព័ន្ធការងារសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ មជ្ឈត្តកម្ម ច្បាប់អន្តរជាតិ កម្មសិទ្ធិបញ្ញា ស្ថិតិពាណិជ្ជកម្ម ឡូជីស្ទីកពាណិជ្ជកម្ម ការចុះបញ្ជីពាណិជ្ជកម្ម ប្រព័ន្ធគោលនយោបាយពាណិជ្ជកម្មពហុភាគី បញ្ហាប្រទេសអភិវឌ្ឍន៍តិចតួច របៀបប្រើព័ត៌មានរបស់មជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មអន្តរជាតិ ការចរចាកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម ការអភិវឌ្ឍវិស័យឯកជន និងការជំរុញប្រសិទ្ធភាពសហគ្រាសធុនតូច និងមធ្យម ការវិភាគប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀង និងសហប្រតិបត្តិការនានា ការបណ្តុះបណ្តាលភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម វគ្គសិក្សា ពីចម្ងាយស្តីពីការចរចាពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ ដែលមានសិក្ខាកាមសរុបចំនួន១.៣៨៥ នាក់។

- ការងារស្រាវជ្រាវ និងបោះពុម្ពផ្សាយ
  - ស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយស្នាដៃស្រាវជ្រាវស្តីពីខ្សែសង្វាក់តម្លៃ ស្វាយ ស្ករត្នោត និងកង់ ចំនួន ១៥០ ក្បាល ព្រមទាំងបកប្រែស្នាដៃស្រាវជ្រាវផ្សេងៗ ដែលមានអត្ថប្រយោជន៍ដល់តម្រូវការបច្ចុប្បន្នរបស់កិច្ចការពាណិជ្ជកម្មកម្ពុជា
  - ចូលរួមពិភាក្សា និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងការបណ្តុះបណ្តាលការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បញ្ហាសេវាកម្ម និងកសិកម្មជាមួយ IDEA Centre ប្រទេសអូស្ត្រាលី។

## ២.១៣. រដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ

### ២.១៣.១. ការងាររដ្ឋបាលទូទៅ

- ទទួលលិខិតចូលចំនួន ៥.៥០៦ច្បាប់
- ចុះលេខលិខិតចេញចំនួន ៥.០០១ច្បាប់
- រៀបចំកិច្ចប្រជុំនានាបានចំនួន ៣០១លើក សិក្ខាសាលា ២៨លើក បដិសណ្ឋារកិច្ចជាតិ និងអន្តរជាតិ ៨៥លើក ព្រមទាំងជួយសម្របសម្រួលក្នុងដំណើរការរបស់គណៈប្រតិភូដែលបានចូលរួមក្នុងកិច្ចប្រជុំតុមូលចិនលើកទី៥ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម និងកិច្ចប្រជុំប្រឹក្សាយោបល់ថ្នាក់តំបន់(អាស៊ី កាពាប៉ៀន និងប៉ាស៊ីហ្វិក)
- ពង្រឹងសន្តិសុខ និងសុវត្ថិភាពក្នុងទីស្តីការក្រសួង
- ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ (ទឹក ភ្លើង ម៉ាស៊ីនត្រជាក់ លូ ផ្លូវ សួនច្បារ) នៅក្នុងទីស្តីការក្រសួង
- រៀបចំពិធីបដិសណ្ឋារកិច្ចទទួលភ្ញៀវជាតិ-អន្តរជាតិ ពិធីបុណ្យជាតិ និងកិច្ចប្រជុំផ្សេងៗ

### ២.១៣.២. ការងារហិរញ្ញវត្ថុ

- ចំណូល៖

ក្រសួងពាណិជ្ជកម្ម បានប្រមូលចំណូលកម្រៃសេវាសាធារណៈ សរុបប្រចាំឆ្នាំ២០១៧ បានប្រមាណ **២៦៨.០៩៦.៧៩៣.៨១៩ ៛** (ពីររយហុកសិបប្រាំបីប៊ីលាន កៅសិបប្រាំមួយលាន ប្រាំពីររយកៅសិបបីពាន់ ប្រាំបីរយដប់ប្រាំបួនរៀលគត់) ស្មើនឹង **១២០,៦%** (ធៀបនឹងច្បាប់ថវិកាឆ្នាំ

២០១៧ ដែលមានទឹកប្រាក់ចំនួន **២២២.៣៨៥.០០០.០០០៛**) ក្នុងនោះត្រូវបង់ចូលថវិកាជាតិចំនួនប្រមាណ **២២០. ១៦០.៩៩២.០១៨ ៛** (ពីររយម្ភៃបីលាន មួយរយហុកសិបលាន ប្រាំបួនរយកៅសិបពីរពាន់ ដប់ប្រាំបីរៀលគត់)។

❖ **ចំណាយ៖**

បានរៀបចំឯកសារទូទាត់ចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការចំណាយផ្សេងៗដូចតទៅ៖

- ជំពូក ៦០ ចំនួន ១៤.០៣៨.៩៦០.៨៣៥ រៀល ស្មើនឹង ៩៨,០០%
- ជំពូក ៦១ ចំនួន ៣២.៧៣៧.៦៣៩.៩៨៩ រៀល ស្មើនឹង ៩៧,១០ %
- ជំពូក ៦២ ចំនួន ៣.០០០.០០០.០០០ រៀល ស្មើនឹង ១០០,០០ %
- ជំពូក ៦៤ ចំនួន ៦៨.៨៤២.៨០១ .០០០ រៀល ស្មើនឹង ១១០,០៣ %
- ជំពូក ៦៥ ចំនួន ៣៧២.២៦៦.៣៦០ រៀល ស្មើនឹង ៣០,៥៣ %

- បានចូលរួមវេទិកាសាធារណៈស្តីពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងថវិកាឆ្នាំ២០១៧
- បានចូលរួមប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ១). ស្ថានភាពកៀរគរចំណូលមិនមែនសារពើពន្ធ និងការពិបាកទារបំណុលឆ្នាំ២០១៦ ២). វឌ្ឍនភាពនៃការរៀបចំផែនការសកម្មភាពគាំទ្រវិធានការដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (Revenue Mobilization Strategy - RMS) ២០១៤-២០១៨ របស់ក្រសួង-ស្ថាប័ន និង ទិសដៅបន្ត
- បានសហការ និងចូលរួមរៀបចំកែសម្រួលតារាងឧបសម្ព័ន្ធ នៃប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម និងបានឆ្លងសេចក្តីសម្រេចអន្តរក្រសួងជាធរមានដោយត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨
- បានរៀបចំចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា សម្រាប់ការរៀបចំដាក់ក្នុងប្រព័ន្ធ FMIS (Financial Management Information System) ជំហានទី២ និងបានផ្ញើជូនអគ្គនាយកដ្ឋានរតនាគារកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧
- បានប្រមូល និងរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់ក្រសួងពាណិជ្ជកម្មឆ្នាំ២០១៦
- កិច្ចលទ្ធកម្មរបស់ក្រសួងពាណិជ្ជកម្មសរុបមានចំនួន ១១គម្រោង
- បានរៀបចំធ្វើប័ណ្ណកម្មសិទ្ធិអចនលទ្រព្យចំនួន០៣ទីតាំងបន្ថែមក្នុងឆ្នាំ២០១៧
- បានធ្វើលិខិតសំណើសុំគោលការណ៍ដើម្បីពន្លឿនការជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នូវដីនិងកន្លែងស្នាក់នៅដែលស្ថិតនៅក្រោមការកាន់កាប់របស់មន្ទីរពាណិជ្ជកម្មខេត្តទាំង១៧
- ចូលរួមការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០១៨
- បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យឡើងវិញ លើសេចក្តីព្រាងកម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្ម
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីអង្គភាពថវិកា នីតិវិធីនៃការអនុវត្តថវិកាកម្មវិធី ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងនីតិវិធីចំណាយ តាមរដ្ឋទេយ្យបុរេប្រទាន នាថ្ងៃទី០៣-០៤ ខែសីហា ឆ្នាំ២០១៧ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី (អនុវត្តបន្តពីត្រីមាសទី២)

- បានរៀបចំសេចក្តីព្រាងនីតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី
- បានរៀបចំសំណុំឯកសារ និងកិច្ចការពាក់ព័ន្ធសម្រាប់ រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំផែនការលទ្ធកម្មឆ្នាំ២០១៨
- ជំរុញការរៀបចំប័ណ្ណកម្មសិទ្ធដែលនៅសេសសល់ទាំងរដ្ឋបាលកណ្តាល និងថ្នាក់ក្រោមជាតិ
- បានបញ្ចប់រឿងទំនាស់អគារលេខ៦០អ៊ី០ និងធ្វើរបាយការណ៍ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដោយមានការឯកភាពពីរាជរដ្ឋាភិបាល ក្រសួងមានការដោះដូរទ្រព្យសម្បត្តិរដ្ឋ ដោយទទួលបាន សំណង់អគាររដ្ឋបាលថ្មីរបស់មន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ អនុវត្តការសាងសង់សម្រេចបាន៩៩% សំណង់អគាររដ្ឋបាលថ្មីរបស់មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង សម្រេចបាន២០% សំណង់អគាររដ្ឋបាលថ្មីរបស់មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម សម្រេចបាន២៥%។

## ២.១៤. ការនាំចេញអង្ករ និងស្វែងរកទីផ្សារ

យោងតាមតួលេខពីលេខាធិការដ្ឋានសេវាច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករកម្ពុជា ការនាំចេញតាមបណ្តាឆ្នាំកន្លងមកមានដូចខាងក្រោម៖

| | | |
|---|---|---|
| – ឆ្នាំ ២០១២ | = | ២០៥.៧១៧តោន |
| – ឆ្នាំ ២០១៣ | = | ២៧៨.៨៥៦តោន |
| – ឆ្នាំ ២០១៤ | = | ៣៨៧.០៦១តោន |
| – ឆ្នាំ ២០១៥ | = | ៥៣៨.៣៩៦តោន |
| – ឆ្នាំ ២០១៦ | = | ៥៤២.១៤៤តោន |

នៅរយៈពេល១០ខែដើមឆ្នាំ២០១៧ កម្ពុជានាំចេញអង្ករបាន ៤៩ម៉ឺនតោន កើនឡើង ១៦,៧០% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦។ ប្រទេសចិនជាប់ចំណាត់ថ្នាក់លេខ១ នាំចូលអង្ករពីកម្ពុជាច្រើនជាងគេដែលមានចំនួន១៤ម៉ឺនតោន។ តួលេខកើនឡើងនេះបណ្តាលមកពី ៖

- រាជរដ្ឋាភិបាលកម្ពុជាបានជួយសម្រួលដល់បណ្តារោងម៉ាស៊ីន និងក្រុមហ៊ុននាំចេញនានាឲ្យមានភាពងាយស្រួលក្នុងការបំពេញបែបបទផ្សេងៗក្នុងការនាំចេញទៅប្រទេសចិនបានចំនួន ២៦រោងម៉ាស៊ីន ហើយក្រុមហ៊ុនចំនួន ៤៥ មានសិទ្ធិនាំចេញតាមរយៈក្រុមហ៊ុន COFCO
- អាកាសធាតុនៅប្រទេសកម្ពុជាមានលក្ខណៈអំណោយផលដល់វិស័យកសិកម្ម ដែលធ្វើឲ្យបរិមាណទឹកភ្លៀងមានចំនួនគ្រប់គ្រាន់រហូតដល់កសិករអាចបង្កបង្កើនផលបានពីរដងក្នុងមួយឆ្នាំ
- ផ្ទៃដីនៃការដាំដុះមានការកើនឡើង ហើយកសិករភាគច្រើនងាកមកដាំស្រូវប្រណិតដែលអាចបំពេញនូវតម្រូវការនាំចេញបានច្រើនជាងមុន
- បណ្តាខេត្តមួយចំនួនដូចជា ព្រៃវែង កំពង់ធំ ពោធិសាត់ បាត់ដំបង និង បន្ទាយមានជ័យ មានស្រូវសម្រាប់ច្រូតគ្រប់រដូវ ដែលជាហេតុធ្វើអោយការផ្គត់ផ្គង់ស្រូវ-អង្ករបានទាន់ពេលវេលា និង គ្រប់ចំនួន
- កសិករដែលធ្លាប់ប្រើប្រាស់សត្វពាហនៈ(គោ-ក្របី) ក្នុងការធ្វើស្រែបានងាកមកប្រើប្រាស់គ្រឿងយន្តកសិកម្មដូចជាត្រាក់ទ័រវិញបានច្រើន ដែលជាកត្តាជំរុញឲ្យការផលិតស្រូវ-អង្ករមានលក្ខណៈងាយស្រួល និង ឆាប់រហ័ស

ក្នុងនោះ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា បានសម្រេចដាក់ចេញនូវ "កម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល" ដែលមានថវិកាសមមូលនឹងចំនួន ៥០លានដុល្លារអាមេរិក ក្នុងគោលដៅរួមចំណែកដោះស្រាយបញ្ហាខ្វះទុនទិញស្រូវរបស់រោងម៉ាស៊ីនកិនស្រូវ នៅតាមបណ្តាខេត្តគោលដៅ និង

ជំរុញប្រមូលទិញស្រូវសែនក្រអូប ដែលចាប់ផ្តើមប្រមូលផលរហូតដល់ចុងឆ្នាំ និងដើមឆ្នាំក្រោយ ព្រមទាំងអំពាវនាវឲ្យគ្រប់ក្រសួង-ស្ថាប័ន និងប្រជាពលរដ្ឋជួយទិញអង្ករសែនក្រអូបទៅទទួលទាន និងស្តុកក្នុងផ្ទះដើម្បីជួយកាត់បន្ថយការស្តុកទុកតាមបណ្តារោងម៉ាស៊ីនកិនស្រូវ និងដើមទុនបង្វិល ។

ក្នុងនាមក្រុមហ៊ុនហ្គ្រីនត្រេដ ដើម្បីរួមចំណែកក្នុងការទប់ស្កាត់ថ្លៃស្រូវសែនក្រអូបកុំអោយធ្លាក់ថ្លៃ ក្នុងនោះក្រុមហ៊ុនហ្គ្រីនត្រេដបានរួមចំណែក ៖

- ទិញអង្ករសែនក្រអូបពីកសិករនៅក្នុងខេត្តបាត់ដំបងបរិមាណ ២៧តោន និង បន្តគ្រោងទិញបន្ថែមបរិមាណ ៣០តោន នៅ៤ខែចុងឆ្នាំ ២០១៧
- ក្រោមការដឹកនាំ និងចង្អុលបង្ហាញពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនហ្គ្រីនត្រេដបានចរចាទីផ្សារនាំចេញដោយ ៖
  - រក្សាបាននូវទីផ្សារនាំចេញទៅកាន់សហគមន៍អ៊ឺរ៉ុបតាមរយៈកិច្ចសហការជាមួយនឹងសហព័ន្ធស្រូវអង្ករកម្ពុជា
  - នាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋប្រជាមានិតចិន បានសន្យាទិញអង្ករពីកម្ពុជា ចំនួន ២០០.០០០តោន សម្រាប់ឆ្នាំ ២០១៦-២០១៧ និង កើនឡើងដល់បរិមាណ ៣០០.០០០ តោនសម្រាប់ឆ្នាំ ២០១៧ -២០១៨
  - ប្រទេសឥណ្ឌូនេស៊ីបាន និងកំពុងពិនិត្យលទ្ធភាពទិញអង្ករពីប្រទេសកម្ពុជាចំនួន ១០០.០០០ តោន ក្នុងមួយឆ្នាំ និងបន្តជាជំហានៗ
  - រដ្ឋាភិបាលប្រទេសបង់ក្លាដេសបានសន្យាទិញអង្ករពីកម្ពុជា ចំនួន ១.០០០.០០០តោន រយៈពេល ៥ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០២២ តទៅ។

❖ **លទ្ធផលអាជីវកម្មឆ្នាំ ២០១៧**

**ក-លទ្ធផលប្រមូលទិញទំនិញ**

- លើមុខទំនិញស្រូវ ៖ មិនបានអនុវត្ត
- លើមុខទំនិញអង្ករ ៖
  - ទិញចូលរយៈពេល ៨ខែ = ៨.២៨២ តោន ៥០០ = ១៣.៥៩៥.០២១.៣៨៥ រ
  - ប៉ាន់ស្មានទិញចូល៤ខែបន្ត= ១៧.៣៣៥តោន = ២៩.៨៣០.៤០២.២៥០ រ
  - សរុបអនុវត្តឆ្នាំ ២០១៧ = ២៥.៦១៧T៥០០ = ៤៣.៤២៥.៤២៣.៦៣៥ រ
    - អង្ករផ្កាម្លិះ ៥% = ២១៧ តោន
    - អង្ករសែនក្រអូប ៥% = ៣.០២៧តោន
    - អង្ករផ្កាខ្ញី = ៧៣ តោន ៥០០
    - អង្ករអ៊ីអ៊ែរ ៥% = ១២.០០០តោន
    - អង្ករអ៊ីអ៊ែរ ១០% = ១០.០០០តោន
    - អង្ករអ៊ីអ៊ែរ ៣៥% = ៣០០តោន

សរុបទិញបានឆ្នាំ២០១៧ បរិមាណ ២៥.៦១៧តោន៥០០ គិតជាទឹកប្រាក់ ៤៣.៤២៥.៤២៣.៦៣៥រៀល ស្មើនឹង ២៥៩,៨១%នៃផែនការទិញ។

**ខ-លទ្ធផលលក់ចេញ**

- លើមុខទំនិញស្រូវ ៖ មិនបានអនុវត្ត
- លើមុខទំនិញអង្ករ ៖

- លក់ចេញរយៈពេល ៨ខែ = ១១.៨៥៣តោន៩៤៦ = ២០.៥៤០.៨២៦.០៥២ រ
- ប៉ាន់ស្មានលក់ចេញ ៤ខែបន្ត = ១៧.៣៣៥តោន = ៣០.០៩៧.៤៤៧.៨០០ រ
- សរុបអនុវត្តឆ្នាំ ២០១៧ = ២៩.១៨៨តោន៩៤៦ = ៥០.៦៣៨.២៧៥.៨៥២ រ
  - លក់ជូនរាជរដ្ឋាភិបាល = ១.៤៤២តោន៣០៨
  - លក់ជូន WFP = ២.៣០០តោន
  - លក់សហការនាំចេញ = ២៥.២០០តោន
  - លក់រាយ និងផ្សេងៗ = ២៤៦តោន៦៣៨

សរុបលក់បានឆ្នាំ២០១៧ បរិមាណ ២៩.១៨៨ តោន៩៤៦ គិតជាទឹកប្រាក់ ៥០.៦៣៨.២៧៥.៨៥២រៀល ស្មើនឹង ៣០៩,៦៤% នៃផែនការលក់។

❖ **ការគ្រប់គ្រងស្តុកត្រៀមបម្រុងរាជរដ្ឋាភិបាល**

ស្ថានភាពស្តុកត្រៀមរបស់រាជរដ្ឋាភិបាល ២០១៧ ក្នុងនោះ ៖

- ស្តុកថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៧ = ១៣.៣៦១តោន៩៩៧
- ទិញចូលឆមាសទី ១ ឆ្នាំ ២០១៧ = ១.៤៤២តោន៣០៨
- បញ្ចេញប្រើប្រាស់ឆមាសទី១ ឆ្នាំ ២០១៧ = គ្មាន
- ស្តុកត្រៀមបម្រុងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៧ = ១៤.៨០៤តោន៣០៥។

## ២.១៥. ការងារអធិការកិច្ច និងសវនកម្ម

### ២.១៥.១. ការងារអធិការកិច្ច

- ចុះធ្វើអធិការកិច្ច បានចំនួន ៣៣អង្គភាព រួមមាន៖ មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ១២អង្គភាព សាខាកាំកុងត្រូលប្រចាំខេត្ត ១១អង្គភាព នាយកដ្ឋានចំណុះទីស្តីការក្រសួង ១០អង្គភាព។ រាល់អនុសាសន៍ដែលតម្រូវឲ្យមានការកែលម្អ រួមមាន៖
  - កំហុសឆ្គងទាក់ទងនឹង ការងារគ្រប់គ្រងរដ្ឋបាល-បច្ចេកទេសចំនួន ៣១ករណី
  - កំហុសឆ្គងទាក់ទងនឹង ការងារគណនេយ្យ-ហិរញ្ញវត្ថុចំនួន ១០ករណី
  - កំហុសឆ្គងទាក់ទងនឹង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋចំនួន ០៧ករណី។
- ចុះធ្វើអធិការកិច្ច Spot Check បានចំនួន ១២លើក ទៅលើការងារគ្រប់គ្រងបញ្ជីវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៅតាមអង្គភាពចំណុះទីស្តីការក្រសួងពាណិជ្ជកម្ម
- បានជូនដំណឹង តាមដាន និងវាយតម្លៃលទ្ធផល នៃការកែលម្អចំណុចខ្វះខាត តាមអនុសាសន៍ របស់ប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានលើកឡើងចំនួន ២៧អង្គភាព សរុប ៦៩ករណី
- បានធ្វើការតាមដាន ត្រួតពិនិត្យ បូកសរុប និងធ្វើរបាយការណ៍ស្តីពី ស្មារតីនៃការអនុវត្តការងារ និងរបបប្រជុំ របស់អង្គភាពចំណុះទីស្តីការក្រសួង និងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត សរុប ១២លើក ស្មើនឹង ៥២អង្គភាព
- ការងារទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ៖ ដោះស្រាយបណ្តឹងរបស់សាធារណៈជនទាក់ទងនឹងការផ្តល់សេវាសាធារណៈ ចំនួន ១០ករណី និងតាមចំណាររបស់ថ្នាក់ដឹកនាំក្រសួង ចំនួន ១១លើក ទាក់ទងនឹង:

- បញ្ហាសាមគ្គីភាពផ្ទៃក្នុងមន្ត្រីរាជការ ០៥លើក
- បញ្ហាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ០៥លើក
- បញ្ហាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ០១លើក

### ២.១៥.២. ការងារសវនកម្មផ្ទៃក្នុង

ដោយផ្អែកលើផែនការចុះធ្វើសវនកម្មប្រចាំឆ្នាំ២០១៧ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្មបានចំនួន៤៧សវនដ្ឋានរួមមាន៖ អគ្គនាយកដ្ឋានចំនួន ០៣ (មានសវនដ្ឋានចំនួន១៧) មន្ទីរពាណិជ្ជកម្មចំនួន ១៣ សាខាកាំកុងត្រូលចំនួន ១៣ និងតំបន់សេដ្ឋកិច្ចពិសេសចំនួន ០៤៖

- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ(នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក នាយកដ្ឋានអាមេរិក នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់)
- អគ្គនាយកដ្ឋានកាំកុងត្រូល រួមមាននាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ នាយកដ្ឋានមន្ទីរពិសោធន៍ និងនាយកដ្ឋាន កិច្ចការប្រកួតប្រជែង
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ រួមមាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- មន្ទីរពាណិជ្ជកម្ម និងសាខាកាំកុងត្រូលខេត្តក្រចេះ រតនគិរី ព្រះសីហនុ កំពត កែបមណ្ឌលគិរី ត្បូងឃ្មុំ បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រៃវែង ស្វាយរៀង ប៉ៃលិន បាត់ដំបង និងកោះកុង
- តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ខេត្តស្វាយរៀង(មេនហាតធេនស្វាយរៀង-តាយសេង បាវិត សាន់ដុង សាន់សេលស្វាយរៀង និងដ្រេហ្គនឃីង បាវិត) ខេត្តខេត្តកោះកុង (នាងកុក) និងតំបន់សេដ្ឋ-កិច្ចពិសេសខេត្តបន្ទាយមានជ័យ(អូរនាង ប៉ោយប៉ែត និងសានកូប៉ោយប៉ែត)។

ការធ្វើសវនកម្មនេះគឺផ្តោតលើ ការតាមដានអនុសាសន៍គ្រាមុន ការត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ អនុលោមភាពនៃច្បាប់ បទប្បញ្ញត្តិនានា និងរាល់ប្រតិបត្តិការឆ្នាំ ២០១៦ និងឆ្នាំពាក់ព័ន្ធ។

ជាលទ្ធផល រួមមានដូចខាងក្រោម៖

- **ការតាមដានអនុសាសន៍គ្រាមុន**
  - អនុលោមអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពី “ការគ្រប់គ្រងវត្តមាន មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា” ឃើញថា សវនដ្ឋានបាន និងកំពុងអនុវត្តតាមអនុក្រឹត្យនេះ ប៉ុន្តែនៅមានសវនដ្ឋានខ្លះមិនទាន់បានអនុវត្តពេញលេញនៅឡើយ
  - ការធ្វើរបាយការណ៍បូកសរុបការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់ការិយាល័យនីមួយៗនៃសវនដ្ឋានខ្លះមិនទាន់អនុវត្តតាមអនុសាសន៍នៅឡើយ
  - ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពាក់ព័ន្ធនឹងការធ្វើប័ណ្ណកម្មសិទ្ធិ ដីធ្លី អគារ និងបញ្ជីបច្ចុប្បន្នភាព មានសវនដ្ឋានខ្លះកំពុងរង់ចាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធ LMAP និងខ្លះទៀត ដោយសារដីនោះមានជម្លោះ កំពុងរង់ចាំធ្វើការដោះស្រាយ។ រីឯការធ្វើប័ណ្ណកម្មសិទ្ធិសម្គាល់អចលនទ្រព្យត្រូវបានដាក់ជូនទៅស្ថាប័នមានសមត្ថកិច្ចរួចរាល់ហើយ ប៉ុន្តែស្ថាប័នមានសមត្ថកិច្ចឲ្យរង់ចាំការចុះបញ្ជីជាប្រព័ន្ធ LMAP

- ការអនុវត្តនូវស្តង់ដារសេវាសាធារណៈដែលទាក់ទងទៅនឹងការបិទផ្សាយនូវនីតិវិធីនៃការផ្តល់សេវា មានសវនដ្ឋានខ្លះមិនបានអនុវត្តតាមប្រកាសរួមលេខ៩៨៥សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

- **លទ្ធផលវឌ្ឍនភាពសវនកម្មផ្ទៃក្នុង**

ផ្អែកតាមផែនការចុះធ្វើសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង សង្កេតឃើញថា សកម្មភាពកែលម្អលទ្ធផលការងារសវនកម្មផ្ទៃក្នុងដែលបានអនុវត្តក្នុងឆ្នាំ ២០១៧នេះមានដូចតទៅៈ

- អង្គភាពផ្តល់សេវាសាធារណៈមួយចំនួនមិនទាន់បិទផ្សាយនូវនីតិវិធីនៃការផ្តល់សេវាសាធារណៈនៅនឹងកន្លែងផ្តល់សេវានៅឡើយ
- របាយការណ៍បូកសរុបការងារប្រចាំត្រីមាស ឆមាស និងឆ្នាំ របស់ការិយាល័យនីមួយៗនៃសវនដ្ឋានខ្លះមិនទាន់អនុវត្តតាមអនុសាសន៍នៅឡើយ
- ការធ្វើប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ការស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌនូវទ្រព្យសម្បត្តិដែលខូចគុណភាព និងការដោះស្រាយទំនាស់លើការស្នាក់នៅរបស់ប្រជាពលរដ្ឋដែលបានរំលោភកាន់កាប់ដី ឃ្លាំងរបស់រដ្ឋកំពុងស្រាយបញ្ចប់ជាស្ថាពរ។

## ២.១៦. ការងារយេនឌ័រ

លទ្ធផលនៃការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៧រួមមានដូចខាងក្រោមៈ

- បើកវគ្គផ្សព្វផ្សាយអំពីយ៉េនឌ័រ អនុសញ្ញាស៊ី-ដ សេចក្តីសន្និដ្ឋាន៥២ចំនុច របស់អង្គការសហប្រជាជាតិ ដែលប្រព្រឹត្តិទៅនៅទីស្តីការក្រសួងពាណិជ្ជកម្ម (ដែលមានសិក្ខាកាមចូលរួមចំនួន៨៥នាក់ ក្នុងនោះស្ត្រីចំនួន៦៣នាក់)
- បើកវគ្គបណ្តុះបណ្តាល ស្តីពីគោលគំនិតយេនឌ័រ សមភាពយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ បញ្ហាប្រឈម ការតស៊ូមតិ និងអនុសញ្ញាស៊ី-ដ នៅខេត្តកំពង់ស្ពឺ ( ដែលមានសិក្ខាកាមចូលរួមចំនួន៧៣ នាក់ក្នុងនោះស្តីចំនួន ៤៨ នាក់)
- បើកវគ្គបណ្តុះបណ្តាល ស្តីពីអនុសញ្ញាលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ និងច្បាប់ពាក់ព័ន្ធក្នុងការអនុវត្តបំពេញសិទ្ធិរបស់ស្ត្រី និងការផ្សព្វផ្សាយជូនពាណិជ្ជករ អាជីវករ ជាស្ត្រី ស្តីពីសុវត្ថិភាពចំណីអាហារ និងការថែទាំសុខភាពមាតា និងកុមារ នៅខេត្តតាកែវ (ដែលមានសិក្ខាកាមចូលរួមចំនួន ៦៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ៤៣នាក់)
- បើកវគ្គបណ្តុះបណ្តាល ស្តីពីគោលគំនិតយេនឌ័រ សមភាពយេនឌ័រ ក្នុងវិស័យពាណិជ្ជកម្ម និងការអភិវឌ្ឍស្ត្រីក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម នៅខេត្តមណ្ឌលគីរី (ដែលមានសិក្ខាកាមចូលរួមចំនួន ៦៩ នាក់ ក្នុងនោះស្ត្រីចំនួន ៥៤ នាក់)
- ប្រជុំរៀបចំ ចងក្រងកែសម្រួលផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ ២០១៧-២០២៣ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ( ដែលមានសិក្ខាកាមចូលរួមចំនួន ៩០នាក់ ក្នុងនោះស្ត្រីចំនួន ៧៣នាក់)

- ពិនិត្យកែសម្រួលផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រឆ្នាំ២០១៧-២០១៣ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ( ដែលមានសិក្ខាកាមចូលរួមចំនួន ៨៧នាក់ ក្នុងនោះស្ត្រីចំនួន ៥២នាក់)
- ចូលរួមប្រជុំបូកសរុបសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៧ និងការលើកទិសដៅសកម្មភាពការងារបញ្ជ្រាបយេនឌ័រឆ្នាំ២០១៨ នៅទីស្តីការក្រសួងពាណិជ្ជកម្ម (ដែលមានសិក្ខាកាមចូលរួមចំនួន ៩៣នាក់ ក្នុងនោះស្រ្តីចំនួន ៦៨នាក់)
- ស្របនឹងការចូលរួមបើកវគ្គបណ្តុះបណ្តាល និងវគ្គផ្សព្វផ្សាយនេះ ក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម ដែលមាន លោកជំទាវ តឹករ៉េត កំរង ជាប្រធានក៏បានចុះសួរសុខទុក្ខ និងនាំយកអំណោយជាប្រាក់ឧបត្ថម្ភជូនដល់សមាជិកក្រុមការងារថ្នាក់ជាតិ ដែលជួបប្រទះដោយគ្រោះថ្នាក់ធម្មជាតិ និងចូលរួមរំលែកទុក្ខជាមួយគ្រួសារសព និងនិវត្តជន ជាអតីតមន្ត្រីមន្ត្រីរាជការដែលបានទទួលមរណភាព។

## ៣. សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

### ៣.១. ការងារគ្រប់គ្រងអាជីវកម្ម

- លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបាន ១៤០៥៩ ច្បាប់ នៅតាមបណ្តារាជធានី-ខេត្តទាំង២៥
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវកម្ម ពាណិជ្ជកម្ម បានចំនួន ៦៨៦០ ច្បាប់ តាមរយៈការិយាល័យច្រកចេញចូលតែមួយ នៅតាមក្រុង-ស្រុក-ខណ្ឌគោលដៅ
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មគ្រឿងអលង្ការ លោហធាតុ និងត្បូងថ្មមានតម្លៃបានចំនួន ៣១១៨ ច្បាប់
- ចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃ ជារូបិយប័ណ្ណបរទេសបានចំនួន ៩៨០ ច្បាប់ ដោយយោងទៅលើប្រកាសលេខ ២៦៦៣.ណបលប្រ.ក របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការធ្វើប្រតិភូកម្មការងារគ្រប់គ្រងការងារចេញលិខិតបិទស្លាកថ្លៃ
- ផ្តល់ប្រឹក្សាជួយសម្រួលដល់ពាណិជ្ជករ អាជីវករដែលមានបំណងចង់បង្កើតអាជីវកម្ម ការចុះបញ្ជីពាណិជ្ជកម្មសហគ្រាស ក្រុមហ៊ុន ចុះបញ្ជីម៉ាក និងសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារប្រកបអាជីវកម្ម
- ផ្សព្វផ្សាយណែនាំ អំពីតម្រូវការទីផ្សារ ពិសេសចំពោះមុខទំនិញកសិផល ដែលជាតម្រូវការទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ដើម្បីតម្រង់ទិសឲ្យកសិករអាចសម្រេចចិត្តធ្វើការដាំដុះបានត្រឹមត្រូវជៀសវាងការធ្លាក់ថ្លៃ និងទំនិញកកស្ទះ
- សហការ និងជួយសម្រួលការងារភ្នាក់ងារកាំកុងត្រូល ក្នុងការត្រួតពិនិត្យអនុលោមភាពបទដ្ឋានបច្ចេកទេស មុខទំនិញម្ហូបអាហារ ទំនិញវេចខ្ចប់ និងស្វែងរកសារធាតុគីមីហាមឃាត់ដែលអាចប៉ះពាល់ សុខភាពអ្នកប្រើប្រាស់។

### ៣.២. ការខារជំរុញពាណិជ្ជកម្ម

- ស្រង់ស្ថិតិថ្លៃទំនិញចាំបាច់សម្រាប់ជីវភាពនៅទីផ្សារបញ្ជូលជាប្រចាំមកក្រសួង សម្រាប់ប្រើប្រាស់ក្នុងវិភាគព័ត៌មានពាណិជ្ជកម្ម
- តាមដានត្រួតពិនិត្យ និងផ្សព្វផ្សាយណែនាំ ឲ្យមានការបិទស្លាកថ្លៃទំនិញនៅលើទីផ្សារដើម្បីធានាតម្លាភាពរវាងអ្នកទិញ និងអ្នកលក់
- សហការជាមួយគណៈកម្មការរៀបចំពិព័រណ៍ថ្នាក់ខេត្ត រៀបចំពិព័ណ៌ប្រចាំឆ្នាំ និងពិព័រណ៍នាំចេញនាំចូលជារៀងរាល់ឆ្នាំ
- ចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិរៀបចំដោយខេត្តសម្ព័ន្ធភាព ដែលធ្វើឡើងនៅតាមខេត្តនីមួយៗ
- ចូលរួមផ្សព្វផ្សាយការការអនុវត្តច្បាប់ពាណិជ្ជកម្មដល់អាជីវករ និងសភាពាណិជ្ជកម្មដើម្បីឲ្យយល់ដឹង អំពីបទប្បញ្ញត្តិ ច្បាប់ពាណិជ្ជកម្មថ្មីៗ ដែលទើបនឹងកសាង និងដាក់ឲ្យអនុវត្ត
- ចូលរួមក្នុងវេទិកាសាធារណៈ ដើម្បីស្តាប់នូវសំណូមពររបស់ប្រជាពលរដ្ឋ និងអាជីករទាក់ទងនឹងវិស័យពាណិជ្ជកម្ម សំដៅផ្តល់នូវដំណោះស្រាយចំពោះមុខទាន់ពេលវេលា។

# ជំពូក២

# ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០១៨

## ១. ការងារអធិការកិច្ច

- អនុវត្តផែនការធ្វើអធិការកិច្ច អង្គភាពនានា ក្នុងក្រសួងពាណិជ្ជកម្មប្រចាំឆ្នាំ២០១៨
- ចុះធ្វើអធិការកិច្ច Spot Check លើការគោរពវិន័យ ពេលម៉ោងធ្វើការ សណ្តាប់ធ្នាប់ និងសកម្មភាពអវិជ្ជមាននានា ដែលធ្វើឲ្យរាំងស្ទះ ដល់គោលនយោបាយកំណែទម្រង់របស់ក្រសួងពាណិជ្ជកម្ម
- បន្តតាមដានការគោរពបទបញ្ជាផ្ទៃក្នុង និងការធ្វើរបាយការណ៍កិច្ចប្រជុំផ្ទៃក្នុង ត្រួតពិនិត្យការអនុវត្តការងាររបស់បណ្តាអង្គភាពចំណុះទីស្តីការក្រសួងពាណិជ្ជកម្ម
- តាមដានការកែលម្អតាមបណ្តាអនុសាសន៍នានា ដែលបានរកឃើញដោយក្រុមអធិការកិច្ច និងសវនកម្ម ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា អង្គភាពដែលមានកំហុសឆ្គង ពិតជាបានកែលម្អពិតប្រាកដមែន
- បន្តអនុវត្តតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង លើបញ្ហាផ្សេងៗ ដែលកើតមានឡើង។

## ២. ការងារសវនកម្មផ្ទៃក្នុង

- តាមដាន និងវាយតម្លៃការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន
- ចុះធ្វើសវនកម្មនៅ ៤៧អង្គភាព រួមមានៈ
    - អគ្គនាយកដ្ឋានចំនួន ៣ (មានសវនដ្ឋានចំនួន១៧)
    - មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តចំនួន ១៣
    - សាខាកាំកុងត្រូលប្រចាំខេត្តចំនួន ១៣
    - តំបន់សេដ្ឋកិច្ចពិសេសចំនួន៤។

❖ **ការងារពង្រឹងស្ថាប័ន**

- បន្តរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីជំរុញ និងពង្រឹងស្មារតីគោរពវិន័យ ការងារសាមគ្គីភាព វប្បធម៌នៃការចែករំលែក និង ក្រមសីលធម៌វិជ្ជាជីវៈ ដែលធ្វើឲ្យការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹងស្ថាប័ន និងគុណភាពការងារ ដើម្បីមានសមត្ថភាពបង្កើតរបាយការណ៍សវនកម្មមួយស្របតាមកម្រិតស្តង់ដារអន្តរជាតិ តាមរយៈការងារបណ្តុះបណ្តាលមន្ត្រី តាមវគ្គសិក្សានានា ដែលក្នុងនោះផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលទាំងក្នុង និងខាងក្រៅក្រសួង។

## ៣. ការងាររដ្ឋបាល

- រៀបចំរបាយការណ៍បូកសរុបសកម្មភាពការងារពាណិជ្ជកម្មប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ របស់ក្រសួងពាណិជ្ជកម្ម ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំសន្និបាតបូកសរុបការងារពាណិជ្ជកម្មប្រចាំឆ្នាំ២០១៨ និងទិសដៅអនុវត្តន៍ការងារពាណិជ្ជកម្មឆ្នាំ២០១៩
- ចាត់ចែងការងារពិធីការ និងបដិសណ្ឋាកិច្ចផ្សេងៗ ក្នុងការរៀបចំបន្ទប់/សាលប្រជុំ រៀបចំពិធីបុណ្យ ឬទិវាបុណ្យជាតិ / អន្តរជាតិនានា

- គ្រប់គ្រងចរាចរលិខិតចេញ-ចូល ឯកសាររដ្ឋបាលផ្សេងៗ រៀបចំលិខិតអញ្ជើញ ទទួល និងចែកលិខិតឲ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា
- រៀបចំការងារគ្រប់គ្រងបណ្ណាល័យ និងបណ្ណសារ
- ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងក្រសួង
- រៀបចំថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងអនាម័យ នៅក្នុងទីស្តីការក្រសួងពាណិជ្ជកម្ម។

## ៤. ការងារមន្ត្រី

- បន្តរៀបចំបញ្ចូនទិន្នន័យបុគ្គលិក តារាងព័ត៌មានប្រតិបត្តិ និងសំណុំឯកសារឡើងវិញទាំងអស់ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា «ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា» (Database Management System)
- រៀបចំឯកសារមន្ត្រីកម្មសិក្សាក្នុងក្របខ័ណ្ឌឆ្នាំ២០១៧ ដើម្បីស្នើសុំតាំងស៊ប់ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ជូនក្រសួងមុខងារសាធារណៈ
- ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការតាមអង្គភាព និងរចនាសម្ព័ន្ធចាត់តាំង
- រៀបចំឯកសារតម្លើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីរាជការប្រចាំឆ្នាំ
- រៀបចំបញ្ចូលប្រាក់បៀវត្សមន្ត្រីរាជការក្នុងតារាងព័ត៌មានវិទ្យា
- សិក្សាស្រាវជ្រាវពីរចនាសម្ព័ន្ធរបស់អង្គភាព/ក្រសួងពាណិជ្ជកម្ម នៃប្រទេសក្នុងតំបន់អាស៊ានដើម្បីពិនិត្យលទ្ធភាពកែសម្រួលរចនាសម្ព័ន្ធក្រសួងឱ្យស្របតាមនិន្នាការតំបន់ និងសកល
- ជំរុញធ្វើទំនើបកម្មវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ រួមទាំងការធ្វើទំនើបកម្មបណ្ណាល័យ និងសម្ភារឧបទ្ទេស ដើម្បីទទួលបានទំនុកចិត្តទាំងថ្នាក់ជាតិ និងអន្តរជាតិ
- បន្តសហការជាមួយដៃគូ ដើម្បីជំរុញសមត្ថភាពបណ្តុះបណ្តាលស្រាវជ្រាវ ឈានទៅរកការកសាងផែនការបណ្តុះបណ្តាល និងកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពកម្រិតអន្តរជាតិ
- ជំរុញបង្កើតមជ្ឈមណ្ឌលកសាងសមត្ថភាពភាពជាសហគ្រិន សហការជាមួយវិស័យឯកជន។

## ៥. ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- លើកគម្រោងផែនការថវិកាក្រសួងឆ្នាំ២០១៩ និងចូលរួមការពារគម្រោងថវិការបស់ក្រសួង ឆ្នាំ២០១៩
- រៀបចំសំណើចំណាយប្រចាំខែ និងត្រីមាស
- រៀបចំរបាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ
- ចងក្រងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងទ្រព្យសម្បត្តិរដ្ឋ។

## ៦. ការងារអភិវឌ្ឍន៍វិស័យឯកជន

- បន្តកសាងផែនការពាណិជ្ជកម្ម ដោយសហការជាមួយនាយកដ្ឋានក្រោមឱវាទក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យសម្រាប់ផែនការពាណិជ្ជកម្មឆ្នាំ២០១៩-២០២៣
- បន្តសហការជាមួយក្រសួងផែនការ ចូលរួមជំរុញការអនុវត្តគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣
- បន្តរៀបចំកែលម្អព្រឹត្តិប័ត្រព័ត៌មានពាណិជ្ជកម្មទាំងរូបភាព និងខ្លឹមសារ ព្រមទាំងជំរុញចងក្រង និងវិភាគទិន្នន័យពាណិជ្ជកម្មសម្រាប់ការប្រើប្រាស់ឱ្យមានប្រសិទ្ធភាព ក៏ដូចជាសម្រាប់ចងក្រងព័ត៌មានស្ថិតិឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីបម្រើសេចក្តីត្រូវការរបស់រដ្ឋ និងឯកជន

- បន្តពង្រឹងសមត្ថភាពសភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម ដើម្បីជំរុញការចូលរួមរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- បន្តពង្រឹងការអភិវឌ្ឍផលិតផលថ្មីៗ ទាំងបរិមាណ និងគុណភាព ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ព្រមទាំងចូលរួមប្រកួតប្រជែងនៅក្នុងទីផ្សារអន្តរជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីផលិតផលទាំងនោះតាមបណ្តារាជធានី-ខេត្ត
- សម្របសម្រួលរៀបចំកិច្ចប្រជុំកំពូលប្រចាំឆ្នាំរបស់សភាពាណិជ្ជកម្មកម្ពុជា
- រៀបចំផែនការសកម្មភាព និងបន្តអនុវត្តការងារអភិវឌ្ឍន៍ផលិតផលសូត្រ តាមមូលដ្ឋានផលិតកម្មសំខាន់ៗ នៅបណ្តាខេត្តចំនួន៦
- សហការជំរុញការអនុវត្តការបិទស្លាកថ្លៃទំនិញលើទីផ្សារ ការចេញលិខិតអនុញ្ញាតប្រកប អាជីវកម្មពាណិជ្ជកម្ម និងសេវាកម្ម ការប្រកបអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ព្រមទាំងការពិនិត្យតាមដានសន្និធិប្រេងឥន្ធនៈ និងហ្គាស នៅតាមរាជធានី-ខេត្តទាំង ២៥
- បន្តបញ្ជើយការកសាងសេចក្តីព្រាងច្បាប់ ដែលកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សា ដើម្បីដាក់ជូនទៅស្ថាប័នអនុម័តច្បាប់ និងបន្តកសាងលិខិតបទដ្ឋានគតិយុត្តចាំបាច់ផ្សេងទៀត សម្រាប់ការអនុវត្តច្បាប់ទាំងនោះ ឱ្យមានប្រសិទ្ធភាព
- បន្តការកសាងសេចក្តីព្រាងច្បាប់ពាណិជ្ជកម្មផ្សេងទៀត ដែលចាំបាច់តាមតម្រូវការរបស់ការងារពាណិជ្ជកម្មថ្នាក់តំបន់ និងពិភពលោក
- បន្តអនុវត្តការចុះបញ្ជីទទួលស្គាល់កិច្ចប្រតិបត្តិការ ដែលមានកិច្ចធានា និងជំរុញឱ្យវិស័យឯកជនប្រើប្រាស់សេវានេះ ដើម្បីបង្កើនប្រសិទ្ធភាពធុរកិច្ចរបស់ខ្លួន
- បន្តអនុវត្តការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ទៅតាមផែនការសកម្មភាពប្រចាំឆ្នាំ និងបន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រី ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កិច្ចការនេះ
- បន្តបកប្រែ និងធ្វើសម្រង់ខ្លឹមសារសំខាន់ស្នាដៃសិក្សាស្រាវជ្រាវអន្តរជាតិនានា ដែលផ្តល់អត្ថប្រយោជន៍ដល់វិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា
- បន្តបើកវគ្គសិក្សាពីចម្ងាយ វគ្គភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែង និងសិក្ខាសាលាជូនមន្ត្រីពាណិជ្ជកម្មរាជធានី-ខេត្ត និងវិស័យឯកជន។

## ៧. ការងារចុះបញ្ជីពាណិជ្ជកម្ម

- បន្តកសាងលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តិកម្មដូចជា៖ បញ្ចប់សេចក្តីព្រាងប្រកាស ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម លើការកែប្រែ ផ្ទេរភាគហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម រៀបចំប្រកាស ស្តីពីការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ប្រកាសស្តីពីការចុះបញ្ជីសាខាក្រុមហ៊ុនក្នុងស្រុកតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ធ្វើការកែប្រែ និងរៀបចំសេចក្តីជូនដំណឹង ស្តីពីការអនុវត្តកម្រៃសេវានៅលើប្រព័ន្ធស្វ័យប្រវត្តិកម្មតាមប្រកាសរួមថ្មី
- ធ្វើទំនើបកម្មដើម្បីអាចចុះបញ្ជីសាខាក្រុមហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- រៀបចំប្រព័ន្ធដើម្បីគ្រប់គ្រងទិន្នន័យ នៃការចេញលិខិតអនុញ្ញាតការប្រកបរបរអាជីវកម្មតាម រាជធានី-ខេត្ត
- ការធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម ដោយបន្ថែមមុខងារផ្តល់សេវាមួយចំនួនទៀត
- រៀបចំឃ្លាំងឯកសារថ្មី-អភិវឌ្ឍឃ្លាំង និងបំពាក់សម្ភារ បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មគ្រប់គ្រងឯកសារ

- បន្តការបញ្ចូលទិន្នន័យ នៃការចុះបញ្ជីពាណិជ្ជកម្ម ដែលមានសកម្មភាពទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ពិនិត្យលទ្ធភាពក្នុងការបន្តការចុះបញ្ជីសារឡើងវិញ រៀបចំបញ្ជីក្រុមហ៊ុនដែលមិនបានចុះបញ្ជីសារឡើងវិញ ត្រឹមចុងឆ្នាំ២០១៨ និងស្នើសុំគោលការណ៍ថ្នាក់ដឹកនាំនូវចំណាត់ការតាមផ្លូវច្បាប់
- រៀបចំបញ្ជីថ្មី ឬកែលម្អបញ្ជីដែលមានស្រាប់ ឲ្យមានលក្ខណៈសមស្រប និងងាយស្រួលដល់អតិថិជនដែលមកទំនាក់ទំនងដោយផ្ទាល់
- បន្តបណ្តុះបណ្តាល និងផ្សព្វផ្សាយការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តិកម្មដល់សាធារណជន
- អនុវត្តប្រកាស ស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដោយការរៀបចំវគ្គបណ្តុះបណ្តាល បង្កើតគណៈកម្មការប្រឡងបញ្ចប់វគ្គ រៀបចំឈ្មោះ និងប័ណ្ណសំគាល់អ្នកតំណាងស្របច្បាប់។

## ៨. ការងារកម្មសិទ្ធិបញ្ញា

- បន្តអនុវត្តផែនការសកម្មភាព ក្រោមអនុស្សរណៈនៃការយោគយល់គ្នា ក្នុងវិស័យកម្មសិទ្ធិបញ្ញាជាទម្រង់ទ្វេភាគី ឬពហុភាគី KIPO, SIPO, MOST, LAO, JPO, USPTO, THAILAND, ASEAN-CHINA, ASEAN-JAPAN, ASEAN-KOREA
- បន្តចូលរួមកិច្ចប្រជុំ ក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន (AWGIPC) និងអនុវត្តផែនការសកម្មភាពអាស៊ាន ២០១៦-២០២៥
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលកម្មសិទ្ធិបញ្ញា ក្រោមកិច្ចព្រមព្រៀងបង្កើតមជ្ឈមណ្ឌលជាតិបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា រវាងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងនាយកដ្ឋានកម្មសិទ្ធិបញ្ញា
- សម្របសម្រួលបង្កើតមជ្ឈមណ្ឌលគាំទ្របច្ចេកវិទ្យា និងការច្នៃប្រឌិត នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- បន្តសហការជាមួយអង្គការ WIPO ដើម្បីធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងកម្មសិទ្ធិបញ្ញា (IPAS)
- រៀបចំបញ្ជីគ្រប់គ្រងទំនិញ និងសេវា (MGS) សម្រាប់បង្កលក្ខណៈងាយស្រួលក្នុងការចុះបញ្ជី
- សហការជាមួយអង្គការ WIPO ដើម្បីរៀបចំពិធីប្រកួតប្រជែងបច្ចេកវិទ្យាសមស្រប
- ស្វែងរកកិច្ចឧបត្ថម្ភ និងរៀបចំព្រឹត្តិការណ៍ណាមួយក្នុងទិវាកម្មសិទ្ធិបញ្ញា
- បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យតាមបណ្តាខេត្ត-ក្រុង ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយទស្សនទានអំពីកម្មសិទ្ធិបញ្ញា នីតិវិធីចុះបញ្ជី ការកសាងម៉ាកយីហោ និងការអនុវត្តច្បាប់
- បន្តសិក្សាលើលទ្ធភាពចូលជាសមាជិកនៃកិច្ចព្រមព្រៀងអនុសញ្ញាឬសន្ធិសញ្ញាអន្តជាតិមួយចំនួន
- រៀបចំប្រកាស ស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា និងនីតិវិធីដោះស្រាយវិវាទ
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា
- រៀបចំសេចក្តីព្រាងប្រកាស ឬអនុក្រឹត្យស្តីពីការកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ និងអាជ្ញាប័ណ្ណពិសេស
- រៀបចំសេចក្តីព្រាងច្បាប់ ស្តីពីព័ត៌មានសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់
- ស្វែងរកដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញ និងអភិវឌ្ឍផលិតផលសក្តានុពលសម្រាប់ចុះបញ្ជីជាទំនិញសម្គាល់ភូមិសាស្ត្របន្ថែមទៀត

- សហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីបន្តអនុវត្តគម្រោងជំរុញ និងអភិវឌ្ឍ "ក្រូចថ្លុងកោះទ្រង់" ក្នុងខេត្តក្រចេះ សម្រាប់ចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- សហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក សហព័ន្ធចុងភៅ និងសណ្ឋាគារ ដើម្បីបន្តអនុវត្តគម្រោងជំរុញ និងកសាងម៉ាកយីហោ "គុយទាវភ្នំពេញ" សម្រាប់ចុះបញ្ជីការពារជាម៉ាកសមូហភាព
- សហការជាមួយប្រទេសកូរ៉េ ដើម្បីលើក និងអនុវត្តគម្រោងជំរុញ និងកសាងម៉ាកយីហោ "ម្រេចមេមត់" សម្រាប់ចុះបញ្ជីការពារជាម៉ាកសមូហភាព ។

## ៩. ការងារនាំចេញ-នាំចូលពាណិជ្ជកម្ម

- រៀបចំកម្មវិធី និងវគ្គបណ្តុះបណ្តាល ដល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម
- បន្តថែទាំ កែលម្អប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធរៀបចំតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ D ទៅក្នុងបញ្ជរតែមួយជាតិ និងឈានទៅការភ្ជាប់បញ្ជរតែមួយអាស៊ាន
- បន្តធ្វើប្រតិភូកម្មក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ D សម្រាប់ទំនិញ កសិផលគ្រប់មន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន
- បន្តជំរុញការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្ម វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់D ពីតំបន់សេដ្ឋកិច្ចពិសេស ទូទាំងព្រះរាជាណាចក្រកម្ពុជាទៅក្នុងប្រព័ន្ធ ASYCUDA នៃប្រព័ន្ធបញ្ជរតែមួយជាតិ និងបញ្ជរតែមួយអាស៊ាន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការប្រើប្រាស់គម្រោងចុះបញ្ជីអ្នកនាំចេញ (Registered Exporter- REX SYSTEM) ដល់អ្នកនាំចេញទំនិញទៅសហភាពអឺរ៉ុបដើម្បីត្រៀមខ្លួនអនុវត្តនៅដើមឆ្នាំ២០១៩
- រៀបចំបន្ថែម CO ទម្រង់ផ្សេងៗទៀតស្របតាមវិធានប្រភពដើមនៃប្រទេសនាំចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម
- រៀបចំបញ្ចូល QR Code ទៅក្នុងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ CO
- បន្តការធ្វើសាមញ្ញកម្មដំណើរការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- បន្តរៀបចំតភ្ជាប់ប្រព័ន្ធ e-payment ជាមួយរតនាគារជាតិ និងធនាគារផ្សេងៗទៀត
- បន្តសហការ និងចូលរួមចុះអង្កេតប្រភពដើមទំនិញជាមួយគយ ក្រុមការងារចុះអង្កេតនានានៃប្រទេសផ្តល់ភាពអនុគ្រោះពាណិជ្ជកម្ម។

## ១០. ការងារព័ត៌មានពាណិជ្ជកម្ម

- បន្តរៀបចំចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសដូចជា៖
  - ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ
  - ពិព័រណ៍ផលិតផលនាំចេញ-នាំចូល និងខេត្ត១ ផលិតផល១
- បន្តរៀបចំចូលរួមពិព័រណ៍ពាណិជ្ជកម្ម និងសន្និបាតក្រៅប្រទេសដូចជា៖
  - ពិព័រណ៍វិនិយោគ និងផលិតផលអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ឆ្នាំ២០១៨ នៅទីក្រុងគុនមីញ

- ពិព័រណ៍ចិន-អាស៊ាន លើកទី១៥ ឆ្នាំ២០១៨ ទីក្រុងណាននីង ដោយប្រទេសកម្ពុជាធ្វើជាប្រទេសកិត្តិយស
- ពិព័រណ៍ពិភពលោកឆ្នាំ២០២០ នៅទីក្រុងឌុយបៃ សហភាពអារ៉ាប់អេមីរ៉ាត់
- សន្និបាតការិយាល័យពិព័រណ៍អន្តរជាតិ (BIE)

## ១១. ការងារអភិវឌ្ឍន៍ទីផ្សារ

- បន្តរៀបចំការតាំងបង្ហាញផ្សព្វផ្សាយ និងប្រឹក្សាយោបល់លើផលិតផលកម្ពុជាសំខាន់ៗ ចំនួន១០មុខ នៅមន្ទីរពាណិជ្ជកម្មខេត្តចំនួន០៦ ទៀត
- បន្តរៀបចំសិក្ខាសាលាចងក្រងអត្តសញ្ញាណផលិតផលសក្តានុពលកម្ពុជា និងអមដោយការតាំងបង្ហាញផលិតផលខ្មែរ ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងពង្រីកការនាំចេញផលិតផលទាំងនោះ ទៅទីផ្សារអន្តរជាតិ និងនៅរាជធានី-ខេត្ត
- បន្តការទទួលរៀបចំជំនួបពាណិជ្ជកម្ម រវាងពាណិជ្ជករក្នុងប្រទេសជាមួយពាណិជ្ជករក្រៅប្រទេស និងបន្តដឹកនាំពាណិជ្ជករទៅបំពេញបេសកកម្មពាណិជ្ជកម្មនៅក្រៅប្រទេស រួមមាន៖ ជប៉ុន កូរ៉េ ឥណ្ឌា កាណាដា ចិន ថៃ វៀតណាម និងអឺរ៉ុប
- បន្តសហការជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ត្រួតពិនិត្យការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងបន្តសិក្សាដើម្បីបង្កើតបន្ថែមទៀត នៅខេត្តកំពតនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំបញ្ជូនផលិតផលខ្មែរ ដើម្បីយកទៅផ្សព្វផ្សាយរកទីផ្សារនៅមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាដែលបានបើករួចចំនួន ៥ទីតាំង និងរៀបចំវេទិកាផ្សព្វផ្សាយ
- បន្តសហការជាមួយក្រុមហ៊ុនឯកជន ដើម្បីបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាថ្មីចំនួន ០៥ ថែមទៀត នៅប្រទេសចិន ប្រទេសថៃ និងប្រទេសវៀតណាម
- បង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា នៅតាមបណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសក្តានុពល ដើម្បីជំរុញផ្សព្វផ្សាយ និងរកទីផ្សារ
- បន្តសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រុមហ៊ុនឯកជនចិន សាងសង់ភូមិវប្បធម៌កម្ពុជា-ចិន នៅទីក្រុងប៉េកាំង និងរៀបចំការសម្ពោធដាក់ឲ្យដំណើរការ ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្ម ទេសចរណ៍ និងវប្បធម៌ រួមគ្នាកម្ពុជា-ចិន
- បន្តពិនិត្យលើលទ្ធភាពបង្កើតស្ថានទីប្រឹក្សាពាណិជ្ជកម្មកម្ពុជា អមស្ថានអគ្គរាជទូតប្រចាំនៅក្រៅប្រទេស ដែលមានសក្តានុពលថែមទៀត
- បន្តកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចរចាជាមួយប្រទេសចិន ជាពិសេសជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័ក្ត (AQSIQ) នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីចុះបញ្ជីនាំផលិតផលកម្ពុជាចូលទីផ្សារចិន នូវមុខទំនិញមួយចំនួនទៀត គឺ៖ ម្រេច កញ្ចុងអង្ករ សណ្តែកសៀង ផ្លែស្វាយ ផ្លែចេក ផ្លែមៀន គ្រាប់កាហ្វេ ផ្លែស្រកានាគ សំបុកទឹកមាត់ត្រចៀកកាំ និងផលិតផលផ្សេងៗទៀត
- បន្តរៀបចំបង្កើតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង
- បន្តការរៀបចំវេទិកាជំរុញពាណិជ្ជកម្មនៅក្រៅប្រទេស ដូចជា៖ នៅប្រទេសចិន និងបណ្តាប្រទេសផ្សេងទៀត ទៅតាមលទ្ធភាពជាក់ស្តែង
- រៀបចំធ្វើជាម្ចាស់ផ្ទះរៀបចំជំនួបពាណិជ្ជកម្មលើកទី៥ ឥណ្ឌា-CLMV នៅកម្ពុជា “The 5th India - CLMV Business Conclave in Cambodia” ថ្ងៃទី២៩-៣០ ខែមីនា ឆ្នាំ២០១៨

- បន្តរៀបចំសិក្ខាសាលា និងវេទិកា ស្តីពី "ការពិគ្រោះយោបល់រវាងអ្នកផលិត និងអ្នកផ្គត់ផ្គង់ផលិតផលខ្មែរ ជាមួយអ្នកប្រើប្រាស់ និងអ្នកចែកចាយបន្ត" នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពរដ្ឋមន្ត្រី ក្រសួងចំនួន ០៤ គឺៈ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរាជធានីភ្នំពេញ
- បន្តចាត់ចែងរៀបចំជំនួបពាណិជ្ជកម្ម និងធុរកិច្ចពាណិជ្ជកម្មក្នុងប្រទេស។

## ១២. ការងារអភិវឌ្ឍន៍គោលនយោបាយ

- បន្តរៀបចំកសាងគោលនយោបាយជំរុញការនាំចេញលើផលិតផលសក្តានុពលផ្សេងៗ ទៀត ដូចជាៈ ដំឡូងមី ពោត ស្វាយ សណ្តែកសៀង ស្វាយចន្ទី កៅស៊ូ និងផលិតផលកសិកម្មដទៃទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់
- បន្តរៀបចំវេទិកាធុរកិច្ច វិនិយោគ និងទេសចរណ៍ ក្នុងឱកាសដែលប្រទេសកម្ពុជាបានចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ចិន-អាស៊ានប្រចាំឆ្នាំ និងពិព័ណ៌ពិភពលោក នាពេលខាងមុខ
- ផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយទ្រទ្រង់ពាណិជ្ជកម្មក្នុងស្រុក តាមរយៈការរៀបចំវេទិកា ឬសន្និសីទថ្នាក់ជាតិ លើគោលនយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្មកម្ពុជាលើកទី៦/ទី៧ ក្នុងខេត្តគោលដៅ (ខេត្តព្រះសីហនុ សៀមរាប ឬ ខេត្តយុទ្ធសាស្ត្រតាមការសម្រេចរបស់ក្រសួង)
- បន្តរៀបចំទិវាជាតិដំឡូងមីកម្ពុជាលើកទី៣ វេទិកាម្រេចលើកទី២ វេទិកាកៅស៊ូ វេទិកាស្វាយចន្ទី វេទិកាបន្លែ និងផ្លែឈើខ្មែរនៅតាមមូលដ្ឋាន ដើម្បីជំរុញផលិតករ កសិករ សមាគមអាជីវកម្ម ខិតខំផលិតទំនិញ និងសេវាកម្មអនុលោមតាមស្តង់ដារផលិតកម្ម សម្រាប់បម្រើទីផ្សារ
- បន្តរៀបចំវគ្គបណ្តុះបណ្តាល រៀបចំសិក្ខាសាលា សន្និសីទ និងតាំងបង្ហាញផលិតផលហាឡាលកម្ពុជានៅរាជធានីភ្នំពេញ និងខេត្តសៀមរាប
- បន្តចូលរួមកិច្ចប្រជុំហាឡាលអាស៊ានប្រចាំឆ្នាំ លើក ១៤ នៅប្រទេសថៃ
- បន្តចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី៤៦ សហគមន៍ម្រេចអន្តរជាតិ
- បន្តចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ ថ្នាក់មន្ត្រីបច្ចេកទេស និងថ្នាក់អគ្គនាយកជំរុញពាណិជ្ជកម្ម នៃវេទិកាជំរុញពាណិជ្ជកម្មអាស៊ី (Asia Trade Promotion Forum)
- សហការរៀបចំសិក្ខាសាលា សន្និសីទ និងការផ្សព្វផ្សាយកម្មវិធីកំណែទម្រង់ក្នុងវិស័យពាណិជ្ជកម្ម និងគោលនយោបាយពាណិជ្ជកម្មជាមួយដៃគូពាក់ព័ន្ធ
- បន្តជំរុញការរៀបចំក្បាលម៉ាស៊ីនដឹកនាំវិស័យម្រេចនៅកម្ពុជា
- បន្តផែនការការងារ និងសកម្មភាពផ្សេងៗដែលនៅសេសសល់។

**១៣. ការងារសន្តិសុខស្បៀង និងសន្តិធិអាស៊ាន**

- យោងតាមគម្រោងផែនការហិរញ្ញកិច្ចឆ្នាំ ២០១៨
- បន្តសិក្សារៀបចំ និងអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនចិន ខេត្តហីណាន ទាក់ទងទៅនឹងគម្រោងសាងសង់ឃ្លាំងស្តុក ស្រូវ-អង្ករ ជាសាធារណៈ របស់រដ្ឋនៅកម្ពុជា ក្នុងក្របខ័ណ្ឌឥណទានសម្បទាន ពីសាធារណរដ្ឋប្រជាមានិតចិន។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១

ក្នុងរយៈពេល ១១ខែ ឆ្នាំ២០១៧ ការចុះបញ្ជីម៉ាក និងការងារក្រោយចុះបញ្ជី មានការកើនឡើង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ ដូចមានទិន្នន័យក្នុងតារាងខាងក្រោម៖

| ប្រភេទពាក្យស្នើសុំ | ប្រៀបធៀប | | |
|---|---|---|---|
| | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ប្រៀបធៀប |
| ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក | ៤៣២៨ | ៥១២៣ | ១៨.៣៦% |
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម | | ០១ | |
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | | ០១ | |
| ការចុះបញ្ជីម៉ាក | ៣៧៨០ | ៣៩១៧ | ៣.៦២% |
| ការទទួលពាក្យសុំស្រាវជ្រាវលទ្ធភាពចុះបញ្ជីម៉ាក | ៥១២ | ៤៨១ | -០.៦% |
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកជាអន្តរជាតិ | ១១៤៤ | ២២៥៩ | ៩៧.៤៧% |
| ការចុះបញ្ជីម៉ាកជាអន្តរជាតិ | ៣២៩ | ៨៤០ | ១៥៥.៣២% |
| ការបញ្ជាក់អំពីការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក | ២២៤៣ | ២៦៨០ | ១៩% |
| ការចុះបញ្ជីម៉ាកសាជាថ្មី | ១១៦០ | ១៨៤៦ | ៥៩% |
| ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក | ៥៦ | ៩៩ | ៧៧% |
| ការកត់ត្រាអាជ្ញាបណ្ណ ឬប្រែហ្វនឆាយ | ៣១ | ៦៤ | ១០៦% |
| ការផ្លាស់ប្តូរផ្សេងៗ | ១៩០៥ | ២០០៣ | ៥% |
| ការធ្វើទុតិយតាវិញ្ញាបនបត្រ | ៦២២ | ៦៨៤ | ១០% |
| ការផាកពិន័យមកបង់ប្រាក់ចុះបញ្ជីម៉ាកសាជាថ្មីយឺតយ៉ាវ | ០៩ | ២៤ | ១៦៧% |
| ការទទួលពាក្យសម្រុះសម្រួលវិវាទ | ១៧ករណី | ១៤ករណី | -១៨% |
| ការសម្រុះសម្រួលវិវាទ | ១២ករណី | ១៦ករណី | ៣៣% |
| ការទទួលពាក្យស្នើសុំលុបម៉ាក | ៣០ករណី | ៣១ករណី | ៣.៣% |
| ការលុបម៉ាក | ២១ម៉ាក | ១២ម៉ាក | -៤៣ |
| ការបោះពុម្ពព្រឹត្តិប័ត្រផ្លូវការប្រចាំសប្តាហ៍ | | ៤៧លេខ | |

**ប្រភព៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម**

## ឧបសម្ព័ន្ធទី ២

ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្មដែលបានអនុវត្តកន្លងមក ឃើញថាមានការកើនឡើងគួរជាទីមោទនៈ ដូចមានតារាងខាងក្រោម៖

| ល.រ | ប្រភេទសហគ្រាសពាណិជ្ជកម្ម | ៩ខែ ឆ្នាំ ២០១៦ | ៩ខែ ឆ្នាំ ២០១៧ | ប្រៀបធៀប |
|---|---|---|---|---|
| I | ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចុះបញ្ជីថ្មី)៖ | | | |
| ១. | ក្រុមហ៊ុន | ២៨៦៩ | ៤៨១២ | ៦៧,៧% |
| ២. | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (ការិយាល័យតំណាង និងសាខាក្រុមហ៊ុនបរទេស) | ៦៨ | ៨៧ | ២៩,៩% |
| ៣. | សរុប... | ២៩៣៧ | ៤៨៩៩ | ៩៨,៦% |
| | សហគ្រាសឯកបុគ្គល | ៧៨៦ | ១២០៩ | ៥៣.៨% |
| II | ការសុំវិញ្ញាបនបត្រផ្សេងៗ៖ | | | |
| ១. | ការកែប្រែផ្លាស់ប្តូរភាគហ៊ុន | ៦៧០ | ១០១៦ | ៥១,៦% |
| ២. | ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៣៨៥ | ២៣៨ | -៣៨,១% |
| ៣. | ការកែប្រែផ្សេងៗ | ៣៣៥៦ | ៦២៥០ | ៨៦,២% |
| ៤. | ពិន័យករណីមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរកែប្រែផ្សេងៗ | ៥២ | ៣៧៦ | |
| ៥. | សរុប... | ៤៤៦៣ | ៧៨៩០ | ៩៩,៧% |
| | សហគ្រាសឯកបុគ្គល | ៥០ | ៩០ | ៨០% |
| III | ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ៖ | | | |
| ១. | សេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | ១៦៩៤ | ៧៣៦៧ | ៣៣៤,៨% |
| ២. | ការពិន័យចំពោះការមិនតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | ០ | ៤០១ | |
| IV | ការថតចម្លងឯកសារ | ១៥៩ | ២ | |
| V | រំលាយ៖ | | | |
| ១. | ក្រុមហ៊ុន-ការិយាល័យតំណាង-សាខាក្រុមហ៊ុនបរទេស | ៣០ | ៥៦ | ៨៦,៦% |
| ២. | សហគ្រាសឯកបុគ្គល | ១ | ២ | ១០០% |
| VI | ការបម្រុងទុកនាមករណ៍៖ | | | |
| ១. | បម្រុងទុកនាមករណ៍ក្រុមហ៊ុន | ៤៤៥៧ | ៦៣៥ | |
| ២. | ពន្យាការបម្រុងទុកនាមករណ៍ក្រុមហ៊ុន | ៤១ | ១២៤ | |
| ៣. | បម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ៩៧៦ | ១៥០០ | |
| ៤. | ពន្យាការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ២ | ៥ | |
| VII | ការប្តូរវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្រុមហ៊ុនរដ្ឋ និងរដ្ឋចម្រុះឯកជន) | ២ | ១ | |

**ប្រភព៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម**

## ឧបសម្ព័ន្ធទី ៣

### តារាងនៃការនាំចេញរបស់តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ

| No. | Name of Special Economic Zones | Annual Export Value | | Variation | |
|---|---|---|---|---|---|
| | | 2016 | 2017 | Amount | Pct (%) |
| 1 | **Manhattan SEZ (Svay Rieng)** | 325,298,395.75 | 327,651,274.18 | 2,352,878.43 | 0.72% |
| 2 | **Tai Seng Bavet SEZ** | 250,402,058.37 | 245,377,969.87 | -5,024,088.50 | -2.01% |
| 3 | **Phnom Penh SEZ** | 166,757,068.04 | 232,547,989.86 | 65,790,921.82 | 39.45% |
| 4 | **Sihanouk Ville SEZ** | 168,868,825.09 | 210,154,034.28 | 41,285,209.19 | 24.45% |
| 5 | **Sihanouk Ville Port SEZ** | 3,598,936.52 | 5,409,313.21 | 1,810,376.69 | 50.30% |
| 6 | **Neang Kok Koh Kong SEZ** | 104,203,371.91 | 117,075,916.88 | 12,872,544.97 | 12.35% |
| 7 | **Sanco Poipet SEZ** | 253,694.08 | 2,566,308.63 | 2,312,614.55 | 911.58% |
| 8 | **Poipet O'Neang SEZ** | 5,122,362.12 | 1,793,598.83 | -3,328,763.29 | -64.98% |
| 9 | **Shandong Sunshell SEZ** | 29,846,475.78 | 37,419,718.44 | 7,573,242.66 | 25.37% |
| 10 | **Dragon King SEZ** | 7,128,326.41 | 8,481,200.49 | 1,352,874.08 | 18.98% |
| 11 | **Hi-Park SEZ** | 54,600.00 | 587,244.00 | 532,644.00 | 975.54% |
| **TOTAL** | | **1,061,534,114.07** | **1,189,064,568.67** | **127,530,454.60** | **12.01%** |

ប្រភព៖ តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

## ឧបសម្ព័ន្ធទី ៤

### តារាងទីផ្សារគោលដៅរបស់តំបន់សេដ្ឋកិច្ចពិសេស

| No | Destination Markets | Description | Unit | Year 2016 | | Year 2017 | | Variation | |
|---|---|---|---|---|---|---|---|---|---|
| | | | | Qty | Value | Qty | Value | Value | Pct (%) |
| | USA | Bicycles | PC/Set | 140,253 | 18,472,451 | 121,674 | 17,583,481.52 | -888,970 | -5% |
| | | Garment | PCS | 4,920,045 | 40,756,984.01 | 6,995,372 | 41,046,620.65 | 289,636.64 | 100% |
| | | Footwear | PRS | 575,811 | 4,328,915.60 | 324,148 | 2,458,471.56 | -1,870,444.04 | 0% |
| | | Others | N/A | - | 148,234,839.98 | | 171,288,508.78 | 23,053,669 | 16% |
| | Canada | Bicycles | PC/Set | 31,780 | 8,676,874.32 | 32,597 | 8,371,468.89 | -305,405.43 | -4% |
| | | Garment | PCS | 750,353 | 3,438,978.87 | 1,327,909 | 4,821,637.22 | 1,382,658.35 | 0% |
| | | Footwear | PRS | 29,617 | 218,004.40 | 102,456 | 344,737.50 | 126,733.10 | 0% |
| | | Others | N/A | - | 14,928,749.93 | - | 9,378,911.46 | -5,549,838.47 | -37% |
| | Others | Bicycles | PC/Set | 11,687 | 1,738,643.02 | 14,116 | 2,502,718.55 | 764,075.53 | 44% |
| | | Garment | PCS | 983,225 | 6,263,608.71 | 973,637 | 5,844,671.30 | -418,937.41 | 0% |
| | | Footwear | PRS | 487,866 | 5,790,193.33 | 327,694 | 2,769,909.33 | -3,020,284.00 | 0% |
| | | Others | N/A | - | 4,893,178.54 | - | 5,213,023.29 | 319,844.75 | 0% |
| ***1-Subtotal USA Continental Markets*** | | | | | ***257,741,422*** | | ***271,624,160.05*** | ***13,882,738.20*** | ***5%*** |
| | EU | Bicycles | PC/Set | 767,245 | 168,192,649.62 | 796,425 | 164,091,374.19 | -4,101,275.43 | -2% |
| | | Garment | PCS | 11,013,681 | 94,867,321.27 | 13,627,948 | 95,230,934.60 | 363,613.33 | 0% |
| | | Footwear | PRS | 3,269,530 | 21,037,313.46 | 5,045,679 | 22,333,742.99 | 1,296,429.53 | 0% |
| | | Others | N/A | - | 23,034,605.34 | - | 39,749,076.42 | 16,714,471.08 | 73% |
| | Great Britain (GB) | Bicycles | PC/Set | 339,041 | 65,178,370.72 | 394,590 | 72,422,545.28 | 7,244,174.56 | 11% |
| | | Garment | PCS | 1,729,548 | 5,506,745.38 | 1,821,264 | 8,969,939.90 | 3,463,194.52 | 0% |
| | | Footwear | PRS | 179,439 | 1,284,129.27 | 354,303 | 2,595,583.57 | 1,311,454.30 | 0% |
| | | Others | N/A | - | 2,237,944.29 | | 6,292,187.17 | 4,054,242.88 | 181% |
| | NON EU | Bicycles | PC/Set | 8,932 | 2,145,445.77 | 15,485 | 3,383,465.04 | 1,238,019.27 | 58% |
| | | Garment | PCS | 319,391 | 2,997,576.03 | 185,991 | 2,125,935.02 | -871,641.01 | 0% |
| | | Footwear | PRS | 121,792 | 1,111,497.48 | 136,397 | 1,196,027.50 | 84,530.02 | 0% |
| | | Others | N/A | - | 290,904.35 | - | 850,859.85 | 559,955.50 | 192% |
| ***2-Subtotal EU Continental Markets*** | | | | | ***387,884,502.98*** | | ***419,241,671.53*** | ***31,357,168.55*** | ***8%*** |
| | Africa | Bicycles | PC/Set | 1,778 | 431,641.85 | 1,191 | 192,770.75 | -238,871.10 | -55% |
| | | Garment | PCS | 32,447 | 733,717.80 | 272,889 | 863,564.71 | 129,846.91 | 0% |
| | | Footwear | PRS | 21,155 | 206,995.00 | 67,664 | 633,810.00 | 426,815.00 | 0% |
| | | Others | N/A | - | 960,384.90 | - | 1,346,845.67 | 386,460.77 | 0% |
| ***3-Subtotal African Continental Markets*** | | | | | ***2,332,739.55*** | | ***3,036,991.13*** | ***704,251.58*** | ***30%*** |
| | ASEAN | Bicycles | PC/Set | 3,963 | 442,293.68 | 1,469 | 480,583.08 | 38,289.40 | 9% |
| | | Garment | PCS | 354,319 | 8,083,621.54 | 26,832,152 | 9,873,214.22 | 1,789,592.68 | 0% |
| | | Footwear | PRS | 66,296 | 820,431.36 | 1,668,048 | 1,219,031.89 | 398,600.53 | 0% |
| | | Others | N/A | - | 117,577,227.34 | 8,267,382 | 164,449,310.72 | 46,872,083.38 | 100% |
| | NON ASEAN | Bicycles | PC/Set | 31,597 | 6,420,165.74 | 33,140 | 5,108,461.18 | -1,311,704.56 | -20% |
| | | Garment | PCS | 32,481,756 | 116,079,340.15 | 18,889,395 | 130,731,794.06 | 14,652,453.91 | 13% |
| | | Footwear | PRS | 1,611,458 | 17,967,597.81 | 1,229,796 | 22,099,132.62 | 4,131,534.81 | 23% |
| | | Others | N/A | - | 146,184,772.07 | - | 161,200,218.19 | 15,015,446.12 | 10% |
| ***4-Subtotal Asia & Oceania Continental Markets*** | | | | | ***413,575,449.69*** | | ***495,161,745.96*** | ***81,586,296.27*** | ***20%*** |
| **GRAND TOTAL** | | | | | **1,061,534,114.07** | | **1,189,064,568.67** | **127,530,454.60** | **12.01%** |

ប្រភព៖ តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

## ឧបសម្ព័ន្ធទី ៥

| ប្រេងសាំង | 2013 | 2014 | 2015 | 2016 | 2017 |
|---|---|---|---|---|---|
| Janury | 5250 | 5154 | 4050 | 3345 | 3710 |
| February | 5560 | 5176 | 3815 | 3345 | 3750 |
| Murch | 5417 | 5200 | 3950 | 3345 | 3668 |
| April | 5427 | 5200 | 3975 | 3185 | 3668 |
| May | 5197 | 5200 | 4120 | 3290 | 3565 |
| June | 5132 | 5208 | 4275 | 3405 | 3610 |
| July | 5263 | 5301 | 4285 | 3313 | 3500 |
| August | 4877 | 5350 | 4175 | 3182 | 3613 |
| September | 4778 | 5346 | 4214 | 3335 | 3773 |
| Octomber | 4767 | 5343 | 3700 | 3430 | 3730 |
| November | 4935 | 4767 | 3650 | 3500 | 3730 |
| December | 5064 | 4935 | 3650 | 3500 | 3730 |
| **ប្រេងម៉ាស៊ូត** Diesel | | | | | |
| Janury | 5150 | 4975 | 3850 | 3085 | 3390 |
| February | 5260 | 4983 | 3635 | 3085 | 3430 |
| Murch | 5123 | 4980 | 3800 | 3085 | 3405 |
| April | 5001 | 4974 | 3825 | 2724 | 3405 |
| May | 4947 | 4974 | 3970 | 2960 | 3282 |
| June | 5038 | 5015 | 4125 | 3095 | 3275 |
| July | 5059 | 5055 | 4135 | 3118 | 3250 |
| August | 4465 | 5050 | 4005 | 2969 | 3362 |
| September | 4401 | 5050 | 4059 | 3065 | 3455 |
| Octomber | 4386 | 5050 | 3450 | 3148 | 3420 |
| November | 4649 | 4386 | 3400 | 3200 | 3420 |
| December | 4862 | 4649 | 3400 | 3200 | 3420 |
| **ប្រេងកាត** | | | | | |
| Janury | 5500 | 5234 | 5175 | 4095 | 3500 |
| February | 5421 | 5181 | 5100 | 4095 | 3500 |
| Murch | 5316 | 5050 | 5100 | 4095 | 3500 |
| April | 5174 | 5082 | 5100 | 3500 | 3500 |
| May | 5130 | 5082 | 5100 | 3500 | 3500 |
| June | 5260 | 5441 | 5100 | 3500 | 3500 |
| July | 5227 | 5218 | 5100 | 3500 | 3500 |
| August | 4606 | 5180 | 5100 | 3500 | 3500 |
| September | 4499 | 5180 | 5100 | 3500 | 4275 |
| Octomber | 4483 | 5180 | 5100 | 3505 | 4500 |
| November | 4763 | 4483 | 5100 | 3540 | 4500 |
| December | 5034 | 4763 | 5100 | 3540 | 4500 |

**ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស**

## ឧបសម្ព័ន្ធទី ៦

### របាយការណ៍ ស្តីពីតម្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ ប្រចាំ ឆ្នាំ២០១៧

| លរ | មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | តម្លៃ (US$/T) មធ្យម ឆ្នាំ២០១៦ | តម្លៃ (US$/T) មធ្យម ឆ្នាំ ២០១៧ | មធ្យមភាគ | ភាគរយ% |
|---|---|---|---|---|---|---|
| **I-អង្ករ** | | | | | | |
| ១ | អង្ករប្រភេទបាក់ ២៥% | FOB Bangkok | 353.84 | 351.06 | -2.78 | 0.79 |
| ២ | អង្ករប្រភេទបាក់ ២៥% | FOB HCM (VN) | 333.36 | 351.46 | 18.1 | 5.43 |
| ៣ | អង្ករប្រភេទបាក់ ៤-៥% | FOB Chicago USA | 508.76 | 519.54 | 10.78 | 2.12 |
| ៤ | អង្ករប្រភេទ១០០% បេ | FOB Bangkok | 386.05 | 375.89 | -10.16 | 2.63 |
| ៥ | អង្ករប្រភេទបាក់ ៥% | FOB Bangkok | 373.89 | 365.58 | -8.31 | 2.22 |
| ៦ | អង្ករប្រភេទបាក់ ៥% | FOB HCM (VN) | 362.55 | 383.2 | 20.65 | 5.70 |
| ៧ | អង្ករប្រភេទបាក់ ១០% | - | 343.85 | 373.2 | 29.35 | 8.54 |
| ៨ | អង្ករប្រភេទបាក់ ១៥% | - | 334.56 | 361.32 | 26.76 | 8.00 |
| ៩ | អង្ករប្រភេទបាក់ ១០% | FOB Chicago USA | 489.17 | 509.51 | 20.34 | 4.16 |
| ១០ | អង្ករប្រភេទបាក់ ១៥% | FOB Chicago USA | 486.25 | 489.30 | 3.05 | 0.63 |
| ១១ | អង្ករប្រភេទផ្កាម្លិះ | FOB Bangkok | 779.97 | 769.78 | -10.19 | 1.31 |
| **II-កសិផល** | | | | | | |
| ១ | ស្រូវសាលី | FOB Chicago USA | 158.15 | 164.475 | 6.325 | 4.00 |
| ២ | ពោត | - | 130.53 | 132.81 | 2.28 | 1.75 |
| ៣ | សណ្តែកសៀង | - | 359.77 | 359.045 | -0.725 | 0.20 |
| ៤ | សណ្តែកបាយ | FOB HCM (VN) | 1,386.21 | 1,397.34 | 11.13 | 0.80 |
| ៥ | សណ្តែកដី | - | 1,666.83 | 1,751.71 | 84.88 | 5.09 |
| ៨ | ប្រេងដូងប្រេង | FOB Malaysia | 698.16 | 734.46 | 36.30 | 5.20 |
| ៩ | គ្រាប់ម្រេច ខ្មៅ | FOB (V.N) | 6,974.24 | 4,547.56 | -2,426.68 | 34.79 |
| ១០ | គ្រាប់ម្រេច ស | - | 7,549.30 | 5,327.80 | -2,221.49 | 29.43 |
| ១១ | គ្រាប់ស្វាយចន្ទីកែច្នៃរួច | FOB HCM (VN) | 6,508.79 | 5,637.39 | -871.395 | 13.39 |
| ១២ | កាហ្វេ (ROBUSTA) | CIF New York (USA) | 1,916.33 | 2,051.40 | 135.07 | 7.05 |
| ១៣ | ការហ្វេ (ARABICA) | - | 3,101.54 | 2,900.33 | -201.205 | 6.49 |
| ១៤ | កប្បាសលេខ២ | FOB New York | 1,503.46 | 1,558.91 | 55.45 | 3.69 |
| **III-ផលិតផលនេសាទ** | | | | | | |
| ១ | ត្រីប្រាស ( Fillet ) | - | 1,000.39 | 854.42 | -145.97 | 14.59 |
| ២ | មឹកបង្កក | - | 3,370.21 | 3,589.73 | 219.52 | 6.51 |
| **IV-ផលិតផលឧស្សាហកម្ម** | | | | | | |
| ១ | ស្ករស | FOB HCM (VN) | 552.90 | 403.56 | -149.34 | 27.01 |
| ២ | កៅស៊ូប្រភេទ RSS2 | FOB Tokyo (Japan) | 1,772.14 | 1,868.65 | 96.51 | 5.45 |
| **V-ប្រេងឥន្ធនៈ** | | | | | | |
| ១ | ប្រេងឆៅBrent ( $/ធុង ) | FOB England | 47.03 | 52.11 | 5.08 | 10.80 |
| ២ | ប្រេង WTI ($/ធុង) | CIF HCM (VN) | 45.59 | 47.62 | 2.03 | 4.45 |

| | | | | | | |
|---|---|---|---|---|---|---|
| VI-**លោហធាតុ** | | | | | | |
| ១ | មាស ( $ / ounce ) | Hong Kong | 1,278.20 | 1,274.30 | -3.9 | 0.31 |
| ២ | មាស ( $ / ounce ) | London | 1,278.57 | 1,274.24 | -4.33 | 0.34 |
| ៣ | ស្ពាន់ | FOB London | 4,778.03 | 6,346.90 | 1,568.87 | 32.84 |
| ៤ | អាលុយមីញ៉ូម (Al ) | - | 1,650.49 | 2,023.91 | 373.42 | 22.62 |
| ៥ | ស័ង្កសី (Zinc ) | - | 2,209.55 | 2,999.03 | 789.48 | 35.73 |
| ៦ | សំណប៉ាហាំង (Tin ) | - | 18,826.61 | 20,436.81 | 1,610.2 | 8.55 |
| ៧ | នីកែល (Nickel) | - | 10,022.72 | 10,630.76 | 608.04 | 6.07 |
| ៨ | ដែកថែបមូលអង្កត់ផ្ចិត0>4 | CIF Kgs.Som | 552.83 | 551.73 | -1.1 | 0.20 |
| ៩ | ដែកថែបអក្សរ (V) 25x25x3 | - | 597.07 | 596.45 | -0.62 | 0.10 |
| ១០ | ដែកថែបអក្សរ (U) 50x25x3 | - | 542.18 | 541.45 | -0.73 | 0.13 |
| VII-**អត្រាប្តូរប្រាក់** | | | | | | |
| ១ | ដុល្លារអាមេរិក USD / EURO | London | 0.9043 | 0.8700 | -0.0343 | 3.79 |
| ២ | យ៉េនជប៉ុន USD/Y | Tokyo | 106.01 | 112.03 | 6.02 | 5.68 |

ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

**សំគាល់៖**

**តម្លៃអង្ករ៖** បើសង្កេតជារួមតម្លៃអង្ករនាំចេញគ្រប់ប្រភេទនៅលើទីផ្សារពិភពលោកប្រចាំឆ្នាំ២០១៧ នេះ មានការប្រែប្រួលទៅតាមតំបន់ ធៀបទៅនឹងឆ្នាំ២០១៦។ នៅប្រទេសថៃតម្លៃអង្ករប្រភេទ២៥% លក់ចេញបានថយចុះ២១,៧៨ ដុល្លារ/តោន គឺស្មើនឹង០,៧៩% ដោយលក់ចេញក្នុងតម្លៃ៣៥១,០៦ដុល្លារ/តោន, FOB Bangkok និងនៅវៀតណាមតម្លៃអង្ករប្រភេទដូចគ្នានេះបានកើន១៨,១០ ដុល្លារ/តោន គឺស្មើនឹង៥,៤៣% ដោយលក់ចេញក្នុងតម្លៃ ៣៥១,៤៦ ដុល្លារ/តោន (FOBកំពង់ផែក្រុងហូជីមិញ) ។

**ពោត៖** បើធៀបទៅនឹងឆ្នាំ២០១៦នេះ តម្លៃពោតលក់ចេញក្នុងឆ្នាំ២០១៧នេះ នៅChicago(អាមេរិក ) បានកើនឡើង ២,២៨ ដុល្លារ/តោន គឺស្មើនឹង១,៧៥% ដោយលក់ចេញក្នុងតម្លៃ ១៣២,៨១ ដុល្លារ/តោន, FOB Chicago។

**តម្លៃសណ្តែកសៀង៖** នៅក្នុងឆ្នាំ២០១៦នេះ តម្លៃសណ្តែកសៀងលក់ចេញក្នុងតម្លៃជាមធ្យម ៣៥៩,០៥៥ ដុល្លារ/តោន FOBChicago(អាមេរិក) បើធៀបទៅនឹងឆ្នាំ ២០១៦ តម្លៃសណ្តែកសៀងបានថយចុះជាមធ្យម ០,៧២ ដុល្លារ/តោន គឺស្មើនឹង០,២០% ។

**តម្លៃសណ្តែកបាយ៖** សណ្តែកបាយលក់ចេញជាមធ្យមថ្លៃ ១,៣៩៧.៣៤ ដុល្លារ/តោន ( FOBកំពុងផែក្រុងហូជីមិញ) នៅក្នុងឆ្នាំ២០១៧ បើធៀបទៅនឹងឆ្នាំ២០១៦ តម្លៃសណ្តែកបាយគឺបានកើនឡើងជាមធ្យម ១១,១៣ដុល្លារ/តោន គឺស្មើនឹង០,៨០%។

**សណ្តែកដី៖** សណ្តែកដីលក់ចេញជាមធ្យមថ្លៃ១,៧៥១.៧១ ដុល្លារ/តោន(FOBកំពង់ផែក្រុងហូជីមិញ)នៅក្នុងឆ្នាំ២០១៧នេះ បើធៀបទៅនឹងឆ្នាំ ២០១៦ គឺបានកើនឡើងជាមធ្យម ៨៤,៨៨ ដុល្លារ/តោនគឺស្មើនឹង ៥,០៩%។

**តម្លៃប្រេងដូងប្រេង៖** តម្លៃប្រេងដូងប្រេងនៅក្នុងឆ្នាំ២០១៧ លក់ចេញជាមធ្យមថ្លៃ៧៣៤,៨៦ ដុល្លារ/តោន ,FOB Malaysia បើធៀបទៅនឹងឆ្នាំ២០១៦ គឺ បានកើនឡើងជាមធ្យម ៣៦,៣០ ដុល្លារ/តោន គឺស្មើនឹង ៥,២០%។

**តម្លៃកាហ្វេ៖** នៅក្នុងឆ្នាំ២០១៧នេះ តម្លៃកាហ្វេបានកើនឡើង និងថយចុះទៅតាមប្រភេទនីមួយៗ។ នៅNewYork (អាមេរិក) តម្លៃកាហ្វេរ៉ូប៊ូស្តាលក់ចេញជាមធ្យមថ្លៃ ២,០៥១.៤០ ដុល្លារ/តោន, Cif NewYork (អាមេរិក) បើធៀបទៅនឹងឆ្នាំ២០១៦ គឺ

បានកើនឡើងជាមធ្យម ១៣៥,០៧ ដុល្លារ/តោន គឺស្មើនឹង ៧,០៥% និងផ្ទុយទៅវិញ នៅទីក្រុងឡុងដ៍តម្លៃកាហ្វេអារ៉ាប៊ីកាលក់ចេញបានថយចុះ២០១,២០ដុល្លារ/តោន គឺស្មើនឹង៦,៩៩% ដោយលក់ចេញក្នុងតម្លៃជាមធ្យម២,៩០០.៣៣ដុល្លារ/តោន។

**តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2៖** នៅក្នុងឆ្នាំ២០១៧នេះ តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2 នៅតូក្យូប្រទេសជប៉ុន លក់ចេញជាមធ្យមថ្លៃ១,៨៦៨.៦៥ ដល្លារ/តោន, FOB Tokyo បើធៀបទៅនឹងឆ្នាំ២០១៦ គឺបានកើនឡើងជាមធ្យម ៩៦,៥១ ដុល្លារ គឺស្មើនឹង ៥,៤៥% ។

**តម្លៃប្រេងឆៅ (Brent)៖** តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ទីក្រុងឡុងដ៍) បានកើនឡើងជាមធ្យម៥,០៨ ដុល្លារ/ធុង (១០,៨០%)នៅក្នុងឆ្នាំ២០១៧នេះ ធៀបទៅនឹងឆ្នាំ២០១៦ ដោយលក់ចេញនៅក្នុងតម្លៃជាមធ្យម៥២,១១ ដុល្លារ/ធុង និងនៅក្នុងឆ្នាំ២០១៦ តម្លៃលក់ជាមធ្យម៤៧,០៣ដុល្លារ/ធុង ។

**តម្លៃមាស៖** នៅក្នុងឆ្នាំ២០១៧ នេះនៅហុងកុងតម្លៃមាសលក់ចេញជាមធ្យមថ្លៃ ១,២៧៤.៣០ដុល្លារ/Ounce,FOB ហុងកុង។ បើធៀបទៅនឹងឆ្នាំ២០១៦ តម្លៃមាសបានថយចុះជាមធ្យម ៣,៩០ ដុល្លារ/ Ounce គឺស្មើនឹង០,៣១% និងនៅទីក្រុងឡុងដ៍តម្លៃមាសលក់ចេញជាមធ្យមថ្លៃ ១,២៧៤.២៤ ដុល្លារ/ Ounce,FOBឡុងដ៍ គឺបានថយជាមធ្យម៤,៣៣ ដុល្លារ/ Ounce គឺ ស្មើនឹង ០,៣៤% ។

**តម្លៃរូបិយ៍បណ្ណ៖** តម្លៃរូបិយ៍បណ្ណបរទេសជាពិសេសប្រាក់ដុល្លារអាមេរិកបានថយចុះ ធៀបទៅនឹងប្រាក់អឺរ៉ូ។ នៅទីក្រុងឡុងដ៍ក្នុងឆ្នាំ២០១៧នេះ តម្លៃប្រាក់អឺរ៉ូលក់ចេញជាមធ្យមថ្លៃ០,៨៧០០ អឺរ៉ូ/ដុល្លារ បើធៀបទៅនឹងឆ្នាំ២០១៦ គឺបានថយចុះជាមធ្យម០.០៣៤៣អឺរ៉ូ/ដុល្លារ ស្មើនឹង៣,៧៩%និង ប្រាក់យ៉េនជប៉ុនថយ៦,០២ យ៉េន/ដុល្លារ ស្មើនឹង៥,៦៨% ដោយលក់ចេញក្នុងតម្លៃជាមធ្យម១១២,០៣យ៉េន/ដុល្លារ និងនៅឆ្នាំ២០១៦លក់ចេញជាមធ្យមថ្លៃ១០៦,០១ យ៉េន/ដុល្លារ។

# ឧបសម្ព័ន្ធទី ៧

| ល.រ | រាយមុខទំនិញ | ឯកតា | Jan-17 | Feb-17 | Mar-17 | Apr-17 | May-17 | Jun-17 | Jul-17 | Aug-17 | Sep-17 | Oct-17 | Nov-17 | Dec-17 | Average |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| I | **តម្លៃអង្ករលក់រាយនៅភ្នំពេញ** | | | | | | | | | | | | | | |
| 1 | អង្ករសូម៉ាលី.ផ្កាម្លិះបាត់ដំបង | R/Kg | 3,350 | 3,400 | 3,425 | 3,575 | 3,575 | 3,500 | 3,475 | 3,600 | 3,650 | 3,650 | 3,600 | 3,530 | **3,527.50** |
| 2 | អង្ករផ្កាខ្ញីបាត់ដំបង | R/Kg | 2,525 | 2,550 | 2,600 | 2,675 | 2,700 | 2,700 | 2,688 | 2,700 | 2,713 | 2,700 | 2,700 | 2,600 | **2,654.25** |
| 3 | អង្ករនាងខុនបាត់ដំបង | R/Kg | 2,350 | 2,300 | 2,300 | 2,300 | 2,330 | 2,420 | 2,430 | 2,495 | 2,510 | 2,500 | 2,400 | 2,400 | **2,394.58** |
| 4 | អង្ករនាងម៉ិញបាត់ដំបង | R/Kg | 2,250 | 2,300 | 2,125 | 2,200 | 2,210 | 2,240 | 2,225 | 2,215 | 2,213 | 2,200 | 2,200 | 2,200 | **2,214.83** |
| 5 | អង្ករសូម៉ាលីមោងឫស្សី | R/Kg | 2,850 | 2,800 | 2,800 | 2,950 | 3,025 | 3,100 | 3,100 | 3,127 | 3,108 | 3,100 | 3,100 | 3,100 | **3,013.33** |
| 6 | អង្ករផ្កាខ្ញីមោងឫស្សី | R/Kg | 2,300 | 2,300 | 2,300 | 2,375 | 2,400 | 2,400 | 2,400 | 2,450 | 2,500 | 2,500 | 2,500 | 2,500 | **2,410.42** |
| 7 | អង្ករចំរុះមោងឫស្សី | R/Kg | 2,075 | 2,000 | 2,000 | 2,000 | 2,000 | 2,000 | 2,000 | 2,000 | 2,050 | 2,100 | 2,100 | 2,100 | **2,035.42** |
| 8 | អង្ករផ្កាខ្ញីតាកែវ | R/Kg | 2,300 | 2,300 | 2,325 | 2,400 | 2,400 | 2,400 | 2,400 | 2,450 | 2,500 | 2,500 | 2,500 | 2,500 | **2,414.58** |
| 9 | អង្ករសក្រហមតាកែវកំពង់ស្ពឺ | R/Kg | 1,900 | 1,845 | 1,875 | 1,975 | 2,000 | 2,025 | 2,000 | 2,000 | 2,000 | 2,000 | 2,000 | 2,000 | **1,968.33** |
| 10 | អង្ករអ៊ីអ៊ែរ បន្លាផ្ដៅ | R/Kg | 1,720 | 1,730 | 1,760 | 1,780 | 1,785 | 1,800 | 1,800 | 1,780 | 1,780 | 1,740 | 1,740 | 1,740 | **1,762.92** |
| II | **តម្លៃស្រូវប្រាំងដល់រោងម៉ាស៊ីន** | | | | | | | | | | | | | | |
| 11 | ស្រូវខេត្ត តាកែវ | R/Kg | 1,100 | 1,075 | 1,050 | 1,050 | 1,050 | 1,050 | 1,050 | 943 | 1,033 | 1,100 | 1,080 | 1,080 | **1,055.08** |
| 12 | ស្រូវខេត្ត ព្រៃវែង | R/Kg | 773 | 815 | 780 | 773 | 788 | 830 | 835 | 843 | 860 | 830 | 820 | 820 | **813.92** |
| 13 | ស្រូវជុំវិញ ភ្នំពេញ | R/Kg | 1,235 | 1,230 | 1,240 | 1,303 | 1,313 | 1,358 | 1,378 | 1,445 | 1,450 | 1,380 | 1,300 | 1,200 | **1,319.33** |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| III | **តម្លៃស្រូវ ទស្សាដល់រោងម៉ាស៊ីន** | | | | | | | | | | | | | | | |
| 14 | ស្រូវចំរុះតាកែវ ព្រៃវែង កណ្តាល | R/Kg | 952 | 1,006 | 1,081 | 1,108 | 1,124 | 1,126 | 1,141 | 1,149 | 1,141 | 1,132 | 1,080 | 970 | **1,084.17** |
| 15 | ផ្កាម្លិះ | R/Kg | 1,373 | 1,385 | 1,394 | 1,406 | 1,422 | 1,437 | 1,501 | 1,580 | 1,580 | 1,350 | 1,160 | 1,160 | **1,395.67** |
| 16 | សូម៉ាលី | R/Kg | 1,334 | 1,374 | 1,382 | 1,393 | 1,400 | 1,413 | 1,475 | 1,550 | 1,550 | 1,450 | 1,140 | 1,100 | **1,380.08** |
| 17 | ផ្កាខ្ញី | R/Kg | 954 | 1,063 | 1,070 | 1,100 | 1,140 | 1,140 | 1,170 | 1,180 | 1,180 | 1,150 | 1,150 | 1,130 | **1,118.92** |
| 18 | នាងខុន | R/Kg | 918 | 990 | 1,043 | 1,100 | 1,100 | 1,100 | 1,160 | 1,180 | 1,180 | 1,130 | 1,130 | 1,130 | **1,096.75** |
| 19 | នាងម៉ិញ | R/Kg | 883 | 968 | 1,005 | 1,035 | 1,050 | 1,050 | 1,113 | 1,048 | 1,065 | 1,068 | 1,068 | 1,020 | **1,031.08** |
| 20 | ល្ងស | R/Kg | 1,011 | 9,800 | 9,778 | 9,778 | 7,592 | 9,980 | 9,355 | 9,660 | 9,680 | 9,400 | 9,960 | 9,960 | **8,829.48** |
| 21 | ល្ងខ្មៅ | R/Kg | 9,980 | 9,800 | 9,835 | 9,835 | 9,863 | 9,770 | 9,355 | 9,960 | 9,680 | 9,400 | 9,960 | 9,960 | **9,783.13** |
| 22 | សណ្តែកសៀង | R/Kg | 4,100 | 4,100 | 4,230 | 4,230 | 4,165 | 4,250 | 4,245 | 4,230 | 4,200 | 4,200 | 4,200 | 4,200 | **4,195.83** |
| 23 | សណ្តែកបាយ | R/Kg | 6,850 | 6,780 | 6,581 | 6,581 | 6,698 | 6,510 | 6,505 | 6,490 | 6,460 | 6,460 | 7,840 | 7,840 | **6,799.58** |
| 24 | ម្រេច | R/Kg | 37,560 | 36,600 | 37,900 | 37,900 | 37,490 | 38,620 | 36,070 | 35,600 | 35,600 | 35,600 | 35,700 | 35,700 | **36,695.00** |
| 25 | ខ្ទឹមស | R/Kg | 5,670 | 6,015 | 6,560 | 6,560 | 6,201 | 5,380 | 5,760 | 5,600 | 5,600 | 5,300 | 5,300 | 5,300 | **5,770.52** |
| 26 | សណ្តែកដីគ្រាប់ | R/Kg | 7,040 | 7,040 | 7,675 | 7,675 | 7,358 | 7,680 | 7,910 | 7,870 | 7,870 | 7,840 | 7,840 | 7,840 | **7,636.46** |
| 27 | គ្រាប់ស្វាយចាន់ទីបកសំបករួច | R/Kg | 41,480 | 41,600 | 42,120 | 42,120 | 41,830 | 42,400 | 42,400 | 42,400 | 35,600 | 42,400 | 42,400 | 42,400 | **41,595.83** |
| IV | **តម្លៃ ត្រី សាច់ និង ម្ហូបអាហារ** | | | | | | | | | | | | | | | |
| 28 | ចេកណាំវ៉ា | R/hand | 3,210 | 3,240 | 3,279 | 3,279 | 3,252 | 3,280 | 3,210 | 3,210 | 3,200 | 3,200 | 3,200 | 3,200 | **3,230.00** |
| 29 | ម្នាស់ | R/Unit | 2,500 | 2,500 | 2,435 | 2,435 | 2,468 | 2,420 | 2,490 | 2,490 | 2,415 | 2,400 | 2,400 | 2,400 | **2,446.04** |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 30 | ក្រូចពោធិសាត់ | R/Doz | 17,420 | 17,510 | 17,270 | 17,270 | 17,368 | 17,220 | 17,040 | 17,040 | 16,830 | 16,800 | 16,800 | 16,800 | **17,113.96** |
| 31 | ប៊ីចេង | R/Parked | 5,500 | 6,480 | 7,665 | 7,665 | 6,828 | 5,525 | 5,550 | 5,601 | 5,601 | 5,574 | 5,598 | 5,598 | **6,098.71** |
| 32 | ស្ករសថៃ | R/Kg | 2,714 | 2,888 | 3,005 | 3,005 | 2,903 | 3,054 | 3,100 | 3,015 | 3,015 | 3,000 | 3,000 | 3,000 | **2,974.92** |
| 33 | ស្ករត្នោត | R/Kg | 4,718 | 4,790 | 4,680 | 4,680 | 4,717 | 4,680 | 4,680 | 4,680 | 4,680 | 4,480 | 4,585 | 4,585 | **4,662.92** |
| 34 | អំបិលម៉ត់ | R/Kg | 1,268 | 1,280 | 1,260 | 1,260 | 1,267 | 1,240 | 1,240 | 1,240 | 1,240 | 1,240 | 1,240 | 1,240 | **1,251.25** |
| 35 | ត្រកួន | R/Kg | 2,920 | 2,920 | 2,846 | 2,846 | 2,883 | 2,970 | 3,205 | 3,240 | 3,240 | 3,040 | 3,223 | 3,223 | **3,046.33** |
| 36 | ប៉េងប៉ោះ | R/Kg | 3,726 | 3,780 | 3,155 | 3,155 | 3,454 | 3,180 | 3,435 | 3,640 | 3,650 | 3,840 | 3,790 | 3,790 | **3,549.58** |
| 37 | សាច់គោ | R/Kg | 37,240 | 37,240 | 37,740 | 37,740 | 37,490 | 36,300 | 36,500 | 35,940 | 35,940 | 36,280 | 34,106 | 34,106 | **36,385.17** |
| 38 | សាច់ជ្រូក | R/Kg | 20,200 | 20,120 | 19,280 | 19,280 | 19,720 | 18,840 | 18,420 | 18,570 | 18,570 | 18,600 | 18,600 | 18,600 | **19,066.67** |
| 39 | សាច់មាន់ | R/Kg | 23,500 | 22,930 | 20,305 | 20,305 | 21,760 | 19,248 | 18,500 | 18,910 | 18,910 | 20,104 | 20,104 | 20,104 | **20,390.00** |
| 40 | ត្រី រ៉ស់ស្រស់ | R/Kg | 20,840 | 20,260 | 16,895 | 16,895 | 18,723 | 17,520 | 19,200 | 18,800 | 18,650 | 18,800 | 18,800 | 18,800 | **18,681.88** |
| 41 | ស្ពៃក្តោប | R/Kg | 2,670 | 2,760 | 2,685 | 2,685 | 2,700 | 2,590 | 2,705 | 2,705 | 2,800 | 3,020 | 2,980 | 2,980 | **2,773.33** |
| 42 | ត្រសក់ | R/Kg | 2,652 | 2,615 | 2,160 | 2,160 | 2,397 | 2,390 | 2,515 | 2,515 | 2,460 | 2,660 | 2,520 | 2,520 | **2,463.65** |
| 43 | ពងមាន់ | 10/Eggs | 4,480 | 4,480 | 4,493 | 4,493 | 4,487 | 4,480 | 4,410 | 4,410 | 5,400 | 4,524 | 4,542 | 4,542 | **4,561.71** |
| 44 | ពងទា | 10/Eggs | 5,500 | 5,472 | 5,295 | 5,295 | 5,391 | 5,240 | 5,170 | 5,170 | 5,228 | 5,260 | 5,260 | 5,260 | **5,295.04** |
| **V** | **ប្រេងឥន្ធនៈ** | | | | | | | | | | | | | | |
| 45 | ប្រេងសាំង | R/L | 3,710 | 3,750 | 3,668 | 3,668 | 3,699 | 3,610 | 3,500 | 3,613 | 3,773 | 3,760 | 3,730 | 3,750 | **3,685.92** |
| 46 | ប្រេងម៉ាស៊ូត | R/L | 3,390 | 3,430 | 3,405 | 3,405 | 3,408 | 3,275 | 3,250 | 3,362 | 3,455 | 3,460 | 3,420 | 3,400 | **3,388.29** |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 47 | ប្រេងកាត | R/L | 3,500 | 3,500 | 3,500 | 3,500 | 3,500 | 3,500 | 3,500 | 4,250 | 4,275 | 4,500 | 4,500 | 4,500 | **3,877.08** |
| **VI** | **អត្រាប្តូរប្រាក់ និងរូបិយវត្ថុ** | | | | | | | | | | | | | | |
| 48 | ដុល្លារអាមេរិក | R/USD | 4,038 | 4,019 | 3,996 | 3,997 | 4045 | 4,082 | 4,091 | 4,098 | 4,050 | 4,052 | 4,044 | 4,045 | **4,046.40** |
| 49 | បាតថៃ | R/Baht | 113 | 114 | 114 | 114 | 117 | 119 | 121 | 124 | 123 | 122 | 122 | 122 | **80.90** |
| 50 | ១ជីមាសគីឡូ | R/Chi | 568,685 | 568,370 | 595,225 | 595,225 | 598,451 | 607,906 | 625,464 | 625,464 | 625,464 | 625,464 | 625,464 | 625,464 | **607,220** |
| 51 | ១០០ដុល្លារអាមេរិក | Chi | 0.70 | 0.70 | 0.72 | 0.72 | 0.72 | 0.72 | 0.72 | 0.72 | 0.72 | 0.72 | 0.72 | 0.72 | **0.72** |

ប្រភពៈ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស